**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ នៅឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល(២០១៥-២០១៩)

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវ និងចងក្រងដោយ

និស្សិតឈ្មោះ៖**ក.តា សុឃីម**

**ក.សរ សោភាវឌ្ឍនា**

សាស្ត្រាចារ្យណែនាំ

លោក **ផេង អ៊ី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ នៅឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល(២០១៥-២០១៩)

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវ និងចងក្រងដោយ

និស្សិតឈ្មោះ៖ **ក.ភា សុឃីម** | សាស្ត្រាចារ្យណែនាំ

**ក.សរ សោភាវឌ្ឍនា** | លោក **ផេង អ៊ី**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលសិក្សា ២០១៦

ជំនាន់ទី ១៣ (អាហារូបករណ៍) | ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ


នាងខ្ញុំឈ្មោះ **តា សុឃីម** និង **សរ សោភាចន្ថ្នា** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៣ឆ្នាំសិក្សា ២០១៩-២០២០ នៃសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

លោកឪពុក **ផុន តា** និងអ្នកម្តាយ **ផាន សុខេន** ដែលជាឪពុកម្តាយរបស់និស្សិតឈ្មោះ **តា សុឃីម** និងលោកឪពុក **សរ សារិន** និងអ្នកម្តាយ **ជា នី** ដែលជាឪពុកម្តាយរបស់និស្សិត **សរ សោភាចន្ថ្នា** ដែលលោកមានគុណទាំងបួន បានផ្តល់កំណើតដល់កូនៗ និងខិតខំបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់កូនធំដឹងក្តីព្រមទាំងខិតខំប្រឹងប្រែងទាំងកម្លាំងកាយចិត្តចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ ទូន្មានប្រៀនប្រដៅរូបកូនគ្រប់បែបយ៉ាង ទោះបីជាមានឧបសគ្គយ៉ាងណាក៏លោកទាំងពីរ នៅតែខិតខំពុះពារដោយមិនត្អូញត្អែរ និងមិនរារែកឡើយ ធ្វើយ៉ាងណាឱ្យតែកូនបានសិក្សាខ្ពង់ខ្ពស់ហើយណែនាំប្រៀនប្រដៅកូនឱ្យកូនធ្វើអំពើល្អ ធ្វើជាមនុស្សល្អ មិត្តល្អ និងមានចំណេះដឹងជ្រៅជ្រះដើម្បីក្លាយជាធនធានដ៏ល្អនៅក្នុងសង្គម និងក្លាយជាពលរដ្ឋល្អម្នាក់ដែលអាចចូលរួមអភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែរីកចម្រើន។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិកអប់រំទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំអស់ពីកម្លាំងកាយចិត្តនៅក្នុងការអប់រំដល់រូបយើងខ្ញុំ ដើម្បីជួយឱ្យយើងខ្ញុំទាំងពីរអ្នកទទួលបានចំណេះដឹងយ៉ាងប្រពៃ ព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន។

សូមថ្លែងអំណរគុណដោយឡែកលោកសាស្ត្រាចារ្យ **ឆេង អ៊ី** ជាសាស្ត្រាចារ្យផ្នែកនីតិរដ្ឋបាលនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំ តម្រង់ទិស និងផ្តល់ដំបូន្មាន ព្រមទាំងផ្តល់នូវការលើកទឹកចិត្តដល់យើងខ្ញុំក្នុងការធ្វើសារណាបញ្ចប់ការសិក្សានេះរហូតទទួលបានជោគជ័យ។

ជាទីបញ្ចប់ យើងខ្ញុំសូមលើកដៃប្តូងសួងដល់វត្ថុសក្តិសិទ្ធទាំងឡាយ និងគោរពជូនពរនូវពុទ្ធពរទាំង៤ប្រការរបស់ព្រះពុទ្ធជាម្ចាស់ ជួយតាមថែរក្សាលោកអ្នកមានគុណគ្រប់រូបដូចដែលបានរៀបរាប់ខាងលើ ព្រមទាំងមិត្តរួមថ្នាក់រួមជំនាន់ទី១៣នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមឱ្យជួបប្រទះតែសេចក្តីសុខចម្រើន ប្រកបដោយភាពជោគជ័យគ្រប់ភារកិច្ច និងមានកម្លាំងកាយសម្បទាមាំមួនក្នុងការបន្តកិច្ចការងារដើម្បីជួយអភិវឌ្ឍន៍ប្រទេសជាតិរបស់យើងឱ្យមានកាន់តែរីកចម្រើនជានិរន្តរភាព។

# អារម្ភកថា

ចំពោះការសិក្សានៅថ្នាក់បរិញ្ញាបត្រ ឯកទេសរដ្ឋបាលសាធារណៈដែលមានរយៈពេលបួនឆ្នាំកន្លងមកនេះដែលមានលោក លោកស្រីសាស្ត្រាចារ្យមានបទបទពិសោធន៍ជាច្រើនឆ្នាំដែលជាអ្នកបម្រើការងាររដ្ឋនិងជាសាស្ត្រាចារ្យបង្រៀនជាមួយមុខវិជ្ជា ឯកទេសច្បាប់ និងរដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាច្រើនឆ្នាំ លោកសាស្ត្រាចារ្យបានចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍ផ្សេងៗ ចំពោះគំនិតកសាងរៀបចំអភិវឌ្ឍន៍សង្គមជាតិដែលទាក់ទងជាមួយនិងមុខវិជ្ជាកំពុងរៀន។

រដ្ឋបាលឃុំ សង្កាត់ត្រូវបានបង្កើតឡើង និងបានដំណើរការអស់រយៈពេលកាលជិត២០ឆ្នាំមកហើយ ដោយអនុវត្តទៅតាមគោលនយោបាយវិមជ្ឈការ ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាច្បាប់ស្នូលមួយធ្វើឱ្យឃុំ សង្កាត់អនុវត្តបាននូវការគ្រប់គ្រងប្រព័ន្ធរចនាសម្ព័ន្ធទៅតាមបែបវិមជ្ឈការយ៉ាងពិតប្រាកដ។ បើទោះបីជាយ៉ាងនេះក៏ដោយ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បែបវិមជ្ឈការនៅកម្ពុជាកាលពីឆ្នាំ២០០១ មកនេះហាក់ដូចជានៅមិនទាន់បានប្រសើរប៉ុន្មានទេ។ ដោយមើលឃើញពីលទ្ធផលកន្លងមកដែលឃុំ សង្កាត់បានសម្រេចនៅមិនទាន់អាចឆ្លើយតបទៅនឹងអ្វីដែលរាជរដ្ឋាភិបាលចង់បាន ក៏ដូចជាគោលបំណងក្នុងការពង្រឹងលទ្ធប្រជាធិបតេយ្យនៅមូលដ្ឋាន ហើយការអភិវឌ្ឍសេដ្ឋកិច្ចទៀតសោតនៅមិនទាន់បានល្អនៅឡើយទេ។ ទន្ទឹងនឹងនេះដោយយើងសង្កេតឃើញមានការបង្កើតឡើងនូវលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលដែលមានពាក់ព័ន្ធទៅនឹងគោលការណ៍ ការធ្វើកំណែទម្រង់ដើម្បីគាំទ្រប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការឱ្យមានប្រសិទ្ធភាព។ ចំណុចនេះអាចធ្វើការសន្និដ្ឋានបានថារដ្ឋបាលឃុំ សង្កាត់នៅមានការរាំងស្ទះពិតមែន។

អាស្រ័យដូចដែលបានរៀបរាប់ខាងលើនេះរួចមកហើយ យោងទៅលើកត្តាទាំងនេះហើយទើបបានធ្វើឱ្យយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ៖ **"ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការរបស់ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល(២០១៥-២០១៩)"** លើកយកមកសិក្សាស្រាវជ្រាវនិងធ្វើការសរសេរជាកិច្ចការសារណាបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ ព្រោះថាការសិក្សាទៅលើប្រធានបទមួយនេះគឺអាចឱ្យយើងមើលឃើញជាក់ស្តែងពីប្រសិទ្ធភាពនៃការអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់អាចនឹងអនុវត្តទៅដោយរលូនបានកម្រិតណា និងបានស្វែងយល់ពីការអនុវត្តតួនាទីនិងភារកិច្ចរបស់មន្ត្រីឃុំ សង្កាត់ ថាតើគោរពទៅតាមគោលការណ៍នៃបទដ្ឋានគតិយុត្តនានាដែរឬទេ? ម្យ៉ាងវិញទៀតយើងខ្ញុំទាំងពីរនាក់ក៏ចង់បង្ហាញមិត្តអ្នកអានបានដឹងកាន់តែច្បាស់អំពីកិច្ចការងារ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាបញ្ហាប្រឈមផ្សេងៗដែលឃុំបានជួបប្រទះ និងត្រូវដោះស្រាយជូនប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ។ ដូចនេះ យើងខ្ញុំសង្ឃឹមថា ការចងក្រងឯកសារសារណាមួយនេះអាចចូលរួមជួយជាប្រយោជន៍ដល់មិត្តអ្នក

អាននៅកាលៈទេសៈចាំបាច់ណាមួយ និងក្លាយជាទុនសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយៗអាចយកទៅពង្រឹងលើការសិក្សាស្វែងយល់ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនៃការសិក្សារបស់ពួកគេបាន ។

តាមរយៈការស្រាវជ្រាវមួយនេះ បើទោះបីជាយើងខ្ញុំបានខិតខំប្រឹងប្រែងស្រាវជ្រាវដោយយោងតាមឯកសារគោលនានា ជាពិសេសឯកសារដែលបានមកពីថ្នាក់មូលដ្ឋានឃុំ សង្កាត់ក៏ដូចជាឯកសារផ្សេងៗជាច្រើនទៀតក្តី ក៏កិច្ចការស្រាវជ្រាវនេះមិនអាចជៀសផុតអំពីចំនុចខ្វះខាត និងកំហុសខុសឆ្គងត្រង់ចំណុចណាមួយដោយអចេតនា និងកម្រិតនៃចំណេះដឹងរបស់យើងខ្ញុំជាក់ជាពុំខានឡើយ ទាំងផ្នែកខ្លឹមសារ អក្ខរាវិរុទ្ធ និងអត្ថបទ។ យើងខ្ញុំសូមអរគុណ និងរីករាយទទួលនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានគ្រប់រូបដើម្បីកែលម្អឡើងវិញឱ្យកាន់តែប្រសើរនៅពេលក្រោយៗទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ......... ១
**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ......... ១
**២. ចំណោទបញ្ហា** ......... ២
**៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ** ......... ២
**៤. គោលបំណងនៃការស្រាវជ្រាវ** ......... ២
**៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** ......... ៣
**៦. វិធីសាស្ត្រស្រាវជ្រាវ** ......... ៣
**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ......... ៣

## ជំពូកទី១

## ទស្សនទានទូទៅនៃវិមជ្ឈការ

**ផ្នែកទី១ ៖ រំលឹកទ្រឹស្តី** ......... ៥
១.១. និយមន័យនៃវិមជ្ឈការ ......... ៥
១.២.ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់ ......... ៧
១.៣. ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ តាមបែបវិមជ្ឈការ ......... ១០
១.៤ ចក្ខុវិស័យនៃប្រព័ន្ធវិមជ្ឈការ ......... ១១
១.៥. គោលបំណងនៃប្រព័ន្ធវិមជ្ឈការ ......... ១១
១.៦. ទិសដៅវិមជ្ឈការ ......... ១២
១.៧. ចរិតលក្ខណៈនៃប្រព័ន្ធវិមជ្ឈការ ......... ១៤
១.៨. លក្ខណៈវិនិច្ឆ័យនៃវិមជ្ឈការ ......... ១៥
**ផ្នែកទី២៖ គោលការណ៍គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ......... ១៦
២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ......... ១៦
២.២. តួនាទីភារកិច្ច និងមុខងារឃុំ សង្កាត់ ......... ១៨
២.៣. សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលឃុំ សង្កាត់ ......... ១៩
២.៤ ការត្រួតពិនិត្យលើរដ្ឋបាលឃុំ សង្កាត់ ......... ២០
២.៥. អាណត្តិរបស់ឃុំ សង្កាត់ ......... ២១

២.៦. កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់ ........................................................ ២១
២.៧. លិខិតបទដ្ឋានគតិយុត្តរបស់ឃុំ សង្កាត់ ........................................................ ២១
២.៨. លិខិតរដ្ឋបាលឃុំ សង្កាត់ ........................................................ ២១
២.៩. ការគ្រប់គ្រងបុគ្គលិករបស់ឃុំ សង្កាត់ ........................................................ ២១
២.១០. ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់ ........................................................ ២១
២.១១. ការគ្រប់គ្រងសម្ភារៈបរិក្ខាឃុំ សង្កាត់ ........................................................ ២២
២.១២. ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ........................................................ ២២
២.១៣. គណនេយ្យភាព ........................................................ ២៣

## ជំពូកទី២

## កិច្ចដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំពញាឮ

**ផ្នែកទី១៖ ស្ថានភាពភូមិសាស្ត្រ** ........................................................ ២៤
**ផ្នែកទី២៖ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលឃុំពញាឮ** ........................................................ ២៥
២.១. រចនាសម្ព័ន្ធឃុំ សង្កាត់ ........................................................ ២៥
២.២. សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ ........................................................ ២៧
**ផ្នែកទី៣៖ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំពញាឮ** ........................................................ ២៧
៣.១. ការរៀបចំ និងអនុម័តថវិកាឃុំ ........................................................ ២៨
៣.២. ការគ្រប់គ្រងលើការចំណាយ ........................................................ ២៩
**ផ្នែកទី៤៖ ប្រព័ន្ធទូទាត់ គណនេយ្យ និងកិច្ចលទ្ធកម្មសម្រាប់ឃុំ** ........................................................ ៣០
៤.១. គោលការណ៍ទូទៅ ........................................................ ៣០
៤.២. ប្រព័ន្ធទូទាត់ ........................................................ ៣០
៤.៣. ប្រព័ន្ធគណនេយ្យ ........................................................ ៣១
៤.៤. កិច្ចលទ្ធកម្មឃុំ សង្កាត់ ........................................................ ៣១
**ផ្នែកទី៥៖ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (សម្រាប់ឆ្នាំ២០១៨-២០២២)** ........................................................ ៣១
៥.១. ចក្ខុវិស័យអភិវឌ្ឍន៍ ........................................................ ៣១
៥.២. គោលបំណងអភិវឌ្ឍន៍ ........................................................ ៣២
៥.៣. គោលដៅអភិវឌ្ឍន៍ ........................................................ ៣២

**ផ្នែកទី៦៖ ការអនុវត្តកម្មវិធីអភិវឌ្ឍន៍ប្រាំឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់របស់ឃុំពញាឮ**..........៣៤
៦.១. ក្របខ័ណ្ឌវិនិយោគ..........៣៥
៦.២. ក្របខ័ណ្ឌផ្តល់សេវា..........៣៥
៦.៣. ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត..........៣៦

## ជំពូកទី៣

## ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

**ផ្នែកទី១៖ ការសិក្សាលើស្ថានភាពបច្ចុប្បន្នរបស់ឃុំពញាឮ**..........៣៧
១.១. ស្ថានភាពសេដ្ឋកិច្ច ឆ្នាំ ២០២០នេះ..........៣៧
១.២. ស្ថានភាពសង្គមកិច្ច..........៣៩
១.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន..........៤១
១.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ..........៤២
១.៥. ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ..........៤២
**ផ្នែកទី២៖ ចំណុចខ្លាំង និង ចំណុចខ្សោយ**..........៤៣
កថាខណ្ឌទី១ ចំណុចខ្លាំង..........៤៣
កថាខណ្ឌទី២ ចំណុចខ្សោយ..........៤៤
**សេចក្តីសន្និដ្ឋាន**..........៤៦
**អនុសាសន៍**..........៤៨
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តតាមលទ្ធប្រជាធិបតេយ្យសេរីពហុបក្សដែលតំណាងរាស្ត្រត្រូវបានបោះឆ្នោតចេញពីប្រជាពលរដ្ឋ។ ការគ្រប់គ្រងរដ្ឋបាលត្រូវបានបែងចែកដាច់ពីគ្នា គឺមានខេត្តនិងក្រុងដែលក្នុងនោះខេត្តចែកជាស្រុក ហើយស្រុកចែកជាឃុំ ឯក្រុងត្រូវចែកជាខណ្ឌ ហើយខណ្ឌត្រូវបានចែកជាសង្កាត់។ ថ្វីបើមានកំណត់យ៉ាងច្បាស់លាស់ពីការបង្កើតនូវរដ្ឋបាលចំណុះខេត្ត និងក្រុងរហូតដល់ថ្នាក់មូលដ្ឋានឃុំ សង្កាត់ តែគេមិនទាន់ឃើញមានលេចឡើងជាទម្រង់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិដូចជាស្រុក ខណ្ឌ និងឃុំ សង្កាត់នៅឡើយទេ។ ក្រោយពីការបោះឆ្នោតឆ្នាំ១៩៩៨បានបញ្ចប់ រដ្ឋាភិបាលអាណត្តិទី២មានគម្រោងរៀបចំកែប្រែការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានពីប្រព័ន្ធបែបមជ្ឈការទៅតាមបែបវិមជ្ឈការវិញ។ យ៉ាងណាមិញ ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការនេះគឺជារបៀបរៀបចំរដ្ឋបាលមួយដែលអនុញ្ញាតឱ្យមានរចនាសម្ព័ន្ធនានាផ្សេងពីរចនាសម្ព័ន្ធរបស់រដ្ឋ ដើម្បីឱ្យមានលទ្ធភាពគ្រប់គ្រងភារកិច្ចរដ្ឋបាលទាំងឡាយនៅមូលដ្ឋាន។

រាជរដ្ឋាភិបាលបានប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធអំណាច ព្រមទាំងធនធានដើម្បីធ្វើយ៉ាងណាឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន។ ដើម្បីរៀបចំការគ្រប់គ្រងថ្នាក់មូលដ្ឋានតាមបែបវិមជ្ឈការនេះ រាជរដ្ឋាភិបាលបានធ្វើនូវគម្រោងបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់។ គួររំលឹកផងដែរថានៅក្នុងអាណត្តិទី១រាជរដ្ឋាភិបាលក៏មានគម្រោងបោះឆ្នោតមេឃុំ ចៅ-សង្កាត់ ដែលនឹងត្រូវបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៧ដែរ តែដោយសារព្រឹត្តិការណ៍ប្រឈមមុខដាក់គ្នាដោយកម្លាំងអាវុធមួយនៅរាជធានីភ្នំពេញ កាលពីថ្ងៃ០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ ដែលធ្វើឱ្យគម្រោងនៃការបោះឆ្នោតនេះត្រូវអាក់ខាន និងត្រូវបានពន្យាពេល។ រហូតមកដល់អាណត្តិទី២ ស្របតាមយុទ្ធសាស្ត្រនយោបាយឈ្នះៗរបស់រាជរដ្ឋាភិបាលបានសម្រេចនូវគោលដៅ ដោយជោគជ័យល្អប្រសើរនៅក្នុងការកែប្រែនូវទម្រង់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៩ មីនា ឆ្នាំ២០០១។ ទន្ទឹងនឹងនេះ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាមួយនិងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ផងដែរ។

ពេលបច្ចុប្បន្ននេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដំណើរការបាន៥អាណត្តិមកហើយ។ ដោយការបោះឆ្នោតលើកទី១ធ្វើឡើងកាលពីខែកុម្ភៈ ឆ្នាំ២០០២ លើកទី២ កាលពីខែមេសា ឆ្នាំ២០០៧ លើកទី៣កាលពីខែមិថុនា ឆ្នាំ២០១២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ និងសង្កាត់អាណត្តិទី៤ កាលពីខែមិថុនា ឆ្នាំ២០១៧កន្លងទៅ។ ជាក់ស្តែងការធ្វើកំណែទម្រង់វិមជ្ឈការថ្នាក់រដ្ឋបាលឃុំ សង្កាត់ រាជរដ្ឋាភិបាលខិតខំបានព្យាយាមកែលម្អ ដោយបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹង

បញ្ហាដែលកើតមានឡើងក្នុងពេលកំពុងអនុវត្ត។ ដូចនេះបើទោះបីជាយ៉ាងណាក៏អាចធ្វើឱ្យប្រសើរជាងការមិនបានធ្វើអ្វីទាំងអស់ នោះដែរ។

## ២. ចំណោទបញ្ហា

ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីអំពី **ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការរបស់ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល** នេះបានចោទឡើងជាបញ្ហាមួយចំនួនដូចខាងក្រោម៖

- តើក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ? តើឃុំពញាឮបានអនុវត្តន៍នូវតួនាទី និងភារកិច្ចរបស់ខ្លួនបានកម្រិតណា?
- ស្របតាមទិសដៅនៃកំណែទម្រង់របស់រាជរដ្ឋាភិបាលដែលអនុវត្តតាមបែបប្រព័ន្ធវិមជ្ឈការ តើឃុំបានសម្រេចនូវសមិទ្ធផលអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងអ្វីដែលរាជរដ្ឋាភិបាលចង់បាន?
- តើគោលការណ៍នៃអនុវត្តលើការគ្រប់គ្រងរដ្ឋបាលរបស់ឃុំពញាឮ ទទួលបានប្រសិទ្ធភាពដល់កម្រិតណាដោយយោងតាមទិសដៅវិមជ្ឈការ?
- តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំពញាឮ បានជួបទៅនឹងបញ្ហាប្រឈមអ្វីខ្លះ? ហើយតើក្រុមប្រឹក្សា ឃុំពញាឮបានលើកនូវដំណោះស្រាយបែបណានៅក្នុងការដោះស្រាយនូវរាល់បញ្ហាទាំងនោះ?

## ៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ផ្អែកទៅលើការស្រាវជ្រាវមួយនេះ គឺពួកយើងបានផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលមានដែនកំណត់ និងវិសាលភាពគ្រប់ដណ្តប់តែទៅលើសកម្មភាពនៃការអនុវត្តការងាររដ្ឋបាលឃុំពញាឮនៅក្នុងចន្លោះឆ្នាំ២០១៥ ដល់ ២០១៩។ ហេតុដូច្នេះហើយប្រធានបទរបស់យើងខ្ញុំ សូមបកស្រាយតែទៅលើចំណុចមួយចំនួនទាក់ទងជាមួយនឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ ដែលរួមមានការផ្លាស់ប្តូរការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋានជាប្រព័ន្ធវិមជ្ឈការ កិច្ចដំណើរការនៃគ្រប់គ្រងរដ្ឋបាល និងស័ក្តសិទ្ធភាពនៃការគ្រប់គ្រងឃុំ ដែលសម្រេចបានជាសមិទ្ធផលរួមទាំងបញ្ហាប្រឈម ដែលត្រូវកែលម្អរបស់ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល។

## ៤. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺមានគោលបំណងស្វែងយល់ឱ្យបានយ៉ាងច្បាស់ពីប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់ឃុំតាមការអនុវត្តគោលនយោបាយវិមជ្ឈការ ដែលស្របទៅតាមទិសដៅរបស់រាជរដ្ឋាភិបាល និងដើម្បីបង្ហាញពីតថភាពជាក់ស្តែងនៃការផ្តល់សេវារបស់ក្រុមប្រឹក្សាឃុំជូនប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះ គឺដើម្បីរួមចំណែកនៅក្នុងការលែលម្អនូវចំណុចខ្វះខាត ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលរបស់ឃុំ សង្កាត់ និងសិក្សាស្វែងយល់ពី៖ វិមជ្ឈការឃុំ សង្កាត់សំដៅរួមចំណែកកាត់

បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដែលជាគោលដៅចំបងរបស់រាជរដ្ឋាភិបាលនៅក្នុងការលើកកម្ពស់ និងផ្ដល់សេវាសាធារណៈចាំបាច់ដល់មូលដ្ឋានតាមតម្រូវការជាក់ស្ដែង។ ពង្រឹងលទ្ធប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ធានាលើការអភិវឌ្ឍប្រកបដោយចីរភាព រួមមានការផ្ដល់សេវាជាមូលដ្ឋានផងដែរ។ សមត្ថភាពរបស់មន្ត្រីរាជការនៅក្នុងការអនុវត្តកិច្ចការមូលដ្ឋានឃុំ-សង្កាត់ ស័ក្តសិទ្ធភាពនៃការអនុវត្តកិច្ចការងាររបស់ក្រុមប្រឹក្សាឃុំពញាឮបង្ហាញពីសិទ្ធិ និងសកម្មភាពរបស់ប្រជាពលរដ្ឋក្នុងការចូលរួមនៅក្នុងមូលដ្ឋាន។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺវាពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះការសិក្សាស្រាវជ្រាវនេះ គឺចង់ស្វែងយល់ពីការអនុវត្តគោលការណ៍នៃការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ឃុំពញាឮ ក៏ដូចជាសិក្សាពីតម្រូវការ និងផលវិបាកផ្សេងៗនៅមូលដ្ឋានដែលឃុំត្រូវដោះស្រាយនិងឆ្លើយតបទៅនឹងទិសដៅរបស់រាជរដ្ឋាភិបាលពង្រឹងលទ្ធិប្រជាធិបតេយ្យ និងធ្វើយ៉ាងណាឱ្យការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនេះស្របតាមគោលនយោបាយវិមជ្ឈការទទួលបានស័ក្តសិទ្ធភាព។ ការសិក្សានេះក៏មានលម្អិតពីបញ្ហាខ្វះខាតមួយចំនួនដែលឃុំពញាឮនៅភាពភាពអសកម្មនៅឡើយ ដែលធ្វើឱ្យរះស្ទះក្នុងដំណើរការការងារ។ ដូច្នេះហើយ យើងខ្ញុំចង់ស្វែងយល់ពីការអនុវត្តកិច្ចការនៅមូលដ្ឋាន ជាពិសេសនៅ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ដើម្បីសិក្សាស្វែងយល់ពីដំណើរការនៃការអនុវត្តគោលនយោបាយវិមជ្ឈការពីឃុំពញាឮនេះ ថាតើនៅមានបញ្ហាប្រឈមដែលកើតឡើងអ្វីខ្លះដើម្បី និងត្រូវមានចំណុចដែលត្រូវកែលម្អបន្ថែមទៀត។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធាន គឺផ្អែកលើការកំណត់ដោយច្បាប់ អនុក្រឹត្យ ប្រកាស បទដ្ឋានគតិយុត្តផ្សេងៗ និងសៀវភៅមេរៀន ដែលពាក់ព័ន្ធនិងប្រធានបទជុំវិញបរិបទឆ្នាំ (២០១៥-២០១៩)។ ចំពោះការស្វែងរកឯកសារគឺ តាមរយៈឯកសារដែលបានធ្វើការស្រាវជ្រាវនូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រធានបទតាមរយៈបណ្ណាល័យ ស្ថាប័ននានា ទស្សនាវដ្ដីបណ្ដាឯកសារពាក់ព័ន្ធដល់ការសិក្សាស្រាវជ្រាវធ្វើការប្រមូលដកស្រង់យកឯកសារដែលពាក់ព័ន្ធទាំងនោះធ្វើជាទុន និងជាទិន្នន័យ។ ទិន្នន័យមួយចំនួនទៀត គឺធ្វើឡើងតាមរយៈការចុះផ្ទាល់នៅឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ដើម្បីធ្វើការសម្ភាសជាមួយ**លោក យូ ផាត់** ដែលជាមេឃុំពញាឮ និងលោក **ម៉ៅ គីមសៀន** ជាស្មៀនឃុំពញាឮ ព្រមជាមួយនិងទទួលបានឯកសារមួយចំនួនពីលោកមេឃុំ និងស្មៀនឃុំ និងស្វែងរកឯកសារលើប្រព័ន្ធអ៊ីនធឺណេតជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវមួយនេះ ដំណើរការទៅបានល្អប្រសើរ និងប្រកបដោយភាពជោគជ័យ សារ

ណានេះត្រូវបានបែងចែកដូចតទៅ៖

- សេចក្តីថ្លែងអំណរគុណ
- អារម្ភកថា
- សេចក្តីផ្តើម
- ជំពូកទី១ ទស្សនៈទានទូទៅនៃវិមជ្ឈការ
- ជំពូកទី២ កិច្ចដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំពញាឮ
- ជំពូកទី៣ ស័ក្តសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំពញាឮ
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- គន្ថនិទេស
- ឧបសម្ព័ន្ធ។

# ជំពូកទី១

# ទស្សនទានទូទៅនៃវិមជ្ឈការ

## ផ្នែកទី១ ៖ រំលឹកទ្រឹស្តី

### ១.១. និយមន័យនៃវិមជ្ឈការ

នៅក្នុងក្របខ័ណ្ឌទូទៅ វិមជ្ឈការត្រូវបានគេឱ្យនិយមន័យថា ជាដំណើរការមួយដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្តាលទៅឱ្យរដ្ឋាភិបាលមូលដ្ឋាន។ វិមជ្ឈការមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងគោលគំនិតស្តីពី "Subsidiarity" ដែលគោលគំនិតនេះបានកំណត់ថារាល់មុខងារត្រូវផ្ទេរទៅឱ្យថ្នាក់ទាបបំផុតណាដែលមានសមត្ថភាពអាចបំពេញមុខងារនោះបាន។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP)បានឱ្យនិយមន័យនៃ "អភិបាលកិច្ចតាមបែបវិមជ្ឈការ" ថា ជាការរៀបចំឡើងវិញនូវសមត្ថកិច្ច ដើម្បីឱ្យមានប្រព័ន្ធមួយដែលមានការសហការទទួលខុសត្រូវរវាងស្ថាប័នអភិបាលកិច្ចនៅថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានដោយផ្អែកទៅលើគោលការណ៍នៃSubsidiarity ដែលកត្តានេះនឹងនាំមកនូវការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចដើរទន្ទឹមនឹងការកើនឡើងនូវសិទ្ធិអំណាច និងលទ្ធភាពនៅថ្នាក់ក្រោមជាតិ។[1]

វិមជ្ឈការ គឺជាការផ្ទេរនូវអំណាច មុខងារ ការទទួលខុសត្រូវ និងធនធានមួយចំនួនពីរដ្ឋបាលកណ្តាលទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកើតឡើងដោយការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ដែលក្រុមប្រឹក្សានេះត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ វិមជ្ឈការ គឺជាការផ្តល់នូវអំណាចនិងឆន្ទានុសិទ្ធិពេញលេញដល់ក្រុមប្រឹក្សាជាប់ឆ្នោត ដើម្បីធ្វើសេចក្តីសម្រេចចិត្តឆ្លុះបញ្ចាំងពីសេចក្តីត្រូវការ ផលប្រយោជន៍ និងតថភាពនៅមូលដ្ឋាន។[2]

វិមជ្ឈការ គឺជាកិច្ចការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សា នូវភាពជាម្ចាស់លើមុខងារសិទ្ធិអំណាចនិងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការមូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។ ក្នុងន័យនេះរាល់កិច្ចការនានាដែលបានផ្ញើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សា ក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញនៅក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅមូលដ្ឋានរបស់ខ្លួន។[3] ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។

---

[1] ក្រសួងមហាផ្ទៃ"វិមជ្ឈការ និងវិសហមជ្ឈការ"ឆ្នាំទី២ លេខ២ ឆ្នាំ២០១៧

[2] បទបង្ហាញដោយឯកឧត្តម "ព្រំ សុខា" រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ថ្ងៃទី២៨ មេសា ២០០៨

[3] សម្តេចក្រឡាហោម ស ខេង, បទបាឋកថា ស្តីពីកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ,២០១៧

វិមជ្ឈការ គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ ។ ក្នុងន័យនេះរាល់កិច្ចការនានាដែលបានធ្វើវិមជ្ឈការទៅឱ្យក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផលដែរ។[4]

តាមន័យបច្ចេកទេសគតិយុត្ត វិមជ្ឈការ គឺជាការបង្កើតនីតិបុគ្គលដាច់ចេញពីរដ្ឋ ដែលមានសមត្ថកិច្ចផ្ទាល់ ពោលគឺនីតិបុគ្គលនេះប្រតិបត្តិសមត្ថកិច្ចខ្លួនដោយរបៀបស្វយ័ត។ បច្ចេកទេសនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការមានលក្ខណៈពិសេសបីគឺៈ

- បុគ្គលភាពគតិយុត្ត
- សមត្ថកិច្ចផ្ទាល់
- ការទទួលបានស្វ័យភាពកំណត់។

រដ្ឋបាលវិមជ្ឈការមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ ពោលគឺមានអង្គការនេះជាប្រធាននៃនីតិផ្សេងពីរដ្ឋ។ បន្ថែមពីនេះ រដ្ឋបាលវិមជ្ឈការទទួលបានសមត្ថកិច្ចកំណត់ដោយច្បាប់ពោល គឺមានឯកភាពពីរដ្ឋ ដូច្នេះក្រោយពេលកំណត់សមត្ថកិច្ចឱ្យទៅរដ្ឋបាលវិមជ្ឈការរដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានទេ។ ជាចុងក្រោយរដ្ឋបាលវិមជ្ឈការទទួលបាននូវស្វ័យភាពដែលធ្វើឱ្យខ្លួនមិនស្ថិតក្រោមអំណាចឋានានុក្រម។ ប៉ុន្តែជាតថភាពស្វ័យភាពនេះមិនឯករាជ្យទេ ដោយសាររដ្ឋបាលកណ្ដាលនៅតែមានសិទ្ធិអំណាចត្រួតពិនិត្យក្នុងនាមជាអាណាព្យាបាល ឬតាមរយៈស្ថាប័នតុលាការ។

ជាការពិតប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនេះ គឺមានខ្លឹមសារជាការអនុវត្តលទ្ធិប្រជាធិបតេយ្យ ជម្រុញឱ្យមានអភិបាលកិច្ចល្អ និងលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យល្អ ដោយសាររដ្ឋអំណាចបានធ្វើ និងតម្រូវការរបស់ប្រជារាស្ត្រជាហេតុធ្វើឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងកែលម្អយុទ្ធសាស្ត្រដឹកនាំឱ្យការងារផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ។ នៅក្នុងកាលានុវត្តភាពនេះរដ្ឋអាចស្គាល់ និងជ្រួតជ្រាបពីការលំបាក ទុក្ខធុរៈ កាន់តែមានប្រសិទ្ធភាព។

ដូច្នេះ រដ្ឋត្រូវតែប្រគល់អំណាចមួយចំនួនទៅឱ្យឃុំ សង្កាត់សម្រាប់សម្រេចកិច្ចការមូលដ្ឋានខ្លួនឯងផ្ទាល់ដោយមិនចាំបាច់សុំការអនុញ្ញាតពីអាជ្ញាធរថ្នាក់កណ្ដាលឡើយ គឺដោយគ្រាន់តែមានការត្រួតពិនិត្យ តាមនីត្យានុកូលភាពលើសេចក្ដីសម្រេចរបស់រដ្ឋតែប៉ុណ្ណោះ។ តាមរយៈនេះឃុំ សង្កាត់ទទួលបាននូវអំណាច និងការទទួលខុសត្រូវមួយចំនួនដែលប្រគល់ឱ្យដោយច្បាប់។

[4] បាឋកថា ស្ដីពី កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ, ឧទ្ទេសនាមដោយសម្ដេចក្រឡាហោម ស ខេង, ក្រសួងមហាផ្ទៃ ឆ្នាំ ២០១៧

## ១.២.ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់

ក្រោយពីការបោះឆ្នោត ឆ្នាំ១៩៩៨ បានបញ្ចប់ រដ្ឋាភិបាលនាអាណត្តិទី២នេះ មានគម្រោងរៀបចំកែប្រែការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន ពីបែបមជ្ឈការ ទៅតាមបែបវិមជ្ឈការវិញ។ ការគ្រប់គ្រងតាមបែប វិមជ្ឈការ គឺជាការគ្រប់គ្រងមួយ ដែលអំណាចថ្នាក់កណ្តាល ត្រូវបានផ្ទេរយ៉ាងពេញលេញទៅឱ្យថ្នាក់មូលដ្ឋាន ដើម្បីមានស្វ័យភាព ក្នុងការអភិវឌ្ឍន៍មូលដ្ឋានទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋខ្លួន។ ដើម្បីរៀបចំការគ្រប់គ្រងថ្នាក់មូលដ្ឋានតាមបែបវិមជ្ឈការនេះ រដ្ឋាភិបាលបានរៀបចំគម្រោងបោះឆ្នោត នៅថ្នាក់ឃុំសង្កាត់។[5]

គួររំលឹកផងដែរថា នៅក្នុងអាណត្តិទី១ រាជរដ្ឋាភិបាលក៏មានគម្រោងរៀបចំការបោះឆ្នោតមេឃុំ ចៅសង្កាត់នៅក្នុងអំឡុងឆ្នាំ១៩៩៧ដែរ។ ដោយសារព្រឹត្តិការណ៍ប្រឈមមុខដាក់គ្នាដោយកំលាំងអាវុធមួយនៅរាជធានីភ្នំពេញកាលពីថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ គម្រោងនៃការបោះឆ្នោតនោះក៏ត្រូវអាក់ខាន និងត្រូវបានពន្យារពេលរហូតមកដល់ឆ្នាំ១៩៩៨។ ក្នុងអាណត្តិទី២នេះ រដ្ឋាភិបាលមានគម្រោងនឹងរៀបចំការបោះឆ្នោតថ្នាក់មូលដ្ឋានឃុំ សង្កាត់តែមិនមែនបោះរើសមេឃុំ ឬចៅសង្កាត់ទេ គឺបោះជ្រើសរើសជាក្រុមប្រឹក្សាឃុំ សង្កាត់ តែម្តង។ គម្រោងនេះជាដំបូង គេរំលឹកថានឹងអាចដំណើរការបាននៅអំឡុងពេលចុងឆ្នាំ១៩៩៩ ក៏ប៉ុន្តែរហូតមកដល់ពេលនេះច្បាប់ពីរដែលជាច្បាប់សម្រាប់រៀបចំដំណើរការការបោះឆ្នោត និងរៀបចំគ្រប់គ្រងរដ្ឋបាលមិនទាន់បានអនុម័តពីអង្គការនីតិបញ្ញត្តិនៅឡើយផង។[6]

តាមរយៈឯកសារ របស់លោកបណ្ឌិតប៉ាទ្រិច រ៉ូម "PATRICK ROOME" អ្នកជំនាញការច្បាប់ UNDP ប្រចាំប្រទេសកម្ពុជាបានបញ្ជាក់អំពីប្រវត្តិនៃការបង្កើត និងគ្រប់គ្រងឃុំ សង្កាត់នៅក្នុងប្រទេសកម្ពុជាយើងតាំងតែពីសម័យអាណានិគមបារាំង ដែលនៅឆ្នាំ១៨៦៣ ជាពេលដែលពួកបារាំងបានដាក់នឹមអាណានិគមមកលើប្រទេសកម្ពុជា។ ក្នុងកំឡុងពេលនោះរហូតមកដល់១៩០៨ ឃុំ សង្កាត់ មិនទាន់មានជាទូទៅទេ។ នៅក្នុងប្រទេសកម្ពុជាវាខុសគ្នាពីកន្លែងដ៏ទៃទៀតនៅក្នុងតំបន់ដែលជាទីកន្លែងប្រព័ន្ធឃុំមានពីមុន ហើយការមកដល់នៃអាណានិគមបារាំងក្នុងសតវត្សទី១៩។ នៅពេលនោះប្រហែលជាមានតែនៅក្នុងតំបន់កាន់កាប់ខ្លះដូចជា "ខេត្ត" ត្រូវបានដឹកនាំដោយចៅហ្វាយខេត្ត ឬមនុស្សដែលមានថ្នាក់ខ្ពង់ខ្ពស់ហើយត្រូវបានតែងតាំងដោយមហាក្សត្រ។ ខេត្តនីមួយៗត្រូវបានចែកចេញជា"ស្រុក" ហើយត្រូវដឹកនាំដោយចៅហ្វាយស្រុក។ នៅឆ្នាំ១៩០៨ ដល់ឆ្នាំ១៩១៩ យោងតាមព្រះរាជក្រឹត្យចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩០៨ បានគូសបញ្ជាក់អំពីការចាប់ផ្តើមបង្កើតឃុំ។ ព្រះរាជ

[5] ឯកសារដើមៈសរសេរដោយ ខុំម្រែហ្វល ដកស្រង់ចេញពី "ព្រឹត្តិបត្រអ្នកឃ្លាំមើល ច្បាប់ចេញផ្សាយ ឆ្នាំទី០៣ លេខ១១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០០"។

[6] ឯកសារដើមៈសរសេរដោយ ខុំម្រែហ្វល ដកស្រង់ចេញពី "ព្រឹត្តិបត្រអ្នកឃ្លាំមើល ច្បាប់ចេញផ្សាយ ឆ្នាំទី០៣ លេខ១១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០០"។

ក្រឹត្យនេះក៏បានចែងអំពីក្របខ័ណ្ឌការងាររដ្ឋបាលដ៏សាមញ្ញមួយផងដែរ។ ភូមិជាច្រើនបានបញ្ចូលគ្នាបង្កើតបានជាឃុំ។ ពិសេសជាងនេះទៅទៀតព្រះរាជក្រឹត្យនេះ បានបែងចែកការបោះឆ្នោតជ្រើសរើសមេឃុំ ឬប្រធានឃុំដោយប្រជាជន ឬជនដែលរស់នៅក្នុងឃុំ។ រីឯភូមិត្រូវបានដឹកនាំដោយ"មេភូមិ" ប៉ុន្តែមិនត្រូវបានប្រគល់ឱ្យនូវឋានៈពិសេសដូចជាអង្គភាពរដ្ឋបាលមួយឡើយ។

ឆ្នាំ១៩១៩-១៩៤៣ រដ្ឋបាលមូលដ្ឋានឃុំ ពីឆ្នាំ១៩១៩ ដល់ឆ្នាំ១៩៤៣ គឺត្រូវបានបង្កើតឡើងដោយព្រះរាជក្រម។ គោលបំណងសំខាន់ គឺដើម្បីញែកចេញនូវការស្រុតចុះ នៃរដ្ឋបាលរបស់ប្រទេសហើយនាំយករដ្ឋបាលមូលដ្ឋានឱ្យបានកាន់តែជិតស្និទ្ធទៅនឹងប្រជាពលរដ្ឋ និងដើម្បីផ្តល់សេរីភាពដល់រដ្ឋអំណាចដ៏ទៃទៀតអាចបំពេញកាតព្វកិច្ចរបស់ខ្លួន។ ចាប់ពីខែមករា ឆ្នាំ១៩២៦ រហូតដល់ឆ្នាំ១៩៤៣ ឃុំបានដើរតួនាទីនៅក្នុងអត្ថន័យច្បាប់ ដូចទៅនឹងតួនាទីឃុំ កាលពីជំនាន់បារាំងដែរ។[7]

ព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩១៩ បានផ្តល់ដល់ឃុំនូវគំរោង និងថវិកាខ្លួនផ្ទាល់ព្រមទាំងផ្តល់អំណាចជាច្រើនដល់មេឃុំ ធ្វើសកម្មភាពផ្សេងៗដើម្បីអភិវឌ្ឍន៍ឃុំ។ ប៉ុន្តែរដ្ឋអំណាចថ្នាក់កណ្តាល(មជ្ឈិម) ក៏បានធ្វើការចាត់តាំងផងដែរ។ ព្រះរាជក្រមនេះ(១៩១៩) ត្រូវបានរៀបចំតាមលំនាំនៃព្រះរាជក្រមចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩២៥ បានចែងយ៉ាងច្បាស់លាស់អំពីអង្គភាពរដ្ឋបាលយុត្តិធម៌ និងហិរញ្ញវត្ថុរបស់ឃុំ។ នៅក្នុងឆ្នាំ១៩២៥នេះដែរ គេបានរៀបចំឱ្យមានការបោះឆ្នោតនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ទៅតាមប្រព័ន្ធវិមជ្ឈការដែលជារបៀបគ្រប់គ្រងមួយមានលក្ខណៈខិតចូលជិតកៀកប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គការពិគ្រោះយោបល់ ឬពិភាក្សា ឬធ្វើសេចក្តីសម្រេចហើយ មេឃុំ ជាអ្នកទទួលខុសត្រូវអនុវត្តសេចក្តីសំរេចក្រុមប្រឹក្សាឃុំរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំមានរយៈពេលប្រជុំ៤ដងក្នុងមួយឆ្នាំ និងសំរេចរាល់ការងាររបស់ឃុំ។ មេឃុំត្រូវបានជ្រើសរើសចេញពីសមាជិកក្រុមប្រឹក្សាឃុំនេះតែម្តង។ មេឃុំមិនគ្រាន់តែជាប្រធាននៃក្រុមប្រឹក្សាឃុំប៉ុណ្ណោះទេ ប៉ុន្តែក៏ជាអ្នកដឹកនាំនិងជាភ្នាក់ងារសំខាន់មួយនៃរដ្ឋាភិបាល ដែលជាការងារខាងក្រៅក្រុមប្រឹក្សារបស់គេ។ ច្បាប់ក៏បានអនុញ្ញាតឱ្យអនុប្រធាន ឬជំទប់ ជ្រើសចេញពីក្រុមប្រឹក្សាឃុំដើម្បីជួយដល់ឃុំ និងបានអធិប្បាយអំពីឋានៈ នៃការទទួលខុសត្រូវរបស់ពួកគេផងដែរ។ ប៉ុន្តែប្រព័ន្ធគ្រប់គ្រងនៃក្រុមប្រឹក្សាឃុំនេះ ត្រូវបានលុបបំបាត់ទៅវិញនៅឆ្នាំ១៩៤៣ ហើយឃុំ សង្កាត់ ត្រូវបានរៀបចំឡើងវិញដោយមេឃុំ និងជំទប់ ត្រូវបានចាត់តាំងពីចៅហ្វាយខេត្ត និងត្រូវមានការយល់ព្រមពីពួកបារាំងដែលនៅប្រចាំតំបន់។ ការផ្លាស់ប្តូរនេះ គឺនៅក្នុងបរិយាកាសសង្គ្រាមនិងអសន្តិសុខ។[8] ឆ្នាំ១៩៥៩ ដល់ឆ្នាំ១៩៧០ នៅក្នុងអារម្ភកថានៃព្រះរាជ

[7] ឯកសារដើមៈសរសេរដោយ ខុំម្រែហ្វល ដកស្រង់ចេញពី "ព្រឹត្តិបត្រអ្នកឃ្លាំមើល ច្បាប់ចេញផ្សាយ ឆ្នាំទី០៣ លេខ១១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០០"។

[8] ដដែល

ក្រមលេខ៣៤០ន.ស ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៥៩ បានចែងថា គេបានបង្កើតការវិលត្រឡប់ស្ទើរទាំងស្រុងទៅកាន់របបសង្គមមួយ ដែលគេបានក៏សាងឡើងនៅក្នុងឆ្នាំ១៩២៥ បានន័យថា គេបានរៀបចំបោះឆ្នោតឃុំសង្កាត់ម្តងទៀត តែសម័យនោះគេហៅថា ក្រុមជំនុំឃុំ ដែលមានតួនាទី ភារកិច្ចដូចក្រុមប្រឹក្សាឃុំឆ្នាំ១៩២៥ដែរ។ ក្រុមជំនុំឃុំ គឺជាអ្នកធ្វើការពិភាក្សាចេញបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចរបស់ក្រុមជំនុំ។ ប៉ុន្តែការអនុវត្តជាក់ស្តែងនូវប្រព័ន្ធគ្រប់គ្រងនេះបានតែក្នុងរយៈពេលប្រមាណពី៥ទៅ៦ខែប៉ុណ្ណោះ ក៏ត្រូវរំសាយទៅវិញដោយសារតែមិនអាចដំណើរការទៅបាន។ ពេលនេះមេឃុំ និងជំទប់ត្រូវបន្តធ្វើការតែងតាំងពីចៅហ្វាយខេត្តដដែលរីញរហូតមកដល់ឆ្នាំ១៩៧០ ជាពេលដែលប្រទេសកម្ពុជាធ្លាក់ទៅក្នុងភ្លើងសង្គ្រាមស៊ីវិលដ៏ធ្ងន់ធ្ងរ ហើយទីបំផុតក៏បានធ្លាក់ចុះទៅក្នុងកណ្តាប់ដៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ក្នុងរបបអាវខ្មៅនេះ របៀបនៃការគ្រប់គ្រងរដ្ឋបាល ក៏ស្ថិតនៅតាមរបៀបនៃការចាត់ចែងដដែលគឺគេពុំមានធ្វើការបោះឆ្នោតជ្រើសរើសអ្វីឡើយ។ រីឯសិទ្ធិអំណាចរបស់មេឃុំ អាចជាតុលាការផង ជាកងទ័ពផង ឬក៏ជាអ្នកដឹកនាំត្រួតពិនិត្យលើប្រជាជាក្នុងមូលដ្ឋានរបស់ខ្លួន។

ក្រោយពីរបបខ្មែរបានកាន់កាប់ត្រូវបានផ្តួលរំលំ ដោយកងទ័ព វៀតណាមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយពួកគេបានបង្កើតនូវរដ្ឋាភិបាលបណ្តោះអាសន្នមួយដឹកនាំប្រទេស។ ក្រោយមករបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមួយត្រូវបានបង្កើតឡើង ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១។ ក្នុងរដ្ឋធម្មនុញ្ញនៃរបបនេះបានកំណត់អំពីអង្គការគ្រប់គ្រងខេត្ត-ក្រុង ស្រុក ឃុំ។ នៅឆ្នាំ១៩៨១នេះដដែល គេបានដំណើរការរៀបចំបោះឆ្នោតថ្នាក់មូលដ្ឋាន ភូមិ ឃុំ សង្កាត់មួយ ប៉ុន្តែពេលនោះគេហៅថា ការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការឃុំ សង្កាត់ ដើម្បីដឹកនាំឃុំ សង្កាត់។ ប៉ុន្តែចាប់ពីឆ្នាំ១៩៨១ រហូតមកដល់ពេលបច្ចុប្បន្ន ការបោះឆ្នោតថ្នាក់មូលដ្ឋានឃុំ សង្កាត់ ចៅសង្កាត់ ឬជំទប់ដែលកើតចេញពីការបោះឆ្នោតត្រូវជំនួសដោយការតែងតាំងទាំងអស់។ ដូច្នេះបើទោះជាកន្លងមកយើងឃើញថា ប្រទេសកម្ពុជាបានធ្វើការរៀបចំគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមការបោះឆ្នោតមួយដងជាពីរដង ដើម្បីនាំយកនូវប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការក៏ដោយ ក៏ទីបំផុតគេបានប្រែក្លាយប្រព័ន្ធគ្រប់គ្រងមកតាមលំនាំចាស់ពីសម័យបារាំង គឺការគ្រប់គ្រងបែបមជ្ឈការដដែល។

ការគ្រប់គ្រងបែបមជ្ឈការ គឺជាការគ្រប់គ្រងមួយដែលអំណាចទាំងអស់ស្ថិតនៅក្នុងថ្នាក់កំពូលកណ្តាល។ ប្រព័ន្ធរដ្ឋបាលត្រូវបានគេគោរពទៅតាមឋានានុក្រមពីលើចុះក្រោម បានន័យថារដ្ឋអំណាចថ្នាក់លើត្រូវមានសិទ្ធិបញ្ជាទៅរដ្ឋអំណាចថ្នាក់ក្រោម ហើយរដ្ឋអំណាចថ្នាក់ក្រោមមុននឹងធ្វើអ្វីមួយត្រូវតែរង់ចាំទទួលនូវការបញ្ជា ឬការសំរេចយល់ព្រមពីថ្នាក់លើ។[9]

រហូតមកដល់ពេលនេះ រដ្ឋអំណាច-សង្កាត់ទាំងអស់ពុំត្រូវបានផ្លាស់ប្តូរដោយប្រជាពលរដ្ឋឡើយ គឺត្រូវបានដកចេញនិងតែងតាំងពីថ្នាក់លើ ហើយអ្នកខ្លះកាន់អំណាចរាប់សិបឆ្នាំដោយពុំមានអាណត្តិនៃការងារអ្វី

[9] ឯកសារដើមៈសរសេរដោយ ខុំម្រៃហួល ដកស្រង់ចេញពី "ព្រឹត្តិបត្រអ្នកឃ្លាំមើល ច្បាប់ចេញផ្សាយ ឆ្នាំទី០៣ លេខ១១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០០"។

ឡើយ។ រាល់ការងាររបស់ថ្នាក់មូលដ្ឋានអនុវត្តកន្លងមកគ្រាន់តែបំពេញទៅតាមបទបញ្ជាណែនាំពីថ្នាក់លើ គឺពុំមានសិទ្ធិស្វ័យសំរេច និងការទទួលខុសត្រូវអ្វីទាំងអស់។ បញ្ហាមួយទៀតដែលយើងគួរកត់សំគាល់នោះគឺរដ្ឋអំណាចមូលដ្ឋានឃុំ សង្កាត់ សុទ្ធតែត្រូវបានតែងតាំងពីគណបក្ស ហេតុនេះការងារអ្វីៗគឺគេត្រូវធ្វើតែងមាននិន្នាការបំរើឱ្យគណបក្សរបស់គេ គឺមិនមែនបំរើផលប្រយោជន៍ប្រជាជនទាំងស្រុងឡើយ ។

នៅក្នុងរបបប្រកាន់លទ្ធិកុម្មុយនីស្តបានប្រើប្រាស់រចនាសម្ពន្ធ័ក្រុមភូមិ ឃុំ ជា "អង្គការភ្នែកម្នាស់"។ ហេតុនេះហើយដែលធ្វើឱ្យផែនការអភិវឌ្ឍមូលដ្ឋាន ក៏ដូចជាប្រទេសជាតិមានការលំបាក និងយឺតយ៉ាវ ព្រោះត្រូវរង់ចាំទទួលការងារ ឬត្រូវរង់ចាំសុំយោបល់ ឬការអនុញ្ញាតពីថ្នាក់លើសិន។ ដោយការផ្តើមចេញពីបទពិសោធន៍ប្រវត្តិសាស្ត្រនៃការគ្រប់គ្រងឃុំ សង្កាត់ គោលនយោបាយនៃរាជរដ្ឋាភិបាលអាណត្តទី២នេះ គឺមានគោលដៅចម្បងក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយផ្តើមចេញពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ទៅតាមគោលនយោបាយគ្រប់គ្រង ឃុំ សង្កាត់ តាមប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ។[10]

### ១.៣. ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ តាមបែបវិមជ្ឈការ

ប្រទេសដែលអនុវត្តតាមគោលការណ៍វិមជ្ឈការ នាំមកនូវការរីកចម្រើនខាងសេដ្ឋកិច្ចកាន់តែខ្លាំងឡើងយ៉ាងឆាប់រហ័សក៏ដូចការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងដោះស្រាយក្នុងការគ្រប់គ្រងឱ្យបានកាន់តែប្រសើរឡើងមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ ហើយការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើងថែមទៀតក្នុងនោះគឺ មានការផ្តោតយកចិត្តទុកដាក់ថែមទៀតទៅលើការធ្វើប្រតិភូកម្ម ថវិកា ភារកិច្ច និងការទទួលខុសត្រូវផ្ទាល់នៅមូលដ្ឋាន។ ក្រៅពីនេះ គឺការធ្វើឱ្យឡើងថែមទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយបានត្រឹមត្រូវនៅតាមទីកន្លែងនិងពេលវេលា ព្រោះមានការចូលរួមដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់។ ហើយនរណានឹងអាចទទួលបានផលប្រយោជន៍នោះ?

វិមជ្ឈការ ឃុំ សង្កាត់នេះគឺត្រូវបានអ្នកនយោបាយទាំងឡាយផ្តួចផ្តើមឡើង និងអនុម័តយល់ស្របអំពីកំណែទម្រង់វិមជ្ឈការនេះ ដូចនេះអ្នកនយោបាយនិងទទួលបានប្រយោជន៍ពីវាជាមិនខាន (បើមិនដូច្នេះទេ ពួកគេនិងមិនយល់ព្រមធ្វើការកំណែទម្រង់វិមជ្ឈការនោះទេ)។ ក្រៅពីអ្នកនយោបាយទាំងនេះ គឺមានប្រជាពលរដ្ឋនៅតាមមូលដ្ឋានព្រោះវិមជ្ឈការផ្តល់នូវអង្គភាពរដ្ឋបាលពោលពេញដោយការប្រជែងខ្លាំងក្លាដែលអាចឆ្លើយតបបានច្រើនជាងមុនចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ព្រោះពួកគេចង់បានការគាំទ្រពីប្រជាពលរដ្ឋនៅមូលដ្ឋានរបស់គេ។

ដូចនេះរាជរដ្ឋាភិបាលបានខិតខំ ធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការ នៅឃុំ សង្កាត់ ដើម្បីទទួលបាននូវសមិទ្ធផលជាច្រើនដូចជាៈ

---

[10] ឯកសារដើមៈសរសេរដោយ ខុំម្រែហ្វល ដកស្រង់ចេញពី "ព្រឹត្តិបត្រអ្នកឃ្លាំមើលច្បាប់ចេញផ្សាយ ឆ្នាំទី០៣ លេខ១១ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០០"។

- កាត់បន្ថយនូវភាពមិនអើពើចំពោះការអភិវឌ្ឍនៅមូលដ្ឋាន
- ជំរុញឱ្យមានការចូលរួមនិងធ្វើសកម្មភាពរួបរួមជាច្រើនផ្សេងៗ របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យកាន់តែខ្លាំងឡើង
- ពង្រឹងការឆ្លើយតប ឱ្យបានឆាប់រហ័ស និងយល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ
- បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់មូលដ្ឋាន
- បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់មូលដ្ឋាន
- ធ្វើឱ្យគម្រោងអភិវឌ្ឍកាន់តែមានចីរភាព
- ពង្រឹងនូវតម្លាភាព
- ជំរុញការទទួលខុសត្រូវកាន់តែខ្ពស់
- ធ្វើឱ្យសម្រេចបាននូវកិច្ចការប្រឹងប្រែងថ្មីៗ
- កាត់បន្ថយឥទ្ធិពលអវិជ្ជា
- ធ្វើឱ្យកម្មវិធីអភិវឌ្ឍកាន់តែលឿនជាងមុននៅមូលដ្ឋាន
- កាត់បន្ថយនូវសកម្មភាពពុករលួយ
- ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន

កត្តាទាំងអស់នេះហើយ ដែលធ្វើឱ្យប្រទេសកម្ពុជាយើងបានសម្រេចចិត្តធ្វើការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ តាមបែបវិមជ្ឈការបន្តទៀត។

### ១.៤ ចក្ខុវិស័យនៃប្រព័ន្ធវិមជ្ឈការ

ចក្ខុវិស័យនៃប្រព័ន្ធវិមជ្ឈការនយោបាយនៅក្នុងកំណែទម្រង់វិមជ្ឈការនេះ គឺមានចក្ខុវិស័យធ្វើយ៉ាងណាឱ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ឱ្យសមស្របទៅនឹងតម្រូវការឱ្យបានឆាប់រហ័សនិងទាន់ពេលវេលាការធ្វើកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដូចជាមាន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១ បានឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន និងស្របតាមទិសដៅរាជរដ្ឋាភិបាល។

### ១.៥. គោលបំណងនៃប្រព័ន្ធវិមជ្ឈការ

ការគ្រប់គ្រងនយោបាយវិមជ្ឈការ គឺផ្តើមចេញពីមូលហេតុ និងគោលបំណងសំខាន់៣យ៉ាងគឺៈ

១. ឃុំ-សង្កាត់ គឺជាថ្នាក់ដែលនៅជាប់ផ្ទាល់នឹងប្រជារាស្ត្រ។ សកម្មភាពរបស់អាជ្ញាធរឃុំ សង្កាត់ មានផលប៉ះពាល់ដល់ប្រជារាស្ត្រ និងមានឥទ្ធិពលប៉ះពាល់ដល់សកម្មភាពទូទៅរបស់រាជរដ្ឋាភិបាលទាំងមូល។ ដូច្នេះឃុំ សង្កាត់ ត្រូវតែមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសតាមច្បាប់បោះឆ្នោត ដើម្បីឱ្យមានសមត្ថ

ភាព និងលទ្ធភាពបំពេញការងារអនុវត្តន៍គោលនយោបាយវិមជ្ឈការនិងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាពនិងជោគជ័យ។

២. ចាក់គ្រឹះលទ្ធិប្រជាធិបតេយ្យឱ្យបានរឹងមាំនៅតាមមូលដ្ឋាន ពីព្រោះបើគ្រឹះលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានមិនរឹងមាំទេ លទ្ធិប្រជាធិបតេយ្យទូទាំងប្រទេស ពិសេសគឺថ្នាក់លើពុំអាចរឹងមាំបានដែរ។

៣. អនុវត្តន៍វិមជ្ឈការ នៅថ្នាក់ឃុំ សង្កាត់ ដើម្បីចូលរួមចំណែកការបន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រ ក៏ដូចជាប្រទេសជាតិដែលជាគោលបំណងចម្បង និងជាចំណុចស្នូលដែលរាជរដ្ឋាភិបាលកំពុងព្រួយបារម្ភ និងធ្វើឱ្យជីវភាពរបស់ប្រទេសជាតិកាន់តែប្រសើរឡើង។

**១.៦. ទិសដៅវិមជ្ឈការ**

ការធ្វើវិមជ្ឈការនេះ គឺ ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលមានផលប៉ះពាល់ទៅ និងជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។ លើសពីនេះទៅទៀត ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ហើយធានាការអភិវឌ្ឍប្រកបដោយចីរភាពរួមទាំងការផ្តល់សេវាឱ្យនៅកាន់តែជិតប្រជាពលរដ្ឋ និងយល់ច្បាស់អំពីតម្រូវការចាំបាច់របស់ពួកគាត់ និងបញ្ហាដែលពួកគាត់កំពុងជួបប្រទះ ដើម្បីបង្កភាពងាយស្រួលក្នុងការស្វែងរកនៅដំណោះស្រាយទាន់ពេលវេលា។

**ក.ការផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមពេញលេញ**

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ ប្រជាពលរដ្ឋគ្រប់រូប(ស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ) មានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ ឃុំ សង្កាត់ និងដំណើរការនៃការអភិវឌ្ឍមូលដ្ឋាន ដូចជា ការបញ្ចេញមតិ និងការរួមចំណែកតាមមធ្យោបាយផ្សេងៗ ។ ប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួនតាមរយៈនីតិវិធី និងយន្តការដែលបានកំណត់ក្នុងលិខិតបទដ្ឋាន និងសេចក្តីណែនាំនានា។

ប្រជាពលរដ្ឋអាចចូលរួមតាមមធ្យោបាយជាច្រើនដូចជា៖

- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលអាចធ្វើឱ្យពួកគាត់គិតថាអាចតំណាងឱ្យផលប្រយោជន៍របស់ពួកគាត់បានប្រសើរបំផុត
- បង្កើតទំនាក់ទំនងជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះការងារដែលពាក់ព័ន្ធនឹងការអភិវឌ្ឍឃុំ សង្កាត់
- លើកឡើងអំពីបញ្ហា និងផលប្រយោជន៍របស់ពួកគាត់ជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬតាមរយៈការចាត់ចែងកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលឃុំ សង្កាត់ ដោយមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្មៀនឃុំ សង្កាត់។

- ការពិនិត្យតាមដានការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាការផ្ដល់សេវា ការអនុវត្តគម្រោងអភិវឌ្ឍន៍ និងការអនុវត្តសកម្មភាពនានានៅក្នុងមូលដ្ឋានរបស់ខ្លួន
- សិទ្ធិចូលរួមទទួលបាននូវព័ត៌មានពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រជាពលរដ្ឋអាចទៅកាន់សាលាឃុំ សង្កាត់ដើម្បីបានទទួលព័ត៌មានផ្សេងៗដែលខ្លួនចង់ដឹង។

ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាភារកិច្ចយ៉ាងសំខាន់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការចូលរួមនេះជួយឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ស្វែងយល់ពីសេចក្ដីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយបង្កើតកម្មវិធីដើម្បីដោះស្រាយសេចក្ដីត្រូវការទាំងនោះ។ ប្រសិនបើ ប្រជាពលរដ្ឋបានចូលរួម ប្រជាពលរដ្ឋមានអារម្មណ៍ថានឹងមានការទទួលខុសត្រូវចំពោះការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។[11]

**ខ. ការលើកកម្ពស់ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃការរស់នៅ**

វិមជ្ឈការ ត្រូវបានចាត់ទុកថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អ។ ហើយអភិបាលកិច្ចល្អ គឺជាការអនុវត្តការងារឱ្យបានសមស្របនិងទិដ្ឋភាពសំខាន់ៗ មួយចំនួន ដូចខាងក្រោម៖

- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបំពេញការងារដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលបានកំណត់។
- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យដោយប្រជាពលរដ្ឋរបស់ខ្លួន ដូចនេះអ្វីដែលក្រុមប្រឹក្សា ឃុំ សង្កាត់បានសម្រេចនិងអនុវត្ត គឺត្រូវទទួលខុសត្រូវយ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួនមានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើផែនការឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ត្រូវផ្ដល់ព័ត៌មានពីរបៀបធនធានដែលខ្លួនមាននិងត្រូវធានាថាធនធានទាំងនោះត្រូវបានប្រើប្រាស់ ដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានតម្លាភាពនៅក្នុងការងារដែលខ្លួនបានបំពេញទាំងអស់ហើយត្រូវជម្រាបជូនសាធារណៈជនពីកិច្ចការនានាដែលខ្លួនបានពិភាក្សាឬសេចក្ដីសម្រេចដែលខ្លួនបានសម្រេច គឺត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយតាមដែលអាចនឹងទទួលមតិយោបល់របស់សាធាណៈជន អំពីសេចក្ដីសម្រេចនោះមកវិញទើបការអនុវត្តទទួលបានលទ្ធផលល្អ។

ដោយក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅកៀកប្រជាពលរដ្ឋមូលដ្ឋាននិងដឹងច្បាស់អំពីសេចក្ដីត្រូវការដូចនេះ ក្រុមប្រឹក្សា ឃុំ សង្កាត់ អាចធ្វើការដោះស្រាយនិងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ពួកគាត់។[12]

---

[11] ក្រសួងមហាផ្ទៃ៖ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ,ខែកក្កដា ឆ្នាំ២០១៧

[12] ក្រសួងមហាផ្ទៃ៖ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ,ខែកក្កដា ឆ្នាំ២០១៧,pdfទំព័រ៤

**គ. ការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាមូលដ្ឋាន**

ក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅកៀកជិតប្រជាពលរដ្ឋ ហើយអាចដឹងច្បាស់អំពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំផែនការ និងកម្មវិធីដើម្បីលើកកម្ពស់ និងកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់យ៉ាងមានប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន។ ប្រជាពលរដ្ឋអាចពិនិត្យមើលការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ថា តើការប្រើប្រាស់ធនធានទាំងនោះពិតជាបម្រើឱ្យផលប្រយោជន៍របស់ខ្លួនដែរឬទេ។ ប្រសិនបើ ប្រជាពលរដ្ឋបានចូលរួមនៅក្នុងដំណើរកសាងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងការអនុវត្តគម្រោងនានានៅមូលដ្ឋានរបស់ខ្លួននោះ នឹងធ្វើឱ្យពួកគាត់កាន់តែទទួលខុសត្រូវច្រើនថែមទៀតនៅក្នុងការអនុវត្តផែនការទាំងនោះ។[13]

## ១.៧. ចរិតលក្ខណៈនៃប្រព័ន្ធវិមជ្ឈការ

ក្នុងការគ្រប់គ្រងតាមប្រព័ន្ធវិមជ្ឈការ ទោះបីជាទម្រង់នៃការរៀបចំនេះបានផ្ទេរទៅឱ្យសមូហភាពដែនដីនូវសិទ្ធិអំណាចក្នុងការសម្រេចប្រកបដោយស្វ័យភាពយ៉ាងណាក៏ដោយ ក៏នៅមានកិច្ចការធំៗ និងសំខាន់ៗចាំបាច់ផ្សេងទៀតដែលអាជ្ញាធរកណ្តាលត្រូវរក្សាទុកផ្តាច់មុខមិនឱ្យអាជ្ញាធរ វិមជ្ឈការក្នុងការសម្រេចដដែលយើងឃើញមាន៖

- កិច្ចការការពារជាតិ
- កិច្ចការសន្តិសុខជាតិ
- កិច្ចការការទូត
- កិច្ចការពាណិជ្ជកម្មក្រៅប្រទេស
- កិច្ចការបោះពុម្ពប្រាក់
- កិច្ចការតុលាការ
- កិច្ចការធ្វើច្បាប់
- កិច្ចការអត្រានុកូលដ្ឋាន
- និងវិស័យផ្សេងទៀតដែលច្បាប់រដ្ឋកំណត់។

ប៉ុន្តែបើសង្កេតជារឿយៗ ក្នុងការផ្ទេរអំណាចដោយកំណត់ក្នុងច្បាប់សមូហភាពវិមជ្ឈការភាគច្រើនវាពាក់ព័ន្ធខ្លាំងនឹងកិច្ចការ៖

[13] ក្រសួងមហាផ្ទៃ៖ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ,ខែកក្កដា ឆ្នាំ២០១៧,pdfទំព័រ៦

- ផ្នែកសេដ្ឋកិច្ចតូចៗ
- វប្បធម៌
- សង្គមកិច្ច
- វិទ្យាសាស្ត្រ
- ជាពិសេសគឺកិច្ចការផ្នែកអភិវឌ្ឍន៍តែម្តង។

### ១.៨. លក្ខណៈវិនិច្ឆ័យនៃវិមជ្ឈការ

#### ក. វិមជ្ឈការរដ្ឋបាលដែនដី

វិមជ្ឈការរដ្ឋបាលសំដៅទៅលើការផ្ទេរមុខងារនិងការទទួលខុសត្រូវមួយចំនួនពីថ្នាក់ជាតិទៅឱ្យអង្គភាពថ្នាក់ក្រោមជាតិឬអង្គភាពដ៏ទៃទៀត។ មុខងារ និងការទទួលខុសត្រូវទាំងនោះនឹងត្រូវអាចត្រួតពិនិត្យនិងដកហូតយកត្រឡប់ទៅវិញដោយថ្នាក់ជាតិនៅពេលដែលមានការអនុវត្តប្រាសចាកពីគោលការណ៍ច្បាប់ណាមួយ ទៅនិងគោលដៅអនុវត្តដែលផ្តល់ឱ្យ។

#### ខ. វិមជ្ឈការនយោបាយ

វិមជ្ឈការនយោបាយសំដៅទៅលើការផ្ទេរឆន្ទានុសិទ្ធិ ឬអំណាចនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងកិច្ចការមូលដ្ឋានទៅឱ្យប្រជាពលរដ្ឋ ឬជាតំណាងរបស់ប្រជាពលរដ្ឋ ជារដ្ឋាភិបាលមូលដ្ឋាន(local government) តាមរយៈប្រជិបតេយ្យូបនីយកម្ម(Démocratisation)។ តាមទ្រឹស្តីនេះ ការធ្វើសេចក្តីសម្រេចផ្សេងៗដោយថ្នាក់មូលដ្ឋាន គឺមានភាពល្អប្រសើរជាងការធ្វើសេចក្តីសម្រេចពីថ្នាក់ជាតិពីព្រោះរដ្ឋាភិបាលមូលដ្ឋាននៅជិតប្រជាពលរដ្ឋ ដែលស្និទ្ធនឹងប្រជាពលរដ្ឋស្គាល់ពីតម្រូវការ និងផ្តល់ផលប្រយោជន៍របស់រាស្ត្រនៅមូលដ្ឋានជាងរដ្ឋាភិបាលថ្នាក់ជាតិ។ ឆន្ទានុសិទ្ធិ ឬអំណាចនោះជាស្វ័យភាពដែលផ្តល់ទៅឱ្យមូលដ្ឋានយោងតាមរដ្ឋធម្មនុញ្ញឬច្បាប់។ វាមិនត្រូវបានត្រួតពិនិត្យ ឬជំទាស់ដោយថ្នាក់កណ្តាលឡើយលើកលែងតែវាធ្វើឡើងដោយផ្ទុយរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀតដែលពាក់ព័ន្ធ។ តំណាងប្រជាពលរដ្ឋដែលទទួលបានអំណាចនោះ ត្រូវតែកើតចេញពីការបោះឆ្នោតផ្ទាល់ពីបណ្តាប្រជាពលរដ្ឋមិនមែនតែងតាំង ឬចាត់តាំងដោយរដ្ឋាភិបាលកណ្តាលឡើយ។ ក្នុងការអនុវត្តវិមជ្ឈការនយោបាយបានពេញលេញបានបើកផ្លូវឱ្យប្រជាពលរដ្ឋអាចចូលរួមដំណើរការតាក់តែងគោលនយោបាយនិងសម្រេចកិច្ចការមូលដ្ឋាន។ ចំពោះវិមជ្ឈការនយោបាយ(Political Decentralization) មានអត្ថន័យប្រហាក់ប្រហែលទៅនឹងពាក្យដូចជា home-rule, self-governing, self-government, self-determination, political autonomy or local autonomy។[14]

[14] ឯកសារស្តីពី "ទ្រឹស្តីវិមជ្ឈការ"របស់លោក ហួត ស៊ីនាថ ស្លាយទី៨ ដល់ទី១០នៃឯកសារសម្រាប់បង្រៀនសិស្សមន្ត្រីក្រមការជំនាន់ទី៤ នៃសាលាភូមិន្ទរដ្ឋបាល (១៥-តុលា-២០១០)

**គ. វិមជ្ឈការហិរញ្ញវត្ថុ**

វិមជ្ឈការហិរញ្ញវត្ថុ សំដៅទៅលើការបែងចែកចំណូលនិងចំណាយរបស់រដ្ឋថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន។ វិមជ្ឈការហិរញ្ញវត្ថុមិនមែនគ្រាន់តែសំដៅទៅលើការផ្ទេរអំណាចសារពើពន្ធ ធនធាន ប៉ុន្តែរួមទាំងសិទ្ធិអំណាចនៅក្នុងការគ្រប់គ្រងនិងចាត់ចែងអំណាចទាំងនោះផងដែរ។ វិមជ្ឈការហិរញ្ញវត្ថុ គឺជាផ្នែកមួយដ៏សំខាន់របស់វិមជ្ឈការ ពីព្រោះដើម្បីឱ្យអង្គវិមជ្ឈការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពនិងគណនេយ្យភាពក្នុងការទទួលបានធនធានគ្រប់គ្រាន់។[15] វិមជ្ឈការហិរញ្ញវត្ថុមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងកម្មវិធីកំណែទម្រង់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈហើយទិសដៅកំណែទម្រង់នេះនៅដំណាក់កាលទី២(២០០៨-២០១០) គឺដើម្បី "**ពង្រឹង និងអភិវឌ្ឍន៍គោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការសារពើពន្ធ(២០១៥-២០១៩)**" ដោយធានាឱ្យបានការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងច្បាប់ស្ដីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងពិចារណាអំពីគណនេយ្យភាព។ ចំណែកនៅថ្នាក់ឃុំ សង្កាត់វិញ សកម្មភាពកំណែទម្រង់ការគ្រប់គ្រងសេវាសាធារណៈដែលបានគ្រោងមានបំណងកែលម្អរៀបចំ និងការអនុវត្តថវិកាក៏ដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលនាំទៅដល់ការប្រមូលចំណូលសារពើពន្ធឱ្យកាន់តែខ្ពស់។[16]

## ផ្នែកទី២៖ គោលការណ៍គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរីត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព តម្លាភាព ដោយចំពោះ និងដោយសម្ងាត់។ ការបោះឆ្នោតនេះត្រូវបានធ្វើឡើងរៀងរាល់៥ ឆ្នាំម្ដងដោយការបោះឆ្នោតនៅគ្រប់ឃុំសង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់។[17] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុតក្រោមសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ នៅក្នុងកិច្ចដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងត្រូវរៀបចំតាមលំដាប់លំដោយដូចតទៅ៖

**ក.ការចុះឈ្មោះបេក្ខជនបោះឆ្នោត**

ការចុះឈ្មោះបេក្ខជនបោះឆ្នោត បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ចូលឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវបានចុះបញ្ជីត្រឹមត្រូវតាម

[15] ឯកសារស្ដីពី "ទ្រឹស្ដីវិមជ្ឈការ"របស់លោក ហួត ស៊ីនាថ ស្លាយទី៨ ដល់ទី១២នៃឯកសារសម្រាប់បង្រៀនសិស្សមន្ត្រីក្រមការជំនាន់ទី៤ នៃសាលាភូមិន្ទរដ្ឋបាល (១៥-តុលា-២០១០)

[16] សៀវភៅនីតិរដ្ឋបាលទូទៅរបស់សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី១ ឆ្នាំ២០១១ ទំព័រទី១១០ (កំណត់ចំណាំ)

[17] ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៦ មាត្រា ៣ថ្មី

លក្ខខណ្ឌកំណត់ក្នុងច្បាប់ស្តីពីគណបក្សនយោបាយ។[18] បន្ទាប់ពីគណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិទៅជាគណៈកម្មការឃុំសង្កាត់ រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច៩០ថ្ងៃមុនថ្ងៃបោះឆ្នោតដោយមានភ្ជាប់មកជាមួយនូវ បញ្ជីរាយនាមបេក្ខជនដែលមានចំនួនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ប្រជាពលរដ្ឋទាំងពីរភេទ មានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំសង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច២៥ ឆ្នាំគិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌ ដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។[19]

ដោយឡែក ចំណែកបេក្ខជនដែលត្រូវបានហាមឃាត់មិនឱ្យឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់រួមមានៈ

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និងចៅក្រមប្រតិភូរាជរដ្ឋាភិបាលអភិបាលរឬ អភិបាលរងរាជធានីខេត្តក្រុងស្រុកខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបំរើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង
- ព្រះសង្ឃ ឬបុព្វជិតសាសនា
- ស្មៀនឃុំសង្កាត់។

**ខ.ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបានរៀបចំ បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានយ៉ាងតិច៩០ ថ្ងៃមុនថ្ងៃបោះឆ្នោត។[20] បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុម

[18] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៦ មាត្រា ៤៩ថ្មី

[19] ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១, មាត្រា១៤

[20] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៦ មាត្រា ៤៣

ប្រឹក្សាឃុំ សង្កាត់រួច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតសំរាប់ឃុំសង្កាត់នីមួយៗមិនត្រូវតិចជាង១៥ ថ្ងៃឡើយដើម្បីមានសិទ្ធិចូលឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឡើងគិតមកដល់ថ្ងៃបោះឆ្នោត
- មិនស្ថិតក្នុងស្ថានភាពជាទណ្ឌិត និងស្ថានភាពជាជនវិកលចរិកជាដើម។[21]

### ២.២ តួនាទីភារកិច្ច និងមុខងារឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំសង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។

នៅក្នុងនោះដែលរដ្ឋបាល ឃុំ សង្កាត់មានតួនាទី ពីរប្រភេទគឺ

**ក. តួនាទីបំរើកិច្ចការមូលដ្ឋាន**

ឃុំ សង្កាត់ មានតួនាទីជុំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ឃុំ សង្កាត់ត្រូវផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនិងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ ពោលគឺរក្សាឱ្យបាននូវនិរន្តរភាពនៃសេវាសាធារណៈ។ ឃុំ សង្កាត់ត្រូវធានារក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងដែនសមត្ថកិច្ចនៃឃុំ សង្កាត់នីមួយៗនិងការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ ទៅតាមទំនៀមទម្លាប់ប្រពៃណីក្នុងតំបន់នីមួយៗ។ ក្រៅពីនេះ ឃុំ សង្កាត់ក៏ត្រូវលើកទឹកចិត្តឱ្យមានការបង្កើនផាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យប្រជាពលរដ្ឋអាចចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍ជាមួយឃុំ សង្កាត់។[22]

**ខ.តួនាទីជាភ្នាក់ងារតំណាងរដ្ឋ**

រដ្ឋបាលឃុំ សង្កាត់ជាភ្នាក់ងារមួយតំណាងឱ្យរដ្ឋ ដែលតួនាទីដូចមានចែងក្នុងច្បាប់អង្គការហើយមុខងារ និងតួនាទីដ៏ទៃទៀតដែលជាភារកិច្ចរបស់ក្រសួងស្ថាប័ននៃរដ្ឋបាលថ្នាក់លើ ក្នុងការធ្វើប្រតិភូកម្មមកឱ្យឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្ត។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។[23]

[21] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៦ មាត្រា ១៩ថ្មី

[22] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៣

[23] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៤

ក្រៅពីតួនាទីជាតំណាងរបស់ប្រជាពលរដ្ឋ និងភ្នាក់ងារតំណាងរបស់ឃុំ សង្កាត់ក៏មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិដែរ។ អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានា ក្នុងក្របខណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួន។ ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ប៉ុន្តែដីកាឃុំ សង្កាត់នេះមិនអាចផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ បើពុំនោះទេ ដីកាឃុំ សង្កាត់នឹងត្រូវមោឃដាច់ខាត។[24] រីឯអំណាចប្រតិបត្តិគឺ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសម្រេចរួចហើយ។

### ២.៣ សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំសង្កាត់។[25] រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ តាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយត្រូវចុះហត្ថលេខាដោយមេឃុំចៅសង្កាត់ សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះដីកាឃុំសង្កាត់មិនត្រូវផ្ទុយពីសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធឡើយ។[26] បើដីកាណាមួយដែលផ្ទុយពីបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះនឹងត្រូវចាត់ទុកជាមោឃៈដាច់ខាត។

អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់មានន័យថា រដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មទៅឱ្យមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តន៍ក្នុងនាមជាក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន។

ដោយឡែក ឃុំ សង្កាត់ គ្មានសិទ្ធិអំណាចសម្រេចលើវិស័យមួយចំនួនដូចខាងក្រោម៖

- ព្រៃឈើ
- ប្រៃសណីយ៍ ទូរគមនាគមន៍
- ការពារប្រទេសជាតិ

[24] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៩

[25] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៨

[26] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០១១,មាត្រា៤៩

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។[27]

### ២.៤. ការត្រួតពិនិត្យលើរដ្ឋបាលឃុំ សង្កាត់

#### ក. ការត្រួតពិនិត្យលើអង្គការឃុំ សង្កាត់

ការត្រួតពិនិត្យលើអង្គការឃុំ សង្កាត់ គឺជាការត្រួតពិនិត្យលើសមាសភាពឃុំ សង្កាត់ និងគណនេយ្យកររបស់ឃុំ សង្កាត់ទាក់ទងបេក្ខភាពជាមេឃុំ ចៅសង្កាត់ បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ទាក់ទងនឹងការតែងតាំងស្មៀនឃុំ សង្កាត់ដោយអាជ្ញាធររដ្ឋបាលកណ្ដាលពោល គឺស្មៀនឃុំ សង្កាត់ត្រូវតែងតាំងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីធ្វើការតាមដានរាល់សកម្មភាពរបស់រដ្ឋបាលឃុំ សង្កាត់។ បញ្ហាហិរញ្ញវត្ថុវិញ គណនេយ្យរាជធានី ខេត្ត ត្រូវជ្រើសតាំងជាគណនេយ្យករឃុំ សង្កាត់។ តែជាគណនេយ្យករ ដែលត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជារួមមក អាជ្ញាធររដ្ឋបាលកណ្ដាលនៅតែមានវត្តមានយ៉ាងសំខាន់ក្នុងរដ្ឋបាលឃុំ សង្កាត់ប្រយោជន៍ដើម្បីធ្វើការត្រួតពិនិត្យលើមនុស្សក៏ដូចសកម្មភាពរបស់ឃុំ សង្កាត់។

#### ខ. ការត្រួតពិនិត្យទៅលើសេចក្ដីសម្រេច

- **ផ្នែករដ្ឋបាលៈ** រាល់សេចក្ដីសម្រេចរបស់រដ្ឋបាលឃុំសង្កាត់ដែលមានខ្លឹមសារផ្ទុយពីរដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតនោះត្រូវមោឃភាពដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នេះជាការត្រួតពិនិត្យអាណាព្យាបាលភាព(បច្ឆាកាល)។
- **ផ្នែកហិរញ្ញវត្ថុៈ** រាល់គម្រងថវិការបស់ឃុំ សង្កាត់មុននឹងអនុម័តត្រូវដាក់ជូនទៅអភិបាលរាជធានីខេត្តជាមុនសិន ដើម្បីត្រួតពិនិត្យអនុលោមភាពថវិកា។ ករណីផ្ទុយនឹងអនុលោមភាព ដែលកំណត់ឡើងដោយអនុក្រឹត្យលេខ២៦ អនុក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ នោះអភិបាលរាជធានី ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឃុំ សង្កាត់ដើម្បីធ្វើការកែតម្រូវឡើងវិញ។

នៅក្នុងករណីឃុំ សង្កាត់មិនមានការយល់ព្រមមានតែមន្ត្រីក្រសួងមហាផ្ទៃប៉ុណ្ណោះដែលជាអ្នក សម្រេចចុងក្រោយ។

[27] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៤៥

**២.៥. អាណត្តិរបស់ឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ នៅកម្ពុជាមានអាណត្តិការងារចំនួន៥ឆ្នាំ។

**២.៦. កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់**

កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់មានដូចជា លិខិតបទដ្ឋានគតិយុត្តិ លិខិតរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងឯកសារ ការគ្រប់គ្រងសម្ភារៈបរិក្ខា និងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

**២.៧ លិខិតបទដ្ឋានគតិយុត្តរបស់ឃុំ សង្កាត់**

លិខិតបទដ្ឋានគតិយុត្តិឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តន៍នានារបស់ឃុំ សង្កាត់ដែលមានដូចខាងក្រោមៈ

**២.៨. លិខិតរដ្ឋបាលឃុំ សង្កាត់**

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការរួមមានៈ ដីកា សេចក្តីសម្រេច លិខិតស្នើ សេចក្តីជូនដំណឹង ឬលិខិតជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីកាអម។

**២.៩ ការគ្រប់គ្រងបុគ្គលិករបស់ឃុំ សង្កាត់**

រដ្ឋបាលឃុំសង្កាត់មានបុគ្គលិក២ប្រភេទគឺ ស្មៀនដែលរដ្ឋាភិបាលបានបញ្ជូនឱ្យមកធ្វើការក្នុងឃុំ និងបុគ្គលិករបស់ឃុំផ្ទាល់។ ស្មៀនឃុំគ្មានសិទ្ធិគ្រប់គ្រងលើបុគ្គលិកផ្ទាល់របស់ក្រុមប្រឹក្សាឃុំទេ។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំនិងស្មៀនមានភាពមិនចុះសម្រុងនឹងគ្នាក្រុមប្រឹក្សាឃុំ មានសិទ្ធិស្នើសុំប្តូរស្មៀនហើយក្រសួងមហាផ្ទៃត្រូវតែឆ្លើយតបជាវិជ្ជមានចំពោះការស្នើសុំនេះ។ ដូច្នេះរាល់ការចាត់ចែងរបៀបនេះនឹងនាំឱ្យមានតុល្យភាពអំណាចរវាងក្រុមប្រឹក្សា និងស្មៀនឃុំក្នុងការងាររដ្ឋបាលប្រចាំថ្ងៃ និងការធ្វើសេចក្តីសម្រេចនានា។

ក្របខណ្ឌច្បាប់មិនបានចែងលម្អិតអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំនោះទេ ច្បាប់គ្រាន់តែបញ្ជាក់ថាក្រុមប្រឹក្សាអាចជួយបុគ្គលិករបស់ខ្លួនផ្ទាល់ស្ថិតក្រោមការចាត់ចែង។ ជាក់ស្តែងក្រុមប្រឹក្សាឃុំ សង្កាត់អាចជួយករណីក៏ឱ្យជួយគ្រប់គ្រងចំណូលដែលឃុំរកបាន។

**២.១០. ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់**

គ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយទៅតាមប្រព័ន្ធមួយដែលមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។ ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់បានផ្តល់នូវផលប្រយោជន៍មួយចំនួនដូចជាៈ

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំក្នុងដំណើរកិច្ចពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការនិងព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំសង្កាត់។

**២.១១. ការគ្រប់គ្រងសម្ភារៈបរិក្ខាឃុំ សង្កាត់**

គ្រប់សម្ភារៈបរិក្ខារបស់ឃុំសង្កាត់ត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ ហើយបញ្ជីគ្រប់គ្រងបរិក្ខានេះត្រូវរក្សាទុកឱ្យបានល្អប្រកបដោយសុវត្ថិភាពនិងត្រូវធ្វើជាប្រចាំ។ គ្រប់សម្ភារៈបរិក្ខារបស់ឃុំសង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់។

**២.១២. ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

**ក. លិខិតអញ្ជើញ**

មេឃុំ ចៅសង្កាត់ ត្រូវតែធានាថាលិខិតអញ្ជើញត្រូវបានរៀបចំនិងផ្ញើជូនដល់អ្នកដែលត្រូវបានចូលរួមប្រជុំគ្រប់គ្នាទាំងអស់ឱ្យបានមុនពេលប្រជុំ។ លិខិតអញ្ជើញ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ពេលវេលា ទីកន្លែងនិងបញ្ហាសំខាន់ដែលត្រូវពិភាក្សាឬជម្រាបនៅពេលប្រជុំ និងឯកសារពាក់ព័ន្ធដែលភ្ជាប់ជាមួយនឹងលិខិតអញ្ជើញ។

**ខ.ការបង្កើតរបៀបវារៈប្រជុំ**

គ្រប់ការប្រជុំទាំងអស់ត្រូវមានរបៀបវារៈហើយត្រូវផ្ញើជូនដល់អ្នកចូលរួមជាមុន ជាការប្រសើរអ្នកចូលរួមក៏មានឱកាសចូលរួមក្នុងការរៀបចំរបៀបវារៈ។

ចំណុចមួយចំនួនដែលយើងលើកមកក្នុងការបង្កើតរបៀបវារៈរួមមានដូចជា៖

- ការងារដែលត្រូវពិភាក្សានិងសម្រេច
- ព័ត៌មានដែលត្រូវជម្រាប
- ពេលវេលាសម្រាប់កិច្ចប្រជុំ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ច្រើនជាងមួយភាគបីអាចបន្ថែមប្រធានបទផ្សេងទៀតដែលស្ថិតនៅក្នុងអំណាច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

ចំនួនប្រជាពលរដ្ឋ ដែលអាចដាក់ស្នើបញ្ចូលបញ្ហាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់បានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់។

**គ.ការផ្សព្វផ្សាយអំពីកិច្ចប្រជុំដល់សាធារណជន**

កាលបរិច្ឆេទ និងទីកន្លែងនៃកិច្ចប្រជុំ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយបិទខ្សែទៅលើ ក្តារខៀន ព័ត៌មានឃុំ សង្កាត់ និងពីកន្លែងសាធារណៈក្នុងភូមិទាំងអស់ និងមធ្យោបាយផ្សព្វផ្សាយសមស្របដែលមាន នៅមូលដ្ឋាន។

**២.១៣ គណនេយ្យភាព**

ប្រព័ន្ធនៃការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលឃុំ សង្កាត់ត្រូវតែមានគណនេយ្យភាព៣ ចាំបាច់នោះគឺ

- ទីមួយៈ គឺជាគណនេយ្យភាពពីលើចុះក្រោម (គណនេយ្យភាពចំពោះប្រជាពលរដ្ឋ)
- ទីពីរៈ គឺជាគណនេយ្យភាពពីក្រោមឡើងលើ (គណនេយ្យភាពចំពោះថ្នាក់ជាតិ)
- ទីបីៈ គឺជាគណនេយ្យភាពផ្ទៃក្នុង នៅក្នុងក្របខ័ណ្ឌនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។[28]

[28] ទស្សនទានអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា,ខែវិច្ឆិកា ឆ្នាំ២០១៦

# ជំពូកទី២

# កិច្ចដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំពញាឮ

## ផ្នែកទី១៖ ស្ថានភាពភូមិសាស្ត្រ

- **ទីតាំងភូមិសាស្ត្រ**

ឃុំពញាឮ ជាឃុំមួយក្នុងចំណោមឃុំទាំង១១របស់ស្រុកពញាឮ ខេត្តកណ្ដាល ដែលមានក្រុមប្រឹក្សាឃុំចំនួន០៥នាក់ស្រី០១នាក់ ថ្នាក់ដឹកនាំភូមិសរុប០៩នាក់ ស្រី០៣នាក់(ស្មើនឹង០,១៨%) មានទីតាំងភូមិសាស្ត្រស្ថិតនៅលើដងផ្លូវជាតិលេខ៥ មានទីតាំងស្ថិតនៅភាគខាងត្បូងនៃស្រុកពញាឮ មានចម្ងាយប្រមាណ០៥ គ.ម ពីសាលាស្រុក ដែលនៅតាមបណ្ដោយដៃទន្លេសាប ខាងកើតជាប់ឃុំកំពង់អូស ខាងត្បូងមានព្រំប្រទល់ជាប់នឹងឃុំព្រែកទទែន ពីសាលាស្រុក មានព្រំប្រទល់រដ្ឋបាល ខាងលិចជាប់នឹងឃុំភ្នំបាត ខាងជើងជាប់នឹងឃុំកំពង់លួង។ នៅក្នុងឃុំពញាឮមានភូមិចំនួន៣ ដែលរួមមានភូមិទួលអំពិល ភូមិពញាឮ និងភូមិព្រែកល្វា។[29]

រដ្ឋបាលឃុំចែកជា០៣ភូមិ ដែលមានផ្ទៃដីសរុប ៦៨៥.៤៦ គីឡូម៉ែត្រការ៉េ និងប្រជាពលរដ្ឋទូទាំងឃុំមានចំនួន៣៥៨៧នាក់ ស្រី១៦៧១នាក់(ស្មើនឹង៤៦%) ស្មើនឹង៩៣១គ្រួសារ ក្នុងនោះមានអាយុ១៨ឆ្នាំឡើងមានចំនួន៣២៧៣នាក់(ស្មើនឹង៦៦%) ស្រី១២៤៤នាក់(ស្មើនឹង៥២%) ជនពិការមានចំនួន៣នាក់(ស្មើនឹង ០.០៨%) ស្រី០នាក់(ស្មើនឹង០%)។[30]

ឃុំមានផ្លូវដែកឆ្លងកាត់ប្រវែងប្រមាណ៥គីឡូម៉ែត្រ ផ្លូវជាតិឆ្លងកាត់ប្រវែងប្រមាណ៥គីឡូម៉ែត្រ គម្រោងផ្លូវបេតុងអភិវឌ្ឍន៍ជនបទប្រវែង ៥៥០ម៉ែត្រនៅក្នុងឆ្នាំ២០២០ និងផ្លូវលំក្នុងភូមិប្រវែង១០ គីឡូម៉ែត្រផ្សេងទៀតដែលសម្រួលដល់ការធ្វើដំណើរ និងដឹកជញ្ជូនរបស់ប្រជាពលរដ្ឋ។

ទន្ទឹមនឹងនោះដែរ ឃុំមានប្រព័ន្ធធារាសាស្ត្រសំខាន់ៗដូចជា៖

- ស្ទឹងព្រែកប្រវែង៥គីឡូម៉ែត្រ
- មេទឹកចំនួន៦កន្លែង។[31]

- **លក្ខណៈប្រជាជន**

ដោយហេតុថា ឃុំពញាឮមានចំនួនត្រឹមតែ៣ភូមិ ដូច្នេះចំនួនប្រជាជនក៏នៅមានកម្រិតទាប ដែលចំនួនប្រជាជនសរុបរួមមាន៣ ៨១៦នាក់(ស្របតាមទិន្នន័យក្នុងឆ្នាំ២០២០) ដែលក្នុងនោះមានស្រីសរុប ១ ៩៨៦នាក់ រួមមាន៨៦៦ គ្រួសារ មាន៧៨៥ខ្នងផ្ទះ។ ជាក់ស្ដែង ប្រជាជនភាគច្រើននៅឃុំពញាឮ បានកំពុងប្រើប្រាស់ប្រព័ន្ធ

---

[29] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២)

[30] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២)

[31] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២)

ទឹកស្អាតដែលក្នុងនោះមានចំនួនរហូតទៅដល់៦១៧គ្រួសារ។ រីឯជីវភាពប្រជាជននៅក្នុងឃុំមានកម្រិតមធ្យមនៅឡើយ ដែលប្រកបមុខរបរលក់ដូរធម្មតា ធ្វើស្រែចំការ(ស្រែប្រាំង) ដាំដំណាំពោត និងជាកម្មកររោងចក្រ។[32]

## ផ្នែកទី២៖ ការរៀបចំ និងការប្រព្រឹត្តិទៅនៃរដ្ឋបាលឃុំពញាឮ

### ២.១. រចនាសម្ព័ន្ធឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗ ត្រូវមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួន ដោយយោងតាមបទបញ្ញត្តិដូចដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

#### ក.ក្រុមប្រឹក្សាឃុំសង្កាត់

ឃុំ សង្កាត់ គឺជារដ្ឋបាលគ្រប់គ្រងទាបជាងគេបង្អស់ ដោយក្នុងនោះមានឃុំ សង្កាត់ចំនួន ១ ៦២១ នៅទូទាំងប្រទេសកម្ពុជា។[33] ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ សមជិកពី៥ ទៅ១១រូបផ្អែកតាមប្រជារាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរនៃប្រជាសាស្ត្រ និងភូមិសាស្ត្រ។ សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដ៏ទៃទៀតដែរ។[34] ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធានម្នាក់ ដែលជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវការជំនួយដោយជំទប់ទី១/ចៅសង្កាត់រងទី១ម្នាក់ និងជំទប់ទី២/ចៅសង្កាត់រងទី២ម្នាក់[35] ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការជួបប្រជុំយ៉ាងហោចណាស់មួយខែម្តង[36]។ គម្រោងផែនការអភិវឌ្ឍន៍ គម្រោងថវិកា ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ។ នៅក្នុងឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹប្រក្សាទាំងមូល ដោយសំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។[37] ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីពីរគឺ៖ (១)តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និង(២) តួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋដែលធ្វើឱ្យមានការចោទជាសំនួរឡើងទាក់ ទងនឹងថាតើក្រុមប្រឹក្សាឃុំ សង្កាត់តំណាងឱ្យនរណាពិតប្រាកដ(រាស្ត្រ ឬក៏រដ្ឋ) ចំណែកបញ្ហាមួយទៀតគឺ ឯក្ខភាពនៃទំនាស់ផលប្រយោជន៍។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិហើយមានតួនាទីកាតព្វកិច្ចបន្ទាប់បន្សំជាច្រើនទៀតនៅក្នុងការប្រព្រឹត្តិទៅរបស់ខ្លួន។

[32] ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨- ២០២២)

[33] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,មាត្រា ១៤៥

[34] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា១២

[35] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៣៣

[36] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា២១

[37] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា២២

**ខ. មេឃុំ ចៅសង្កាត់**

មេឃុំ ចៅសង្កាត់វិញមានតួនាទីដូចជាអនុវត្តន៍សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការធ្វើសេចក្តីរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនឱ្យបានយ៉ាងតិចមួយខែម្តង។ ហើយក៏នៅមានការអនុវត្តបទបញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ និងការផ្តល់យោបល់ផ្សេងទៀត និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហរិញ្ញវត្ថុ និងចាត់ចែងអនុវត្តន៍តួនាទីមុខងារ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំព្រមទាំងកិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាឃុំបានប្រគល់ឱ្យ។[38]

**គ. ជំទប់ ឬ ចៅសង្កាត់រង**

ជំទប់ឃុំ ឬចៅសង្កាត់រងមានតួនាទីដូចជា ជំទប់ឃុំជាជំនួយការរបស់មេឃុំ(ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៣៩) ហើយអនុវត្តកិច្ចការងារដែលមេឃុំប្រគល់ឱ្យ និងជាជំនួយការមេឃុំទៅតាមឋានានុក្រមនៃជំទប់នៅពេលដែលមេឃុំអវត្តមាន។ ហើយក្នុងនោះដែរ ជំទប់ទី១ជាជំនួយការមេឃុំលើកិច្ចការសេដ្ឋកិច្ចហិរញ្ញវត្ថុ រីឯជំទប់ទី២ ជាជំនួយការមេឃុំលើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្តាប់ធ្នាប់សាធារណៈ។ គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ត្រូវបានបង្កើតឡើងនៅក្នុងករណីដែលមេឃុំមានការចាំបាច់នៅក្នុងការអនុវត្តគោលនយោបាយរបស់ឃុំ ហើយគណៈកម្មាធិការនានា មានតួនាទីផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាដូចជាការកសាងផែនការ និងថវិកាឃុំ រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន និងផ្តល់យោបល់ពីវិធានការដែលត្រូវអនុវត្តន៍ពាក់ព័ន្ធជាមួយនឹងការងារ។

**ឃ. គណៈកម្មធិការ**

គណៈកម្មាធិការនានាមានតួនាទីផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាដូចជាការកសាងផែនការ និងថវិកាឃុំ រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន និងផ្តល់យោបល់ពីវិធានការដែលត្រូវអនុវត្តន៍ពាក់ព័ន្ធជាមួយនឹងការងារ។

**ង. សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីដូចជា ត្រូវធ្វើការធានាថាក្រុមប្រឹក្សាឃុំប្រើប្រាស់អំណាចតួនាទី និងភារកិច្ចដូចដែលមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ ហើយសមាជិកក្រុមប្រឹក្សាឃុំក៏ត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ និងធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋផងដែរ។

**ច. ស្មៀន ឃុំសង្កាត់**

ឃុំ សង្កាត់ទាំងអស់មិនមែនមានតែក្រុមប្រឹក្សាឃុំពញាព្ទប៉ុណ្ណោះទេ គឺត្រូវមានបុគ្គលិកក្រសួងមហាផ្ទៃ ហើយជាមន្ត្រីមុខងារសាធារណៈតែងតាំង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយអាចផ្លាស់ប្តូរតាម

[38] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,ឆ្នាំ២០០១,មាត្រា៣៩

សំណើរបស់មេឃុំ ចៅសង្កាត់ដោយផ្អែកតាមការសម្រេចពីក្រុមប្រឹក្សាឃុំ សង្កាត់នោះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងចេញប្រកាសផ្លាស់ប្តូរ។ [39]

**ឆ. មេភូមិ**

មេភូមិមានតួនាទីទទួលខុសត្រូវរួមនៅក្នុងភូមិរបស់ខ្លួន ហើយជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិនីមួយៗ និងជាខ្សែរយៈចម្បងសម្រាប់ទំនាក់ទំនងរវាងឃុំ និងក្រុមប្រឹក្សាឃុំ។ មិនតែប៉ុណ្ណោះ មេភូមិមានភារកិច្ចអនុវត្តន៍កិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីជានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងភូមិ។ បង្កើតការពិគ្រោះ ផ្តល់យោបល់ទទួលការណែនាំ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ លើកឡើងពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ភូមិរបស់ខ្លួន និងធ្វើការស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។[40]

**២.២. សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់**

ដោយផ្អែកទៅលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល សមាសភាពនៃក្រុមប្រឹក្សាមានបញ្ជីរាយមានដូចតទៅៈ

- លោក យូ ផាត់ ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ)
- លោក ប៉ែន សុខន ជាសមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១ ផ្នែកកសិកម្ម)
- លោក ជៀម ស៊ុយ សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២ផ្នែកដោះស្រាយទំនាស់)
- លោក ប៉ាល់ យ៉ាង សមាជិកក្រុមប្រឹក្សាឃុំ (ធម្មការ និងសាសនា)
- អ្នកស្រី សៀង ចាន់ណា សមាជិកក្រុមប្រឹក្សាឃុំ (កិច្ចការនារី & កុមារ)
- លោក ម៉ៅ គឹមសៀន ស្មៀនឃុំ។[41]

**ផ្នែកទី៣ៈ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំពញាឮ**

ឃុំ សង្កាត់ជានីតិបុគ្គលសាធារណៈដែលមានធនធានសម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន។ តាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តម្រូវឱ្យមានឃុំ សង្កាត់នីមួយៗមានធនធានហិរញ្ញវត្ថុថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។[42] ឃុំ សង្កាត់មានសិទ្ធិអំណាចគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់របស់ខ្លួន និងមានប្រភពចំណូលចំណាយមួយចំនួនផងដែរ។

[39] (អនុបណ្ឌិត ហៀង សាង,នីតិរដ្ឋបាលទូទៅ,ឆ្នាំ២០១១,ទំព័រ១២២)

[40] (សៀវភៅក្រសួងមហាផ្ទៃ,ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ,ឆ្នាំ២០០៧,ទំព័រ២១)

[41] កិច្ចសម្ភាសន៍ជាមួយ លោក យូ ផាត់ ដោយ ភា សុឃីម និង សរ សោភាវឌ្ឍនា ថ្ងៃទី០៣ ខែ០៦ ឆ្នាំ២០២០

[42] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៣។

### ៣.១. ការរៀបចំ និងអនុម័តថវិកាឃុំ

គម្រោងថវិកាត្រូវបានរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសង្កាត់ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីត្រួតពិនិត្យ និងអនុម័ត។ ហើយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវអនុម័តគម្រោងថវិកានៃកិច្ចប្រជុំជាសាធារណៈ។ ចំពោះឃុំពញាឮមុននឹងរៀបចំថវិកានេះផងដែរ ឃុំតែងតែធ្វើការប្រឹក្សាយោបល់ពីប្រជាពលរដ្ឋសិក្សាអំពីតម្រូវការរបស់ពួកគាត់ដើម្បីធ្វើឱ្យងាយស្រួលនៅក្នុងការរៀបចំថវិកាឱ្យត្រូវតាមទិសដៅដែលប្រជាពលរដ្ឋនៅក្នុងឃុំចង់បាន និងឱ្យប្រជាពលរដ្ឋផ្តិតមេដៃចូលរួមចំណែកក្នុងការដឹងឮ និងជាសាក្សីផងដែរ។ ជាក់ស្តែងចំពោះការរៀបចំគម្រោងថវិកាឆ្នាំ ២០២០ របស់ឃុំពញាឮ គឺឃុំបានរៀបចំថវិកាចំនួន៣៤៧,៦០៦,៩៣៩រៀល ដើម្បីធ្វើការវិនិយោគនៅក្នុងឃុំ និងសម្រាប់បំពេញនូវតម្រូវការផ្សេងទៀតរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។[43] បន្ទាប់ពីការអនុម័តគម្រោងថវិកានៅថ្នាក់ឃុំរួចរាល់ហើយមេឃុំពញាឮក៏បញ្ជូនគម្រោងថវិកានេះទៅការអភិបាលខេត្តកណ្តាល។ ក្រោយពីអភិបាលខេត្តឯកភាពលើគម្រោងថវិកានេះ ហើយលោកក៏បញ្ជូនសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកឱ្យលោកមេឃុំវិញ ហើយដើម្បីបញ្ជាក់ពីការទទួលស្គាល់លើការគម្រោងថវិកាដែលសេចក្តីជូនដំណឹងនេះមានថតចម្លងជូននិងភ្ជាប់ជាមួយគម្រោងថវិកាទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្តផងដែរ។[44]

#### ៣.១.១ ប្រភពចំណូលរបស់ឃុំ

ឃុំ សង្កាត់មានប្រភពចំណូលចំនួន៣ គឺចំណូលផ្ទាល់ ចំណូលពីមូលនិធិឃុំ សង្កាត់ និងចំណូលពីការអនុវត្តពីមុខងារ។

- **ចំណូលផ្ទាល់**

ឃុំ សង្កាត់មានសិទ្ធិក្នុងការប្រមូលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធនិងចំណាយមិនមែនសារពើពន្ធក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន។ ការអនុវត្តកិច្ចនេះរង់ចាំច្បាប់ដោយឡែកទើបអនុវត្តបាន។[45]

- **ចំណូលពីមូលនិធិ**

ឃុំ សង្កាត់ចំណូលពីមូលនិធិឃុំ សង្កាត់គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ទៅឱ្យឃុំ សង្កាត់នីមួយៗដែលក្នុងនោះរួមមានចំណូលសម្រាប់ចំណាយរដ្ឋបាល និងចំណាយអភិវឌ្ឍន៍ឃុំ សង្កាត់។[46]

[43] កិច្ចសម្ភាសន៍ជាមួយ លោក យូ ផាត់ ដោយ ភា សុឃីម និង សរ សោភាវឌ្ឍនា ថ្ងៃទី០៣ ខែ០៦ ឆ្នាំ២០២០។
[44] កិច្ចសម្ភាសន៍ជាមួយ លោក យូ ផាត់ ដោយ ភា សុឃីម និង សរ សោភាវឌ្ឍនា ថ្ងៃទី០៣ ខែ០៦ ឆ្នាំ២០២០។
[45] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៤
[46] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,មាត្រា៧៨

- **ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ**

ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ គឺជាចំណូលដែលបានមកពីការបំពេញការងារដោយឃុំ សង្កាត់ ជំនួសមុខឱ្យក្រសួង ស្ថាប័ន ឬអង្គភាពនានា របស់រដ្ឋទៅតាមការព្រមព្រៀងគ្នា ។ ក្រៅពីចំណូលទាំងបីខាលើ នេះឃុំ សង្កាត់មានចំណូលផ្សេងៗទៀតដូចជាចំណូលពីការរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន ចំណូលបាន មកពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។ ចំពោះមុខច្បាប់នៅក្នុងប្រភពចំណូលថវិកានេះឃុំសង្កាត់ត្រូវ ទទួលខុសត្រូវការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ដើម្បីធានាការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ តម្លាភាព សន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់។

### ៣.១.២. ប្រភពចំណាយរបស់ឃុំ

ឃុំ សង្កាត់មានចំណាយពីរ គឺចំណាយចរន្ត និងចំណាយមូលធន។

ចំណាយចរន្ត មានប្រាំពីរប្រភេទគឺចំណាយបៀវត្ស និងប្រាក់បំណាច់ ចំណាយរដ្ឋបាលទូទៅ ចំណាយ សេវាសាធារណៈ ចំណាយសម្រាប់មុខងារជាភ្នាក់ងារ ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច និងចំណាយមិនបាន គ្រោងទុក។

ចំណាយមូលធន មានពីរប្រភេទ គឺចំណាយវិនិយោគផ្នែករដ្ឋបាល និងចំណាយអភិវឌ្ឍន៍មូលដ្ឋាន។[47] ចំណាយរដ្ឋបាលគឺជាចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តភារកិច្ចរួមមាន ប្រឹក្សាឃុំ ការទិញគ្រឿងសង្ហារឹម សម្ភារៈ មធ្យោបាយរដ្ឋបាល ការជួសជុល និងថែទាំសម្ភារៈមធ្យោបាយរដ្ឋបាល ថ្លៃប្រើទឹកភ្លើង ទិញនិងជួសជុលយានយន្តជំនិះ និងការចំណាយផ្សេងៗទៀត។ ចំណែកឯការអភិវឌ្ឍវិញ គឺជា ការចំណាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសង្គមកិច្ច ដែលក្នុងនោះរួមមាន៖ ការអង្កេត គំនូសប្លង់ ការសាងសង់ការជួសជុល ការថែទាំ ផ្សារ មណ្ឌលសុខភាព សាលារៀន សាលាមត្តេយ្យ មជ្ឈ-មណ្ឌលសហគមន៍សំណង់ ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹក ថាមពល ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចមន្ត្រី បុគ្គលិកកិច្ចការខាងលើ កម្មវិធីអភិវឌ្ឍសហគមន៍ បរិស្ថាន និងធនធានធម្មជាតិ។

## ៣.២. ការគ្រប់គ្រងលើការចំណាយ

ការចំណាយទាំងឡាយខាងក្រោមនេះ ត្រូវបានចាត់ទុកជាចំណាយចាំចាច់របស់ឃុំ សង្កាត់ដែលត្រូវ បានឆ្លុះបញ្ចាំងជាអាទិភាពនៅក្នុងថវិកា៖

- ការចំណាយទៅលើបៀវត្ស និងប្រាក់បំណាច់
- ចំណាយទៅលើការទុកដាក់ថែរក្សាឯកសារ

[47] អនុក្រឹត្យលេខ ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា៧

- ចំណាយទៅលើថ្លៃឈ្នួលថែទាំទីស្នាក់ការឃុំ សង្កាត់
- ចំណាយថែទាំ និងប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធ ដែលឃុំ សង្កាត់ត្រូវទទួលខុសត្រូវ
- ការចំណាយទៅលើការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ការចំណាយបន្តគម្រោងការវិនិយោគកំពុងដំណើរការ
- ការចំណាយចាំចាច់ដទៃទៀតដែលសមស្របទៅតាមច្បាប់ ឬបទបញ្ជាដែលបានកំណត់។[48]

ដោយឡែក យោងតាមការសម្ភាសន៍ផ្ទាល់ជាមួយលោកមេឃុំ **យូ ផាត់** បានលើកឡើងពីការចំណាយផ្សេងៗជាក់ស្តែងរបស់ឃុំពញាឮសម្រាប់ឆ្នាំ២០២០នេះ គឺឃុំបានចំណាយទៅលើ ការអភិវឌ្ឍ និងកិច្ចការងាររដ្ឋបាលអស់ចំនួនទឹកប្រាក់ជាសរុប១១៩,៣៣០,០០០ រៀល និងផ្នែកកិច្ចការនារី និងសាលាមត្តេយ្យសហគមន៍ចំនួនពីរកន្លែងសរុបជាទឹកប្រាក់ចំនួន១១៥,៨២០,០០០រៀល និងការចំណាយផ្សេងៗទៀត។[49]

## ផ្នែកទី៤៖ ប្រព័ន្ធទូទាត់ គណនេយ្យ និងកិច្ចលទ្ធកម្មសម្រាប់ឃុំ

### ៤.១. គោលការណ៍ទូទៅ

ឃុំ សង្កាត់ត្រូវបង្កើតគណនីប្រាក់បញ្ញើនៅរតនាគាខេត្តក្រុង។[50] ហើយមេឃុំចៅសង្កាត់ជាអាណាប័ក និងមានសិទ្ធិពេញលេញនូវការប្រមូលឬសន្យាចំណាយ និងបញ្ជាចំណាយដោយផ្អែកលើថវិកាដែលបានអនុម័ត។ មេឃុំ ចៅសង្កាត់ អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅឱ្យជំទប់ ឬចៅសង្កាត់រងរបស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវនិងត្រួតពិនិត្យរបស់មេឃុំចៅសង្កាត់មេឃុំ ចៅសង្កាត់។ មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ។[51] ហើយអ្នកទទួលសិទ្ធិនិងបុគ្គលិករដ្ឋបាលឃុំសង្កាត់ជាទូទៅមិនត្រូវអនុញ្ញាតឱ្យកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយលើកលែងតែក្នុងករណីទូទាត់បេឡាបុរេប្រទាន និងចំណូលដែលប្រមូលបានដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀតសិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់ឱ្យមនុស្សតែម្នាក់បានឡើយហើយរតនាគារខេត្ត ក្រុង ត្រូវបំពេញមុខងារជាគណនេយ្យករឃុំ សង្កាត់។

### ៤.២. ប្រព័ន្ធទូទាត់

ការទូទាត់ផ្ទាល់ គឺគេទូទាត់តាមរយៈរតនាគារខេត្តក្រុងហើយការទូទាត់ផ្ទាល់តាមរយៈបេឡាបុរេប្រទានត្រូវបានបានប្រើសម្រាប់តែចំណាយចរន្ត(លើកលែងប្រាក់បៀវត្ស និងប្រាក់បំណាច់) និងចំណាយវិនិយោគ

[48] អនុក្រឹត្យលេខ ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា៩
[49] ទិន្នន័យពីការសម្ភាសន៍ផ្ទាល់ជាមួយលោកមេឃុំពញាឮនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង៩:៣៥នាទី
[50] អនុក្រឹត្យលេខ ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៩
[51] អនុក្រឹត្យលេខ ២៦ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៧

រដ្ឋបាល។ ហើយការចំណាយមួយលើកៗចេញពីបេឡាបុរេប្រទានត្រូវមានចំនួនទឹកប្រាក់នៅក្រោមគំនិតណាមួយជាកំណត់តាមនីតិវិធីបេឡាបុរេប្រទាន។[52]

**៤.៣. ប្រព័ន្ធគណនេយ្យ**

គណនេយ្យហិរញ្ញវត្ថុ គឺជាកិច្ចបញ្ជីការរាល់ចំណូលចំណាយនៅក្នុងប្រព័ន្ធគណនេយ្យ ហើយអ្នកដែលមានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ គឺគណនេយ្យករនៅរតនាគាររាជធានី ខេត្ត ។ គណនេយ្យថវិកា គឺជាការតាមដាននិងរាយការណ៍អំពីការអនុវត្តចំណូលចំណាយ និងថវិកាដែលមានអនុម័ត។ ហើយអ្នកដែលមានភារកិច្ចទទួលខុសត្រូវក្នុងការអនុវត្តគណនេយ្យថវិកា គឺមេឃុំចៅសង្កាត់។[53]

**៤.៤. កិច្ចលទ្ធកម្មឃុំ សង្កាត់**

កិច្ចលទ្ធកម្ម គឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេញទទួលបានទំនិញសំណង់ឬសេវាកម្ម។ ចំណែកឯលទ្ធកម្មវិញសំដៅទៅដល់ការទិញឬការរកបាននូវទំនិញសំណង់ឬសេវាកម្មតាមរយៈវិធីសាស្ត្របានដោយធានាគុណភាពអ្នកទទួលការអ្នកផ្តល់សេវា និងអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើគ្នាដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌយុត្តិធម៌ និងស្មើភាពលទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ។ ចំពោះសមាសភាពគណៈកម្មការលទ្ធកម្មនេះផងដែររួមមានដូចជា៖ មេឃុំចៅសង្កាត់ជាប្រធានហើយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ២រូបជាសមាជិកនិងស្មៀនឃុំសង្កាត់ដែលបំពេញតួនាទីជាលេខាធិការដូចដែលបានកំណត់។ គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មមានដូចជាលទ្ធកម្មសំណង់លើសេវាកម្មនិងលទ្ធកម្មទំនិញត្រូវអនុវត្តក្នុងលក្ខណៈមួយ ដែលមានតម្លាភាពប្រសិទ្ធភាព និងធ្វើសំចៃបំផុតតាមដែលអាចធ្វើទៅ គណៈកម្មការលទ្ធកម្មឃុំ សង្កាត់។ ដោយឡែកចំពោះវិធីសាស្ត្រលទ្ធកម្មវិញ គឺត្រូវអនុវត្តដូចជាការដេញថ្លៃដោយប្រកួតប្រជែងជាចំហ(ជាសាធារណៈ) ការស្ទង់តម្លៃក្នុងស្រុក និងការបំពេញដោយផ្ទាល់ឬការចុះកិច្ចសន្យាផ្ទាល់ (ការចរចាតម្លៃផ្ទាល់)។

## ផ្នែកទី៥៖ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ (សម្រាប់ឆ្នាំ២០១៨-២០២២)

**៥.១. ចក្ខុវិស័យអភិវឌ្ឍន៍**

ប្រជាពលរដ្ឋរស់នៅក្នុងឃុំពញាញានជីវភាពកាន់តែប្រសើរឡើងរស់នៅប្រកបសុភមង្គល សុវត្ថិភាពសន្តសុខសង្គម សុខុមាលភាព រស់នៅក្នុងបរិស្ថានល្អ តាមរយៈនិរន្តរភាព នៃកិច្ចអភិវឌ្ឍប្រកបដោយសមធម៌និងបរិយាប័ន្ន។

[52] អនុក្រឹត្យលេខ ២៦ អន.ក្របកស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា៣១

[53] អនុក្រឹត្យលេខ ២៦ អន.ក្របកស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់,មាត្រា២៤

### ៥.២. គោលបំណងអភិវឌ្ឍន៍

គោលបំណងអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំពញាឮ គឺខិតខំធ្វើយ៉ាងណាឱ្យផែនការនេះអភិវឌ្ឍន៍លើគ្រប់វិស័យ គ្រប់ផ្នែកទាំងអស់ឱ្យ មានការរីកលូតលាស់ និងរីកចំរើនខ្លាំងជាងឆ្នាំមុនៗ ទាំងផ្នែកសង្គមកិច្ច ផ្នែកគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រួមទាំងផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈផងដែរ។ ម្យ៉ាងវិញទៀត នៅក្នុងគោលបំណងនៃផែនការអភិវឌ្ឍន៍នេះគឺចង់បម្រើសេវាសាធារណៈឱ្យប្រជាពលរដ្ឋនៅក្នុងឃុំឱ្យកាន់តែល្អ រហ័ស និងទាន់ពេលវេលា។

### ៥.៣. គោលដៅអភិវឌ្ឍន៍

#### ៥.៣.១.គោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច

នៅក្នុងគោលដៅអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច គឺផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍នៅក្នុង វិស័យកសិកម្ម ឧស្សាហកម្ម គមនាគមន៍ សេវាកម្ម និងវិស័យវិនិយោគ ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ។ ក្រុមប្រឹក្សាឃុំពញាឮ បានរៀបចំគោលដៅចំពោះការអភិវឌ្ឍលើវិស័យកសិកម្មដោយនៅឆ្នាំ២០២២ ទិន្នផលស្រូវនិងកើនឡើងរហូតទៅដល់០៣ហិចតា។ ការដាំដុះដំណាំគ្រប់ប្រភេទ និងការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនឹងមានការកើនឡើងជាកំហិត ព្រមជាមួយនិងការរៀបចំនូវប្រព័ន្ធស្រោចស្រពត្រូវការស្តារ និងជួសជុសបម្រើដល់ការងារកសិកម្ម ដើម្បីឱ្យស្ថានភាពរបស់កសិករកាន់តែមានភាពងាយស្រួលនៅក្នុងការធ្វើកសិកម្មរបស់ពួកគាត់។ រីឯវិស័យឧស្សាហកម្មវិញ គឺផ្តោតសំខាន់ទៅលើទីតាំងផលិតកម្មនានាក្នុងឃុំកាន់តែកើនឡើង ព្រមជាមួយនឹងការកើនឡើងនៃរោងចក្រ សហគ្រាសផ្សេងៗទៀតកាន់តែកើនឡើងជាលំដាប់ ដើម្បីជាផលប្រយោជន៍ក្នុងការផ្តល់ជាការងារដល់ប្រជាពលរដ្ឋចូលទៅធ្វើការនៅក្នុងរោងចក្រ និងសហគ្រាសទាំងនោះ។ នេះក៏ជាការរួមចំណែកមួយ ក្នុងការផ្តល់នូវឱកាសការងារដល់ប្រជាពលរដ្ឋក្នុងឃុំផងដែរ។ ចំណែកឯវិស័យគមនាគមន៍វិញ ក្រុមប្រឹក្សាឃុំ មានការយកចិត្តទុកដាក់ខ្លាំងទៅលើការអភិវឌ្ឍន៍ផ្លូវលំជាច្រើនផ្លូវនៅក្នុងភូមិនានាទូទាំងឃុំ ដូចជាធ្វើការជួសជុល និងកែលម្អរផ្លូវឡើងវិញ ចំពោះផ្លូវណាដែលខូចខាតដើម្បីសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋឱ្យតែមានភាពងាយស្រួល។

ចំពោះវិស័យសេវាកម្មក៏ដូចគ្នា សេវាកម្មអគ្គីសនីត្រូវតែពង្រីកបណ្តាញអគ្គីសនីបន្ថែមទៀតជូនប្រជាពលរដ្ឋនៅតាមភូមិដើម្បីប្រជាពលរដ្ឋទទួលបានអគ្គីសនីប្រើប្រាស់គ្រប់គ្រាន់ស្របតាមតម្រូវការរបស់ពួកគាត់។ រួមជាមួយនិងការពង្រីកបន្ថែមរបស់ក្រុមហ៊ុនទឹកស្អាតក្នុងការផ្គត់ផ្គង់ទឹកស្អាតឱ្យគ្រប់គ្រាន់និងមានអនាម័យ ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្តក្នុងការប្រើប្រាស់ទឹកដោយសុវត្ថិភាពផងដែរ។

គោលដៅក្នុងការអភិវឌ្ឍន៍លើវិស័យវិនិយោគការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការវិញ គឺបានរៀបចំនូវគម្រោងក្នុងការវិនិយោគ ការទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិដែលទទួលបានការគាំទ្រពីមន្ទីរវិស័យ អង្គភាពដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជនឱ្យកាន់តែកើនឡើងជាមុន។

**៥.៣.២. គោលដៅអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច**

នៅក្នុងឆ្នាំ២០២២ ក្រុមប្រឹក្សាឃុំពញាឮ មានគោលដៅក្នុងការអភិវឌ្ឍលើផ្នែកសង្គមកិច្ច ដោយផ្អែកលើវិស័យជាច្រើនដូចជា វិស័យអប់រំ វិស័យសុខាភិបាល វិស័យយេនឌ័រ វិស័យលើភាពក្រីក្រ វិស័យសាសនា អន្តោប្រវេសន៍ និងការផ្លាស់ទីលំនៅ ពិការភាព និងភាពងាយរងគ្រោះជាដើម។

នៅក្នុងការអភិវឌ្ឍន៍លើវិស័យអប់រំ គឺធ្វើយ៉ាងណាឱ្យកុមារអាយុចន្លោះពី៣ឆ្នាំទៅ៥ឆ្នាំ បានចូលរៀននៅសាលាមត្តេយ្យឱ្យកាន់តែច្រើន ផ្ទុយមកវិញគឺចូលរួមក្នុងការកាត់បន្ថយអត្រានៃការមិនបានចូលរៀនរបស់កុមារអាយុ៦ឆ្នាំ និងចន្លោះអាយុពី៦ឆ្នាំ ទៅ១១ឆ្នាំ។ ការបោះបង់ការសិក្សារបស់សិស្សនៅបឋមសិក្សា និងអនុវិទ្យាល័យក៏ត្រូវតែមានកម្រិតតិចជាងមុនផងដែរ។ ប៉ុន្តែនឹងខំខិតធ្វើឱ្យអត្រានៃការប្រលងជាប់នៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិរបស់សិស្ស ឱ្យកាន់តែច្រើន។

វិស័យសុខាភិបាលវិញ គឺធ្វើការណែនាំដល់ស្ត្រីមានផ្ទៃពោះ ឱ្យទៅពិនិត្យសុខភាពជាប្រចាំនិងទៀងទាត់តាមការណែនាំរបស់គ្រូពេទ្យនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ព្រមជាមួយការណែនាំឱ្យស្ត្រីមានផ្ទៃពោះធ្វើការសម្រាលកូនដោយពេទ្យឆ្មប ដែលមានជំនាញត្រឹមត្រូវជាជាងការសម្រាលកូននៅតាមផ្ទះព្រោះការសម្រាលកូនតាមបែបបុរាណងាយនិងមានគ្រោះថ្នាក់ចំពោះម្តាយនិងកូនណាស់។ ឪពុកម្តាយគ្រប់រូបត្រូវតែយកក្មេងដែលមានអាយុ៩ ខែទៅ១២ ខែ ទៅចាក់ថ្នាំបង្ការគ្រប់ចំនួនកំណត់របស់គ្រូពេទ្យ។ ប្រជាពលរដ្ឋទាំងអស់ ជាពិសេសយុវជនត្រូវតែទទួលបាននូវការយល់ដឹងអំពី ការឆ្លងនូវជំងឺអេដស៍ គ្រុនឈាម គ្រុនចាញ់ របេង សុខភាពផ្លូវភេទ និងជំងឺឆ្លងផ្សេងៗដើម្បីជៀសឱ្យផុតពីជំងឺទាំងនោះ និងដឹងអំពីវិធីនៃការពារខ្លួនឱ្យបានត្រឹមត្រូវ។

ចំណែកឯគោលដៅអភិវឌ្ឍន៍លើវិស័យយេនឌ័រក្រុមប្រឹក្សាឃុំ ត្រូវធ្វើយ៉ាងណាឱ្យមានការកាត់បន្ថយការធ្វើចំណាកស្រុកក្រៅប្រទេសនិងក្នុងប្រទេសរបស់ស្ត្រី ផ្តល់ឱកាសឱ្យស្ត្រីទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈកាន់តែច្រើនកើនកម្ពស់ស្ត្រីឱ្យធ្វើជាថ្នាក់ដឹកនាំភូមិ និងក្រុមប្រឹក្សាឃុំ។ កាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ និងការជួញដូរលើស្ត្រី។ ក្រុមប្រឹក្សាឃុំ ក៏មានគោលដៅក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដោយការស្វែងរកការងារឱ្យប្រជាជនបានធ្វើដើម្បីជៀសវាងនៃការធ្វើចំណាកស្រុកប្រទេស និងធ្វើអន្តោប្រវេសន៍ជាដើម។

**៥.៣.៣ គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ**

ការគ្រប់គ្រងធម្មជាតិ បរិស្ថាន និងការបន្សាំនិងការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាឃុំបានរៀបចំដោយផ្អែកលើគោលដៅអភិវឌ្ឍន៍លើវិស័យការប្រើប្រាស់ដីធ្លី ដោយធ្វើយ៉ាងណាកាត់បន្ថយនៃការកើតមានឡើងនូវទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋដែលកើតមាននូវទំនាស់រវាងក្រុមហ៊ុនឬបុគ្គលដទៃ។ ស្វែងរកដំណោះស្រាយដែលទាក់ទងនិងបញ្ហាដីធ្លីឱ្យបានឆាប់រហ័ស និងទាន់ពេលវេលាក៏ដូចជាធ្វើការអប់រំ និងផ្សព្វផ្សាយពីច្បាប់ភូមិបាលនិងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីសិទ្ធិនៅក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី។

គោលដៅអភិវឌ្ឍន៍វិស័យធនធានធម្មជាតិ គឺកាត់បន្ថយការទន្ទ្រានកាន់កាប់ព្រៃលិចទឹក ឬតំបន់អភិរក្ស និងបទល្មើសនេសាទខុសច្បាប់ផ្សេងៗ ដោយជំនួសមកវិញនូវការលើកកម្ពស់យុវជនឱ្យចូលរួមនៅក្នុងការដាំកូនឈើឡើងវិញនិងចូលរួមចំណែកក្នុងការថែរក្សា និងស្រលាញ់ព្រៃឈើដែលមានស្រាប់។ ដូច្នេះយើងគួរគប្បីកាត់បន្ថយនៅការប្រើប្រាស់ថ្នាំពុលគីមីសំលាប់សត្វចង្រៃ និងស្មៅ និងជីគីមីរបស់បងប្អូនប្រជាកសិករក្នុងវិស័យកសិកម្ម ព្រោះការប្រើប្រាស់ថ្នាំទាំងនោះធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន។ ការទប់ស្កាត់នូវគ្រោះមហន្តរាយដែលអាចនឹងកើតមានឡើងនូវពេលដែលកើតមាននូវគ្រោះធម្មជាតិជាយថាហេតុ និងបញ្ហាដែលកើតមានឡើងនៅពេលកើតមាននូវការបំរែបំរួលអាកាសធាតុ។

**៥.៣.៤ គោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

នៅក្នុងគោលដៅអភិវឌ្ឍន៍ផ្នែកគ្រប់គ្រងរដ្ឋបាល ក្រុមប្រឹក្សាឃុំ បានរៀបចំឡើងនៅផែនការក្នុងការធ្វើយ៉ាងណាផ្តល់ជូននូវគ្រប់សេវាសាធារណៈ ជូនប្រជាពលរដ្ឋគ្រប់គ្នាៗប្រកបដោយ គុណភាព សេវារហ័សទាន់ពេលវេលានិងមានតម្លាភាព។ រីឯផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់វិញក្រុមប្រឹក្សាឃុំ នឹងធ្វើការពង្រឹងមិនឱ្យមានក្មេងទំនើងនៅក្នុងឃុំដែលបង្ករអសន្តិសុខនៅក្នុងឃុំ ។ ត្រូវអនុវត្តច្បាប់ស្តីពី អភិបាលកិច្ចល្អ ឱ្យបានភ្ជាប់ក្ជួរដោយដើរតាមគោលការណ៍១៤ ចំណុចរបស់ភូមិ-ឃុំមានសុវត្ថិភាព។ លុបបំបាត់គ្រឿងញៀនគ្រប់ប្រភេទ ល្បែងស៊ីសង និងបទល្មើសផ្សេងៗទៀត។

## ផ្នែកទី៦៖ អនុវត្តកម្មវិធីអភិវឌ្ឍន៍ប្រាំឆ្នាំរំកិលរបស់រដ្ឋបាលឃុំ សង្កាត់របស់ឃុំពញាឮ

កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ គឺជារបៀបវារៈឬកម្មវិធីជាក់ស្តែងដែលរដ្ឋបាលឃុំពញាឮដែលចង់សម្រេចបានក្នុងអាណត្តិទី៣ សម្រាប់បង្ហាញពីគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានមានសមាសភាគចំនួន បីគឺ៖

- ក្របខ័ណ្ឌវិនិយោគ

- ក្របខ័ណ្ឌផ្តល់សេវាកម្ម
- ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

ការរៀបចំកម្មវិធីអភិវឌ្ឍន៍មូលដ្ឋាននេះ រដ្ឋបាលឃុំពញាឮធ្វើឡើងដោយផ្អែកតាម មុខងារ ធនធានសិទ្ធិ អំណាចរបស់ខ្លួន និងខ្លឹមសារនៃក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិ៤។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាននេះ ជាឯកសារសម្រាប់ គ.ផ.ថ ពិចារណានៅពេលរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលផែនការថវិកា និងសម្រាប់ការតាមដាននិងវាយតម្លៃអំពីការបំពេញការងាររបស់រដ្ឋបាលឃុំឱ្យកាន់តែប្រសើរឡើង។

## ៦.១ ក្របខ័ណ្ឌវិនិយោគ

ក្របខ័ណ្ឌវិនិយោគ គឺជាកម្មវិធីឬរបៀបវារៈជាក់ស្តែងនិងតាមលក្ខណៈពិសេសរបស់មូលដ្ឋានសម្រាប់រដ្ឋបាលឃុំពញាឮ គិតគូរពិចារនាពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ដោយប្រើប្រាស់ធនធានដែលរដ្ឋបាលឃុំមាន។ ពាក់ព័ន្ធនឹងគោលការណ៍នៃការវិនិយោគផ្អែកទៅលើផ្នែកសេដ្ឋកិច្ចទូទាំងឃុំរួមមាន ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម បណ្តុះបណ្តាលបច្ចេកទេសការប្រើប្រាស់ដី និងថ្នាំគីមី ការសាងសង់ផ្លូវបេតុងគ្រោងនឹង១៥០០ម៉ែត្រ និងជុសជុលផ្លូវលំនៅក្នុងភូមិពញាឮចំនួន១៣០ម៉ែត្រ។ ដោយឡែកផ្នែកសង្គមកិច្ច ការសាងសង់អាគារសិក្សាពាមសត្លាសម្រាប់ភូមិព្រៃកល្ងាចំនួន១ខ្នងដែលក្នុងមួយខ្នងមាន១០បន្ទប់ ការចាក់គ្រោះក្រហមបំពេញទីធ្លាសាលាបឋមសិក្សាពញាឮចំនួន៦០ម$^{៣}$ ការផ្តល់ឱ្យថ្នាំការពារជម្ងឺ៩មុខចំនួន៤៣០នាក់ ផ្តល់ថ្នាំពន្យាកំណើតសម្រាប់៩០នាក់ ការសាងសង់ប្រព័ន្ធលូបណ្តោះសម្រាប់ភូមិពពញាឮចំនួន១៩៥៨ ម៉ែត្រ។ ផ្អែកលើផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំ នឹងការប្រែប្រួលអាកាសធាតុរួមមានការផ្សព្វផ្សាយច្បាប់ភូមិបាលចំនួន៣លើក ការផ្សព្វផ្សាយច្បាប់បរិស្ថានចំនួន៣លើក និងវេទិកាជលផលជួបជាមួយសហគមន៍ចំនួន៣លើកនៅទូទាំងឃុំផងដែរ។ លើសពីនេះទៀតសោត ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅទូទាំងឃុំដែលរួមមាន ការផ្សព្វផ្សាយច្បាប់ចរាចរណ៍ ចំនួន៣លើក ការផ្សព្វផ្សាយផែនការប្រជាការពារចំនួន៣លើក វេទិកានគរបាលជួមជាមួយសហគមន៍ចំនួន៣លើកផងដែរ។

## ៦.២. ក្របខ័ណ្ឌផ្តល់សេវា

ការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋទូទាំងឃុំរួមមានដូចជា សំបុត្រកំណើតចំនួន៥០នាក់ សំបុត្របញ្ជាក់កំណើតគ្រោង៥០នាក់ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត និងកំណើតចំនួន៥០សន្លឹក ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចំនួន៧០គូរ សំបុត្រអាពាហ៍ពិពាហ៍ ចំនួន៤៥គូរ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចំនួន១០សន្លឹក សំបុត្រមរណភាព ចំនួន៦នាក់ សេចក្តីចម្លងសំបុត្រមរណភាព ចំនួន១០សន្លឹក លិខិតបញ្ជាក់ភាពនៅលីវ ចំនួន៧៥នាក់ លិខិតបញ្ជាក់ទីលំនៅ ចំនួន៥០នាក់ លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ ចំនួន៧៥នាក់

លិខិតបញ្ជាក់ពីប្រវត្តិដី ចំនួន៦នាក់ លិខិតបញ្ជាក់ទាយាទ លិខិតបញ្ជាក់កិរិយាមាយាទ ចំនួន៣នាក់ លិខិតបញ្ជាក់ពីប្រវត្តិរូបសង្ខេប ចំនួន៣នាក់ លិខិតបញ្ជាក់ទិញ-លក់សត្វពាហនៈ ចំនួន២នាក់ លិខិតបញ្ជាក់ពីបណ្តាញអគ្គិសនី លិខិតបញ្ជាក់ពីបណ្តាញទឹកស្អាត លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះសម្រាប់ចំនួន២នាក់ លិខិតបញ្ជាក់ជួលបន្ទប់ស្នាក់នៅ លិខិតបញ្ជាក់លើលិខិតស្នាម និងផ្សេងៗទៀត។

### ៦.៣. ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត

រាល់ការដាក់ចេញនូវលិខិតបទដ្ឋានគតិយុទ្ធគឺធ្វើឡើងដោយសាលាឃុំ ដែលក្នុងនោះរួមមាន ដីកាមានចំនួន១លេខ សេចក្តីសម្រេចចំនួន៥លេខ និងសេចក្តីជូនដំណឹងចំនួន៥លេខ។

# ជំពូកទី៣

# ការវិភាគលើលទ្ធផលនៃការស្រាវជ្រាវ

## ផ្នែកទី១៖ ការសិក្សាលើស្ថានភាពបច្ចុប្បន្នរបស់ឃុំពញាឮ

ចំពោះស្ថានភាពបច្ចុប្បន្នឃុំពញាឮ មានភាពខ្វះខាតដោយឃុំត្រូវចំណាយថវិកាមួយផ្នែកទៅលើការផ្គត់ផ្គង់គ្រូមត្តេយ្យសម្រាប់សាលាមត្តេយ្យសហគមន៍ ដោយគោលបំណងបង្កើតសាលាមត្តេយ្យសហគមន៍នេះគឺឃុំចង់សម្រួលដល់ជីវភាពប្រជាពលរដ្ឋ ដែលមានលក្ខណៈទីទាល់ក្រមានទីលំនៅដាច់ស្រយាល និងខ្វះខាតពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការឱ្យកូនកូនបានចូលសាលា ដូចនេះហើយការចំណាយផ្សេងៗត្រូវបានឧបត្ថម្ភទៅលើគ្រូនិងគ្រឿងបរិក្ខារផ្សេងៗសម្រាប់ក្មេងៗដូចជា តុ ក្តាខៀន កៅអី សៀវភៅ ប៊ិច។ ដោយឡែកចំពោះសម្ភារៈប្រើប្រាស់សម្រាប់សាលាឃុំក៏នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយទេដូចជាតុកៅអី កុំព្យូទ័រ ក្រដាសផ្សេងៗទៀត រាល់ការផ្គត់ផ្គង់ច្បាស់ណាថាឃុំមិនអាចផ្គត់ផ្គង់រ៉ាប់រងទាំងស្រុងបាននោះទេពីព្រោះថវិការឃុំទទួលបានចំនួនតិច ដូច្នេះឃុំមានតែស្នើសុំថវិកាខ្លះនិងជំនួយពីអង្គការក្រៅរដ្ឋាភិបាលនិងបណ្តាលក្រុមហ៊ុនផ្សេងៗដែលមកវិនិយោគ យ៉ាងណាមិញ ដោយមូលហេតុសាលាឃុំពញាឮស្ថិតនៅលើតំបន់វាលទំនាបទើបធ្វើឱ្យសាលាឃុំមានសភាពលិចទឹកនៅរដូវវស្សា ករណីមានភ្លៀងធ្លាក់លើសពីនេះទៅទៀតបញ្ហាចម្បងបំផុតដែលប្រឈម គឺជាបញ្ហាជាមួយនឹងប្រជាពលរដ្ឋដល់ហេតុថា ប្រជាពលរដ្ឋមានលក្ខណៈសកម្ម ដោយមិនសូវមានឆន្ទៈក្នុងការចូលរួមស្តាប់ការបណ្តុះបណ្តាលពីក្រុមប្រឹក្សាឃុំផ្ទាល់ដែលត្រូវចុះទៅដល់មូលដ្ឋាន ហេតុដូចនេះហើយវាធ្វើឱ្យមានកង្វះខាតផ្នែកអប់រំលើការយល់ដឹងរបស់ប្រជាពលរដ្ឋមូលដ្ឋាន នៅមានកម្រិតទាបសកម្មភាពនៃការអនុវត្ត ដោយផ្អែកតាមគោលនយោបាយ៩ ចំណុចរបស់រាជរដ្ឋាភិបាល និងការអនុវត្តច្បាប់ចរាចរណ៍ផ្សេងៗពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ។ យ៉ាងណាមិញ យើងក៏បានសិក្សាទៅលើវិស័យមួយចំនួនដែលឃុំកំពុងជួបប្រទះផងដែរ រួមមាន៖

### ១.១. ស្ថានភាពសេដ្ឋកិច្ចឆ្នាំ ២០២០នេះ

ប្រជាពលរដ្ឋនៅតែប្រកបរបរកសិកម្មជាចម្បងដដែលសម្រាប់ការអភិវឌ្ឍគ្រួសារ ដោយហេតុលក្ខណៈភូមិសាស្ត្រនៅតែបង្កភាពងាយស្រួលដល់ការបង្កបង្កើនផលស្រូវ ជាក់ស្តែងបងប្អូនបានអនុវត្តការបង្កបង្កើនផលរដូវប្រាំងបានជោគជ័យលើសផែនការ។ ទន្ទឹមនេះក៏មានមុខរបររួមផ្សំដូចជា សិកប្បកម្ម អាជីវកម្ម និងនេសាទជាដើម សម្រាប់ជួយសម្រួលបន្ថែមដល់ជីវភាពបងប្អូន។

#### ១.១.១. វិស័យកសិកម្ម

ការបង្កបង្កើនផលរដូវប្រាំងក្នុងឆ្នាំនេះ បងប្អូនត្រៀមលក្ខណៈបានល្អប្រសើរទោះបីជាទឹកពុំបានគ្របដណ្តប់ពេញលេញក៏ដោយ ក៏បងប្អូនបានការជួបឧបត្ថម្ភអំពីក្រុមការងារថ្នាក់ជាតិធ្វើការបូមទឹកបំពេញក្នុង

មេទឹក ធានាឱ្យបានបង្កបង្កើនផលស្រូវអនុវត្តសម្រេចបានលើសផែនការ។ ជាក់ស្តែងអនុវត្តបានសរុប ២៨៨ ហិកតា លើផ្ទៃដីគ្រោង២៨០ ហិកតា ស្មើ៩៧% មានបរិមាណផលសរុប៣.៥០ តោន/ហិកតា។

កត្តាដែលសម្រេចបានលទ្ធផលទាំងនេះ គឺតាមរយៈការផ្តល់ប្រេងពីក្រុមការងារថ្នាក់ជាតិចុះជួយឃុំ ការិយាល័យកសិកម្មជួយដល់បងប្អូនប្រជាកសិករ ធ្វើការបណ្តុះបណ្តាលពីបច្ចេកទេសការបណ្តុះបណ្តាលអំពីការប្រើប្រាស់ពូជដី ការធ្វើពិពិធកម្មលើដំណាំកសិកម្ម និងការដកពិសោធន៍លើការធ្វើស្រែបង្ហាញរួមផ្សំ និងការប្រើប្រាស់ឧបករណ៍ផលិតកម្មទំនើប ដូចជាត្រាក់ទ័រព្យួរ គោយន្ត ម៉ាស៊ីនស្ទូង-ច្រូត ម៉ាស៊ីនបោកជាដើម ធ្វើឱ្យការងារកសិកម្មកាន់តែទទួលបានលទ្ធផលខ្ពស់។ ប៉ុន្តែទោះបីជាដំណើរការវិស័យនេះ ទទួលបានផលល្អក្តី ឃុំក៏នៅតែជួបបញ្ហាប្រឈម និងជំនះដោយស្រាយមួយចំនួនសម្រាប់ធានាជីវភាពបងប្អូនប្រជាពលរដ្ឋ ជាអាទិ៍៖

- បញ្ហាសុខភាពពលកម្ម
- បញ្ហាទិន្នផល
- បញ្ហាគ្រោះធម្មជាតិ
- បញ្ហាសមត្ថភាពបច្ចេកទេស។

### ១.១.២. វិស័យធនធានទឹក និងធារាសាស្ត្រ

ឆ្នាំនេះទូទាំងភូមិ ប្រព័ន្ធធារាសាស្ត្រធានាបាននូវការគ្រប់គ្រងធនធានទឹកគ្រប់គ្រាន់សម្រាប់ការងារបង្កបង្កើនផលស្រូវរដូវប្រាំងពិសេសអាចធានាបានលើផ្ទៃដីមួយចំនួន ដែលធ្លាប់ជួបប្រទះគ្រោះរាំងស្ងួតពេលរដូវដាំដុះដូចជាភូមិពញាព្ទ ជាដើម។ តែទន្ទឹមនេះ ការិយាល័យជំនាញស្រុកគ្រប់ភូមិក៏ត្រូវយកចិត្តទុកដាក់បន្ថែមទៀតតាមរយៈការប្រើប្រាស់ សម្រាប់ជួសជុសកែលម្អប្រព័ន្ធធារាសាស្ត្រមួយចំនួនដែលខូចខាត ដើម្បីធានាគ្រប់គ្រងថែរក្សាធនធានទឹកបានគ្រប់គ្រាន់តាមតម្រូវការស្រោចស្រពដែលមាន ការជួសជុលទំនប់និងសណ្តរទំនប់។

### ១.១.៣. វិស័យសាធារណការ និងដឹកជញ្ជូន

ថ្វីត្បិតតែទឹកជំនន់ឆ្នាំ២០២០ ពុំបង្កឱ្យមានការខូចខាតដល់ប្រព័ន្ធគមនាគមន៍ក៏ពិតមែនក៏នៅមានប្រព័ន្ធផ្លូវមួយចំនួនរងការខូចខាត ដោយសារខ្វះការគ្រប់គ្រង ជួសជុល ថែរក្សា និងទុកឱ្យបណ្តាពួកអាជីវកម្មប្រើរថយន្តធុនធ្ងន់ហួសកម្រិតឆ្លងកាត់ ធ្វើឱ្យប៉ះពាល់ដល់ជីវិភាពនិងការរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងត្រូវយកចិត្តទុកដាក់ជួសជុលកែលម្អឡើងវិញជាចាំបាច់។ កត្តាទាំងនេះជាបុព្វបទដែលឃុំត្រូវយកចិត្តទុកដាក់ និងលើកកម្ពស់ការដឹកនាំ ណែនាំដល់មូលដ្ឋាន និងប្រជាពលរដ្ឋឱ្យកាន់តែស៊ីជម្រៅថែមទៀត។

### ១.១.៤. វិស័យឧស្សាហកម្ម សិប្បកម្ម

កំណើនវិស័យឧស្សាហកម្ម បានបង្កើនយ៉ាងខ្លាំងដល់មុខរបរយុវជនយុវនារីធ្វើឱ្យចំនួនកម្មករកើនដល់រាប់រយនាក់ជាហេតុបង្កដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងទូទាំងឃុំ កាន់តែមានភាពល្អប្រសើរ។

ជាក់ស្តែងទូទាំងឃុំមានផ្នែកកិច្ចការសិប្បកម្មនិងរោងចក្រផលិតក្រដាសអនាម័យនិងកន្លែងផលិត ទឹកពិសាបរិសុទ្ធ(ដប) ផលិតទឹកស្អាត។

**១.១.៥. វិស័យធនធានរ៉ែ និងថាមពល**

ទូទាំងឃុំ បណ្តាញសេវាអគ្គីសនីនិងទឹកស្អាតបានចែកចាយដល់ភូមិទាំង៣ហើយឃុំបានទំនាក់ទំនងជាមួយម្ចាស់អាជីវកម្មធ្វើយ៉ាងណាបញ្ចុះតម្លៃឱ្យបានសមរម្យជូនដល់ប្រជាពលរដ្ឋក្នុងឃុំពញាព្ន។

**១.១.៦. វិស័យជលផល**

ឃុំពញាព្ន ជាឃុំមួយដែលស្ថិតក្នុងតំបន់វាលទំនាប់ទន្លេសាប និងសម្បូរទៅដោយសម្បត្តិធម្មជាតិមច្ឆាជាតិ នៅក្នុងតំបន់វាលទំនាបទន្លេសាបជាដើម បង្កលក្ខណៈឱ្យប្រជាពលរដ្ឋប្រកបរបរនេសាទសម្រាប់ដោះស្រាយជីវភាពតាមគ្រួសារ។ ប៉ុន្តែក៏នៅតែមានបទល្មើសបង្កឡើងដោយឈ្មួញនេសាទខ្លះលួចប្រើឧបករណ៍នេសាទខុសច្បាប់ និងគោរពរដូវកាល(បើកនិងបិទ) ធ្វើឱ្យប៉ះពាល់ដល់ផលនេសាទដែលនោះជាបញ្ហាប្រឈមដែលឃុំត្រូវយកចិត្តទុកដាក់ធ្វើការងារមួយចំនួនដូចជា៖

- បញ្ហាផ្សព្វផ្សាយពីកិច្ចការការពារសម្បត្តិធម្មជាតិ
- លុបបំបាត់ការប្រើប្រាស់ឧបករណ៍ខុសច្បាប់
- ការបំផ្លិតបំផ្លាញព្រៃ ជម្រកត្រីពង កូន។

**១.១.៧. វិស័យពាណិជ្ជកម្ម សេវាកម្ម**

ទូទាំងភូមិពុំមានទីផ្សារ ឬចំណតសមស្របសម្រាប់ការធ្វើពាណិជ្ជកម្មដូចជាការដោះដូរកសិផល ឬមុខទំនិញផ្សេងៗ ដែលបង្កលក្ខណៈងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋទេ។ តែបើបងប្អូនប្រជាពលរដ្ឋចង់ដោះដូរមានតែផ្សារព្រែកព្នៅ ឬឃឿត្រីព្រែកព្នៅសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារប៉ុណ្ណោះ។

**១.២. ស្ថានភាពសង្គមកិច្ច**

តាមរយៈការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី៤ (២០២០-២០២២) និងការអនុវត្តផ្ទាល់អំពីគោលនយោបាយវិមជ្ឈការវិសហមជ្ឈការនៅថ្នាក់ឃុំក្នុងបណ្តាឆ្នាំកន្លងមក សកម្មភាពសង្គមកិច្ចកាន់តែមានការប្រែប្រួលវិវត្តឈានឡើងពិសេសប្រជាពលរដ្ឋមូលដ្ឋានមានការប្រែប្រួលទាំងសមត្ថភាព បច្ចេកទេស ចំណេះដឹង ធ្វើឱ្យស្ថានភាពជីវភាពសុខភាពកាន់តែធានា និងផ្តើមពីបញ្ហាខាងលើធ្វើឱ្យឃុំពញាព្នកាន់តែរក្សាបាននូវសុខសន្តិភាព សុវត្ថិភាពដោយរស់នៅប្រកបដោយភាពសុខដុមរមនា។

**១.២.១. ការងារអប់រំ**

វិស័យអប់រំកាន់តែមានភាពរីកចម្រើនជាលំដាប់ជាក់ស្តែង ទូទាំងឃុំមានអនុវិទ្យាល័យ១ កន្លែង(ក្នុងនោះមានមត្តេយ្យរដ្ឋនិងមត្តេយ្យសហគមន៍ ៥បន្ទប់) ដែលជាហេតុបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ

ក្នុងការបញ្ជូនយុវជន យុវនារីកុមារាកុមារីបានចូលរៀនគ្រប់ៗគ្នា។ ជាក់ស្តែងលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមឆ្នាំសិក្សា២០១៩-២០២០ មានបេក្ខជនចំនួន ៣៩នាក់ ស្រី ២៥នាក់ បានប្រឡងជាប់ ៣៧ នាក់ ស្មើ ៩៤.៨៧% (និទ្ទេស B=0 នាក់ C=៥ នាក់ D=៧នាក់ និង E=២៥នាក់)។ តែទន្ទឹមនេះ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀតដូចជា បញ្ហាសិស្សបោះបង់ការសិក្សា បញ្ហាក្រមសីលធម៌យុវវ័យ ដែលរដ្ឋបាលគ្រប់ថ្នាក់ ត្រូវប្រឈមដោះស្រាយ។

**១.២.២. ការងារសុខាភិបាល**

ការអប់រំសុខភាព ជាបញ្ហាគន្លឹះក្នុងការរួមចំណែកអនុវត្តជោគជ័យនូវ គោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល និងកាត់បន្ថយបាននូវហានីភ័យ ដែលកើតឡើងដោយហេតុអំពីធម្មជាតិឬការរីករាលដាលនៃជម្ងឺឆ្លងផ្សេងៗ។ កន្លងមកឃុំបានយកចិត្តទុកដាក់ជាចម្បងលើបញ្ហាការពារសុខភាពកុមារបញ្ហាស្ត្រីជាមាតា និងការទប់ស្កាត់ជម្ងឺឆ្លងផ្សេងៗ។

តាមរយៈគោលនយោបាយដឹកនាំរបស់ថ្នាក់ជាតិនោះ ឃុំក៏បានបង្កើតឡើងនូវគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ(គ.ក.ន.ក) បានបង្កលក្ខណៈងាយស្រួលដល់កាងារសុខភាពអនាម័យកាន់តែបានល្អប្រសើរ។ តែទន្ទឹមនេះ ក៏នៅមានបញ្ហាប្រឈមដែលឃុំត្រូវដោះស្រាយជាអាទិ៍ បញ្ហាខ្វះមធ្យោបាយសម្ភារៈបច្ចេកទេស និងសមត្ថភាពឆ្មបជនបទ។

**១.២.៣. ការងារវប្បធម៌ ប្រពៃណី**

ការប្រែប្រួលនៃចរន្តវប្បធម៌ អរិយធម៌សកលលោកបានជះឥទ្ធិពលយ៉ាងខ្លាំងចូលមកដល់សង្គមកម្ពុជាក្នុងដំណាក់កាលបច្ចុប្បន្ន ពិសេសការវិវត្តលើលទ្ធិមនោគមវិជ្ជា ទំនៀមទំម្លាប់ ប្រពៃណី ជំនឿ ហើយបញ្ហានេះធ្វើឱ្យថមថយនូវការគោរពសក្ការៈរបស់ប្រជាជនយើង។ ទាំងនេះជាកត្តាចាំបាច់ដែលឃុំត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់ និងការទប់ស្កាត់ការហូរចូល នូវវប្បធម៌ដែលប៉ះពាល់ដល់ប្រពៃណីដ៏ល្អរបស់យើង។

ចំពោះមុខឃុំនៅជួបបញ្ហាខ្លះដូចជា ការរៀបចំកែលម្អសោភ័ណនិងការកែលម្អនូវ បាតុភាពខុសឆ្គងដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណី ដូចជាក្នុងពិធីទំនៀមទម្លាប់ផ្សេងៗ បុណ្យទានអាពាហ៍ពិពាហ៍។ល។

**១.២.៤. ការងារធម្មការ និងសាសនា**

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញមាត្រា៤ នៃបាវចនាជាតិខ្មែរ គឺ ជាតិ សាសនា ព្រះមហាក្សត្រ។ ក្នុងទសវត្សរ៍ចុងក្រោយនេះ វិស័យព្រះពុទ្ធសាសនាកាន់តែជះឥទ្ធិពលយ៉ាងខ្លាំងទាំងលើឆាកជាតិ ក៏ដូចជាអន្តរជាតិ ដោយហេតុក្រសួងធម្មការ និងកិច្ចការសាសនា និងគណៈសង្ឃនាយកបានសហការបង្កើតឱ្យមានការបណ្តុះបណ្តាលប្រទេសកាន់សាសនាផ្សេងៗ ជាក់ស្តែងឃុំពញាឮមានវត្តចំនួន២ វត្ត។

ចំពោះមុខ ឃុំក៏ត្រូវមានការយកចិត្តទុកដាក់ដល់បាតុភាព ឬអធិករណ៍ផ្សេងៗ ដែលកើតមានក្នុងវត្ត រវាងគណៈកម្មការ អាចារ្យ និងអាចារ្យ រវាងព្រះសង្ឃ និងព្រះសង្ឃដែលត្រូវសម្រួលដោះស្រាយ។

## ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ឆ្នាំ២០១៩ គោលនយោបាយនៃការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ និង បរិស្ថានកាន់តែត្រូវបានពង្រឹងជាក់ស្តែងឃុំបានទទួលពាក្យបណ្តឹងស្តីពីករណីវិវាទដីធ្លីចំនួន១ បណ្តឹង ហើយឃុំមិនអាចបញ្ចប់បាន។ ទន្ទឹមនេះ រដ្ឋបាលឃុំនៅតែយកចិត្តទុកដាក់ណែនាំដឹកនាំនិងជំរុញការអនុវត្តគោលនយោបាយដីធ្លីឱ្យកាន់តែស៊ីជម្រៅដល់មូលដ្ឋានពិសេសការរួមចំណែក ថែរក្សាធនធានធម្មជាតិ បរិស្ថាន ការដាំដើមឈើ និងទប់ស្កាត់រាល់បាតុភាពទន្ទ្រានកាប់បំផ្លាញព្រៃលិចទឹក ការបញ្ចេញចោលនូវសំណល់រឹងរាវបែបអនាធិបតេយ្យនិងការប្រើប្រាស់សារធាតុបំពុលជាដើម។

### ១.៣.១. ការគ្រប់គ្រងដីធ្លី

បច្ចុប្បន្នការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីរបស់ប្រជាពលរដ្ឋមានការប្រែប្រួលពិសេសការផ្លាស់ប្តូរបដិរូបកម្ម រូបភាពដី ពីដីស្រែទៅជាដីស្រះ ដីសំណង់រោងចក្រ សិប្បកម្មតាមការវិវត្តប្រែប្រួលនៃចរន្តសេដ្ឋកិច្ចទីផ្សារ។ ផ្ទៃដីមួយចំនួនទៀតត្រូវបានកែប្រែទៅតាមលក្ខណៈពិសេសនៃភូមិសាស្ត្រ។ ដោយឡែកការគ្រប់គ្រងពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយបច្ចុប្បន្នរដ្ឋបាលឃុំ កំពុងដំណើរការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋឆ្លើយប្រកាសរៀបចំជាប្រព័ន្ធទៅតាមគោលការណ៍ច្បាប់។

ចំពោះមុខ ឃុំនឹងប្រឈមនូវបញ្ហាមួយចំនួនទៀតដែលត្រូវដោះស្រាយ មានជាអាទិ៍៖

- បញ្ហាទំនាស់ដីធ្លីដែលពុំទាន់បានដោះស្រាយចប់
- ការរៀបចំគ្រប់គ្រងជាប្រព័ន្ធ
- ការផ្តល់បណ្ណកម្មសិទ្ធិ
- ការបោះបង្គោលប្រចពីរិភាគ
- ការរៀបចំគំនូសព្រាង និងកំណត់តំបន់ជាដើម។

### ១.៣.២. ការងារបរិស្ថាន

កម្មវិធីជាតិបានកំណត់ថាការអភិវឌ្ឍជាកត្តាចម្បង ហើយរាល់ការអភិវឌ្ឍលើគ្រប់ វិស័យនៅមូលដ្ឋានត្រូវតែធានាដល់និរន្តភាពបរិស្ថាន។ បច្ចុប្បន្ន គ្រប់មូលដ្ឋានត្រូវបង្កើនការគ្រប់គ្រងសំណល់រឹង សំរាម នៅតាមបណ្តោយផ្លូវជាតិលេខ៥ មានលក្ខណៈមិនល្អប្រសើរ ធ្វើឱ្យបាត់បង់សោភ័ណភាពបរិស្ថាន។ ដោយនៅតែបោះចោលរាយប៉ាយគ្មានសណ្តាប់ធ្នាប់។ បញ្ហានេះរដ្ឋបាលឃុំ ក៏ដូចជាភូមិ ត្រូវលើកកម្ពស់ការផ្សព្វផ្សាយ រក្សាឱ្យបាននូវសោភ័ណភាពបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

## ១.៤. ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ឃុំពញាឮបានទទួលនូវឥទ្ធិពលខ្យល់មូសុងនិរតី ឆ្នាំនេះអាកាសធាតុធម្មជាតិមានការប្រែប្រួលមិនទៀងទាត់ ដែលមិនអាចធ្វើការប៉ាន់ប្រមាណបានជាមុន និងមានការរាំងស្ងួតរយៈពេលយូរនៅក្នុងឆមាសទី១ ហើយតំបន់ខ្លះមានភ្លៀងច្រើន រីឯខ្លះទៀតភ្លៀងតិច មិនស្របនឹងតម្រូវការនៃការបង្កបង្កើនផល។ ប៉ុន្តែដើម្បីធានាបាននូវស្ថានការណ៍នៃគ្រោះមហន្តរាយធម្មជាតិ ដែលកើតឡើងជាយថាហេតុនោះ ឃុំក៏បានកសាងឡើងនូវគម្រោងផែនការជាក់លាក់មួយសម្រាប់ជាបុព្វបទពេលមានបាតុភូតនេះកើតឡើង។ ជាងនេះទៅទៀតឃុំបានលើកកម្ពស់ការងារសេវាសង្គមតាមរយៈសមត្ថកិច្ចមូលដ្ឋាន និងធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយរក្សាបាននូវស្ថេរភាពល្អប្រសើរ។

### ១.៤.១. គ្រោះមហន្តរាយ

ទឹកជំនន់ឆ្នាំ២០២០ មិនមានកម្រិតធ្ងន់ធ្ងរដែលបង្កជាមហន្តរាយដល់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ឬភោគទ្រព្យរបស់ប្រជាពលរដ្ឋនោះទេក៏ប៉ុន្តែឃុំនៅតែជួបប្រទះបញ្ហាខ្លះៗ ដែលយើងបាននិងកំពុងដោះស្រាយតាមរយៈគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ សាខាកាកបាទក្រហមកម្ពុជា ដូចជាករណីលង់ទឹកខ្យល់ព្យុះជាងដើមត្រូវបានម្ចាស់ការដោះស្រាយបានទាំងស្រុង។

តែចំពោះមុខឃុំនៅតែត្រៀមលក្ខណៈ និងធានាដោះស្រាយបន្ទាន់នៅពេលដែលមានករណីចាំបាច់កើតមាន។

### ១.៤.២. ការប្រែប្រួលអាកាសធាតុ

ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឃុំពញាឮក្នុងដំណាក់កាលបច្ចុប្បន្នមួយចំនួនធំ ត្រូវទទួលរងនូវឥទ្ធិពលអាកាសធាតុដូចជាតម្រូវការទឹកភ្លៀង មធ្យោបាយទឹក សម្រាប់ការបង្កបង្កើនផល។ ម្យ៉ាងវិញទៀត កត្តាធម្មជាតិក៏បណ្តាលផលប៉ះពាល់ដល់ដំណើរការបង្កបង្កើនផល និងលំនៅឋានរបស់ប្រជាពលរដ្ឋជាច្រើនផងដែរ ដូចជាបញ្ហាទឹកជំនន់ បញ្ហាកំណើនកម្តៅ បញ្ហាគ្រោះរាំងស្ងួត សុទ្ធតែជាបញ្ហាដែលជះឥទ្ធិពលដល់ជីវភាព សុខភាពរបស់ប្រជាពលរដ្ឋផងដែរ ហើយទាំងនេះជាបញ្ហាប្រឈមដែលឃុំត្រូវយល់ដឹងជ្រួតជ្រាប និងត្រូវមានគម្រោងផែនការវិធានការការពារ ទប់ស្កាត់ ពិសេសការរួមចំណែកថែរក្សាការពារបរិស្ថានធម្មជាតិឱ្យស្របនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

## ១.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

គោលនយោបាយថ្មីក្នុងដំណាក់កាលបច្ចុប្បន្ន ស្តីពីការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈតាមរយៈកម្មវិធីជាតិនិងការអនុវត្តវិធីទាំង ៦ ចាំបាច់ឃុំត្រូវអនុវត្តតាមនិតិវិធីនៃការគ្រប់គ្រងរដ្ឋបាលដោយផ្សារភ្ជាប់រចនាសម្ព័ន្ធដែលមានស្រាប់តាំងពីឃុំរហូតដល់ភូមិធ្វើជាយន្តការ នោះទើបជាគោលដៅនៃការគ្រប់គ្រងដឹងនាំក្នុងដែនសមត្ថកិច្ច ការអភិវឌ្ឍ ការការពារនូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជូនមហាជន ប្រជាជនរក្សាបាន។

គោលដៅចម្បងក្នុងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពនៅឃុំពញាឮ[54] គឺធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិឃុំរស់នៅប្រកបដោយសន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ដោយៈ

- គ្មានសកម្មភាពលួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការផលិតការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើចោរកម្ម ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ[55]
- បង្ក្រាប និងទប់ស្កាត់មិនឱ្យមានក្មេងទំនើង[56]
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់ និងការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- មានវិធានការទប់ស្កាត់គ្រប់គ្រងនិងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់។

## ផ្នែកទី២ៈ ចំណុចខ្លាំង និង ចំណុចខ្សោយ

### កថាខណ្ឌទី១ ចំណុចខ្លាំង

ជាក់ស្តែងយោងតាមការចុះអង្កេត និងសិក្សាដោយផ្ទាល់នៅឃុំពញាឮ យើងបានសង្កេតមើលឃើញថាអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាលនៅក្នុងការបំពេញការងារផ្តល់សេវារដ្ឋបាលជូនដល់ប្រជាពលរដ្ឋរបស់ខ្លួនបានដូចខាងក្រោមៈ

ឃុំពញាឮបានខិតខំប្រឹងប្រែងយ៉ាងសកម្មនៅក្នុងការបំពេញការងាររបស់ខ្លួនក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋសេវាជាច្រើនត្រូវបានផ្តល់ជូនដល់ប្រជាពលរដ្ឋតាមតម្រូវការជាក់ស្តែងជាហូរហែរដែលគ្មានទទួល ពាក្យបណ្តឹងពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្តល់សេវាឡើយ។

សមិទ្ធផលដែលសម្រេចបានជោគជ័យភាគច្រើនផងដែរទៅលើៈ

- វិស័យគមនាគមន៍ ការអភិវឌ្ឍន៍ ទៅលើផ្លូវលំមកជាផ្លូវប៉េតុងជាច្រើនខ្សែនៅគ្រប់ភូមិដែលតំណភ្ជាប់ឆ្លងការពីភូមិមួយទៅភូមិមួយ ផ្លូវរួមភូមិ និងផ្លូវរួមឃុំ
- ការកសាងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំ ដូចជាអភិវឌ្ឍន៍សាលាមត្តេយ្យសហគមន៍

[54] ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ'ភូមិ-ឃុំមានសុវត្ថិភាព'

[55] ផែនការសកម្មភាពលេខ០២៣ ផ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈឆ្នាំ២០០៥របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ

[56] សារាចរលេខ០៤ស.រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ០២១ស.ណ.ន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ០៥០ផ.ក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩របស់អគ្គស្នងការនគរបាលជាតិ

- ការកសាងប្រព័ន្ធទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រុមហ៊ុនឯកជនជាច្រើនដើម្បីមកវិនិយោគនៅក្នុង និងបានផ្តល់ឳកាសការងារដល់ប្រជាពលរដ្ឋក្នុងឃុំ ហើយបានធ្វើឱ្យលក្ខណៈជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំពញាឮមានការរីកចម្រើនជាងមុន។

**ដោយឡែកចំពោះទីតាំង៖** សាលាឃុំពញាឮស្ថិតនៅលើដងផ្លូវជាតិលេខ៥ មានបរិវេណធំទូលាយ មានផាសុខភាពនិងរួមមានប៉ុស្តិ៍នគរបាលនៅក្នុងនោះផងដែរ ដែលបង្កភាពងាយស្រួលជូនប្រជាពលរដ្ឋ និងអាចរកឃើញ និងទទួលបានការផ្តល់សេវាយ៉ាងល្អ និងទាន់ពេលវេលា។

**-ចំពោះមន្ត្រី ឬបុគ្គលិក៖** នៅពេលដែលយើងខ្ញុំចុះទៅស្រាវជ្រាវឯកសារដោយផ្ទាល់នៅ ឃុំពញាឮ លោកមេឃុំមានភាពរីករាយក្នុងការស្វាគមន៍ប្រកបដោយភាពកក់ក្តៅ និងការគោរពរាប់អាន ក៏ដូចជាមានការសហការយ៉ាងល្អក្នុងការផ្តល់នូវអ្វីដែលយើងខ្ញុំចង់បានដែលរួមមានទិន្នន័យ ឯកសារពាក់ព័ន្ធ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងកិច្ចការស្រាវជ្រាវមួយនេះ ដើម្បីផ្តល់ជាទុនក្នុងការចងក្រងឯកសារសិក្សាស្រាវជ្រាវនេះបានយ៉ាងរលូន។ ម្យ៉ាងវិញទៀតបុគ្គលិកផ្សេងៗទៀត ក៏មានភាពរួសរាយរាក់ទាក់ មានក្រមសីលធម៌ និងផ្តល់ការសហការដូចគ្នា។ ដោយឡែកនៅក្នុងម៉ោងបំពេញការងារ បុគ្គលិកទាំងអស់ស្ថិតនៅក្នុងកន្លែងបំពេញការងារយ៉ាងយកចិត្តទុកដាក់ និងមានការពាក់នូវឯកសណ្ឋានត្រឹមត្រូវ និងសមរម្យ។

**-ចំពោះវិវាទទាក់ទងនឹងការផ្តល់សេវា៖** នៅក្នុងការបំពេញការងាររបស់ខ្លួន ឃុំគ្មានវិវាទណាមួយកើតឡើងទាក់ទងនឹងការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋនោះទេ។ ម្យ៉ាងវិញទៀតមិនមានករណីបណ្តឹងណាមួយទាក់ទងនឹងការផ្តល់សេវា ដែលកើតចេញពីភាពមិនសុខចិត្តរបស់ប្រជាពលរដ្ឋកើតឡើងឡើយ។

**កថាខណ្ឌទី២ ចំណុចខ្សោយ**

ក្រៅពីចំណុចខ្លាំងរបស់ឃុំពញាឮ យើងក៏បានសង្កេតឃើញពីចំណុចខ្សោយ និងចំណុចអសកម្មមួយចំនួនផងដែរនៅក្នុងសកម្មភាពការងាររបស់ខ្លួន៖

**-កត្តាចំណេះដឹង និងសមត្ថភាព៖** ចំណេះដឹងរបស់មន្ត្រី និងបុគ្គលិកនៅមានកម្រិតនៅឡើយទាក់ទងទៅនឹងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល។ ឧទាហរណ៍ដូចជា ... តួយ៉ាងនៅពេលយើងខ្ញុំចុះទៅធ្វើសិក្សាស្រាវជ្រាវឯកសារផ្ទាល់នៅសាលាឃុំពញាឮ ដោយមានការសាកសួរលោកមេឃុំផ្ទាល់ ពាក់ព័ន្ធនឹងបញ្ហាមួយចំនួនរបស់ឃុំ តែលោកមេឃុំមិនបានឆ្លើយឱ្យបានក្បោះក្បាយ និងមានភាពស្រពិចស្រពិល។

**-ការចងក្រង និងការរក្សាទុកឯកសារ៖** នៅមានការខ្វះខាត នៅក្នុងការចងក្រងជាឯកសារ ជារបាយការណ៍ ឬការចងក្រងមានលទ្ធភាពស្ហួចស្តើងនៅឡើយ។ នៅពេលដែលយើងខ្ញុំធ្វើការចុះស្រាវជ្រាវ និងស្នើសុំ

ព័ត៌មាន និងឯកសារផ្សេងៗពាក់ព័ន្ធនឹងសាលាឃុំនេះ គឺការផ្តល់ព័ត៌មាន និងឯកសារទាំងនោះមានភាពខ្វះខាតច្រើន។ ចំណែកឯការរក្សាទុកឯកសារនៅមិនទាន់មានការគ្រប់គ្រងបានល្អប្រសើរនៅឡើយទេ។

-**គ្រឿងសម្ភារបរិក្ខារ** នៅមានភាពខ្វះខាតនៅឡើយដូចជាតុ កៅអី កុំព្យូទ័រសម្រាប់បញ្ចូលទិន្នន័យ និងឯកសារផ្សេងៗសម្រាប់ដំណើរកិច្ចការរដ្ឋបាល។

ថ្វីត្បិតតែមានបញ្ហាផ្សេងៗកើតឡើងជះឥទ្ធិពលដល់ឃុំពញាឮក្តី តែឃុំមានតួនាទី និងទំនួលខុសត្រូវធ្វើយ៉ាងណាជួយសម្របសម្រួលដល់ប្រជាពលរដ្ឋ ហើយយ៉ាងណាមិញ រាល់ដំណោះស្រាយរបស់ឃុំពញាឮបានជួយដោះស្រាយជូនប្រជាពលរដ្ឋដោយមានលក្ខណៈល្អប្រសើរជាក់ស្តែងដូចជាបញ្ហាវិវាទក្នុងគ្រួសារ។ ឃុំ បានដោះស្រាយ និងកោះហៅភាគីទាំងសងខាងមកសាលាឃុំដើម្បីដោះស្រាយបញ្ហានេះ។ ការសម្របសម្រួលចំនួនក្រុមប្រឹក្សាឃុំសម្របសម្រួលដោយគតិយុត្ត គឺជាវិធានការពារទុកជាមុនដ៏សមស្របបំផុតដែលឃុំប្រកាន់យកដើម្បីការពារទំនាស់កុំ ឱ្យរីករាលដាលកាន់តែខ្លាំងឡើង និងទប់ស្កាត់ក្រុមក្មេងពាលការប្រើប្រាស់គ្រឿងញៀន និងល្បែងស៊ីសងឱ្យមានការចុះថយជាបណ្តើរៗ។

ដោយឡែកចំពោះការផ្តល់សេវាសាធារណៈវិញ គឺមានភាពល្អប្រសើរ រាល់លិខិតបទដ្ឋានគតិយុត្ត ដូចជា ការធ្វើអាត្រានុកូលដ្ឋាន ការធ្វើសៀវភៅគ្រួសារ ការធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ គឺឃុំយកទៅប្រគល់ឱ្យប្រជាពលរដ្ឋដោយផ្ទាល់។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកដូចយើងបានដឹងរួចមកហើយថា ការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់គឺជាការគ្រប់គ្រងថ្នាក់ក្រោមបង្អស់នៅក្នុងរដ្ឋបាលរបស់ជាតិយើង ហើយមិនតែប៉ុណ្ណោះ គឺជារដ្ឋបាលមួយដែលស្ថិតនៅជាប់ផ្ទាល់របស់ប្រជាពលរដ្ឋហើយគឺជាការអនុវត្តប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ។ លើសពីនេះទៅទៀត ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក៏ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រទេសជាតិឱ្យបានកាន់តែរីកចម្រើនថែមទៀត និងមានស្ថេរភាពផងដែរ ដោយស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូលត្រង់មាត្រា៥១ថ្មី ដែលបានចែងថា ប្រទេសកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្សដែលតំណាងរាស្ត្រត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ។

ការអនុវត្តប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់មានមូលហេតុនិងសារៈសំខាន់គឺធ្វើឱ្យឃុំនីមួយៗ មានស្វ័យភាពអាចម្ចាស់ការគ្រប់គ្រងដោះស្រាយផ្ទាល់រាល់កិច្ចការនៅមូលដ្ឋានបានយ៉ាងឆាប់រហ័សទាន់ពេលវេលា ចំទិសដៅឬសគល់នៃបញ្ហា និងអាចប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលរបស់ខ្លួន ដោយគួបផ្សំជាមួយការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនឱ្យបានកាន់តែរីកចម្រើនប្រសើរឡើង។ យ៉ាងណាមិញ នៅឃុំពញាឮ ប្រជាពលរដ្ឋទទួលបាននូវ សិទ្ធិយ៉ាងទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ទាក់ទងទៅនឹងការអនុវត្តរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាពលរដ្ឋបានចូលរួមផ្តល់ជាមតិយោបល់ រិះគន់ក្នុងន័យស្ថាបនា ស្នើឡើងនូវសំណូមពរផ្សេងៗទៅលើកិច្ចការជាច្រើនដែលពាក់ព័ន្ធទៅផលប្រយោជន៍របស់ខ្លួនឯងផ្ទាល់។ រួមជាមួយការចូលរួមរបស់ប្រជាពលរដ្ឋ មន្ត្រី និងក្រុមប្រឹក្សាឃុំ ក៏បាននឹងខិតខំប្រឹងប្រែងបំពេញកិច្ចការងាររបស់ខ្លួនយ៉ាងសស្រាក់សស្រាំ និងយកចិត្តទុកដាក់បំផុតណាស់ដែរ ដែលធ្វើឱ្យកើនឡើងនូវសមិទ្ធផលនានាដូចជា ផ្លូវថ្នល់ សាលារៀន ដោយប្រើប្រាស់មូលនិធិឃុំ រួមទាំងថវិកាបដិភាគរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ រាល់ស្នាដៃទាំងនេះ គឺសុទ្ធដោយសារមានការចូលរួមសហការពីបណ្តាប្រជាពលរដ្ឋជាធំនៅក្នុងឃុំទាំងមូលនេះផងដែរ។ លើសពីនេះទៅទៀត វិធានការចម្បងសម្រាប់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់គឺការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ តួយ៉ាងដូចជា ឃុំចុះទៅមូលដ្ឋានចុះជួយឧបត្ថម្ភដែលរួមមានជាថវិកា គ្រឿងបរិក្ខារសម្រាប់បរិភោគ ដល់ជនរងគ្រោះដោយសារគ្រោះថ្នាក់ធម្មជាតិផ្សេងៗ ដូចជាទឹកជំនន់ ភ្លើងឆេះផ្ទះជាដើម និងជនដែលមានសភាពទីទាល់ក្រជាដើម។ នេះគឺជាសកម្មភាពដ៏ល្អប្រសើរបំផុត ដែលជាកត្តាជំរុញកិច្ចអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចយើង ដែលបានរងការខូចខាតខ្ទេចខ្ទាំដោយសារសង្គ្រាមដែលអូសបន្លាយអស់ជាច្រើនទសវត្សរ៍មកហើយ ហើយវាជាគំរូល្អមួយដែលបានបង្ហាញដល់មនុស្សជាតិគ្រប់រូបឱ្យមានវប្បធម៌ល្អនៅក្នុងការចែករំលែក។

ដោយឡែកបើទោះបីជាការគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់ មានការអនុវត្តតាមប្រព័ន្ធវិមជ្ឈការ បានល្អប្រសើរក៏ពិតមែនតែក៏នៅមានចំណុចខ្វះចន្លោះផងដែរដូចជា ប្រព័ន្ធបច្ចេកទេសនៅមានកម្រិត ខ្វះប្រភពធនធានហិរញ្ញវត្ថុ ដែលជាកត្តាជះឥទ្ធពលដល់អភិវឌ្ឍន៍ឃុំ សមាសភាពមន្ត្រីរាជការនៅមិនទាន់មានសមស្របទៅតាមទំហំឃុំ និងសមាមាត្រទៅនឹងចំនួនប្រជាជនផងដែរ។

# អនុសាសន៍

បើតាមការស្រាវជ្រាវ និងការជួបប្រទះជាក់ស្ដែងចំពោះការអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ យើងខ្ញុំយល់ថាមិនទាន់មានភាពល្អប្រសើរនៅឡើយទេដោយសារតែនៅមានការខ្វះចន្លោះប្រហោងនៅឡើយទេ ដែល រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ និងបំពេញបន្ថែមនូវចន្លោះខ្វះខាតទាំងនោះដូចជា៖

- រាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ គួរតែពិនិត្យពិចារណាផ្ដល់នូវមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវបន្ថែមទៀតទៅដល់រដ្ឋបាលឃុំពញាឮ ដោយភ្ជាប់ជាមួយធនធានហិរញ្ញវត្ថុដើម្បីឱ្យឃុំមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការប្រើប្រាស់ក្នុងការអនុវត្តការងារ និងការអភិវឌ្ឍលើផ្នែកផ្សេងៗ និងរួមមានការបើកវគ្គបណ្ដុះបណ្ដាលមន្ត្រីរាជការថ្នាក់ឃុំសង្កាត់ឱ្យបានច្រើនដង ដើម្បីបង្កើនសមត្ថភាពមន្ត្រីរាជការឱ្យបានកាន់តែខ្លាំង ជាពិសេសលើផ្នែកបច្ចេកទេស។
- រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគួរតែត្រួតពិនិត្យលទ្ធភាពនៅក្នុងការបន្ថែមនូវកញ្ចប់ថវិកាឱ្យបានសមស្របដល់ឃុំពញាឮ ជាពិសេសនោះគឺមូលដ្ឋានដែលក្រីក្រ និងស្ថិតនៅក្នុងតំបន់ដាច់ស្រយាល ព្រោះដើម្បីបានអភិវឌ្ឍន៍នៅមូលដ្ឋានឱ្យបានយ៉ាងឆាប់រហ័ស និងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែច្រើន។
- រាជរដ្ឋាភិបាលគួរតែផ្ដល់នូវសម្ភារៈគ្រឿងបរិក្ខារមួយចំនួន សម្រាប់ប្រើប្រាស់នៅក្នុងសាលាឃុំ ដូចជា តុ កៅអី កុំព្យូទ័រ និងឯកសារផ្សេងៗសម្រាប់ប្រើប្រាស់ជារួមក្នុងដំណើរការកិច្ចការងារផ្សេងៗ។
- បង្កើនសមាសភាពមន្ត្រីរាជការឱ្យសមស្របទៅតាមទំហំឃុំ និងចំនួនប្រជាជនទៅតាមមូលដ្ឋានដើម្បីឱ្យពួកគាត់មានភាពងាយស្រួលក្នុងការអនុវត្តការងារបានឆាប់រហ័ស។
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែត្រួតពិនិត្យបន្ថែមទៀត និងវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកឃុំ សង្កាត់អំពីការប្រើប្រាស់ឥរិយាបថទៅលើប្រជាពលរដ្ឋថា តើបុគ្គលិកនីមួយៗ មានអាកប្បកិរិយាគួរសមដែរឬទេនៅពេលប្រជាពលរដ្ឋមកទទួលសេវាឬសាកសួរព័ត៌មានផ្សេងៗ។

# គន្ថនិទេស

- **ច្បាប់ និងបទដ្ឋានគតិយុត្ត**
  - ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
  - ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
  - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
  - ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១
  - អនុក្រឹត្យលេខ២៦ អនក្រ/បក ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ឆ្នាំ២០០២
  - អនុក្រឹត្យលេខ២២ អនក្រ/បក ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០២
  - អនុក្រឹត្យលេខ១៦ អនក្រ/បកស្តីពីមូលនិធិឃុំ សង្កាត់
  - ព្រះរាជក្រឹត្យ លេខ នស/រកម/១២០៨/១៤២៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨។ ព្រះរាជក្រឹត្យ លេខ នស/រកម/ ១០១៤/១១៧៤ ស្តីពីកែសម្រួលនិងបន្ថែមសមាសភាពថ្មី នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ២០១៤។
  - អនុក្រឹត្យ លេខ ៤៥៦ ស្តីពីការផ្ទេរធនធានពីថវិកាជាតិ ទៅមូលនិធិឃុំ សង្កាត់ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៣។ អនុក្រឹត្យ លេខ ៣៤២ ស្តីពីការផ្ទេរធនធាន ពីថវិកាជាតិ ទៅមូលនិធិក្រុង-ស្រុក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤។
  - ប្រកាស ក្រសួងពាណិជ្ជកម្ម លេខ១៦៨/២០១០ ស្តីពីការធ្វើប្រតិភូកម្មកិច្ចការពាណិជ្ជកម្មទៅទីក្រុង និងស្រុកគោលដៅ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០។
  - ប្រកាស ក្រសួងសុខាភិបាល លេខ០៧៧ ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យសុខាភិបាលទៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងការផ្តល់សេវាសាធារណៈរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៥។
  - ប្រកាស ក្រសួងមហាផ្ទៃ លេខ៦០៤៩ ស្តីពីការធ្វើប្រតិភូកម្មមុខងារសេវាសាធារណៈ និងអត្តប្រយោជន៍ស្តីពីស្ថិតិប្រជាពលរដ្ឋ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៥។
  - ប្រកាសស្តីពី តួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ លេខ ១៣២៩ ប្រ.ក,ឆ្នាំ២០០១។

- **សៀវភៅ**
  - ក្រសួងមហាផ្ទៃ ឆ្នាំ២០១៧ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ
  - ក្រសួងមហាផ្ទៃ ឆ្នាំ២០០៧ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ
  - អនុបណ្ឌិត ហៀង សាង ឆ្នាំ២០១១ នីតិរដ្ឋបាលទូទៅ
  - គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហជ្ឈការឆ្នាំ២០០៧ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ
  - អ៊ុង ចំរើន,សិក្ខាប័ននីតិរដ្ឋបាលបោះពុម្ពលើកទី១ ភ្នំពេញ ២០១១
  - ហៀងសាង,ការគ្រប់គ្រងរដ្ឋបាលដែនដី, ភ្នំពេញ២០១៥។
- **ឯកសារផ្សេងៗ**
  - កម្មវិធីវិនិយោគឃុំ
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- **ដកស្រង់ចេញពី Website**
  - ក្រសួងមហាផ្ទៃ៖ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ,ខែកក្កដា ឆ្នាំ២០១៧៖ http://sihanoukville.gov.kh/wp-content/uploads/2017/01/2017-CS-Decentralization-Mgt-final.pdf
  - សរសេរដោយ ខុមហ្វ្រែល ៖"ស្វ័យភាពក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោលនយោបាយវិមជ្ឈការ" ៖ https://www.nec.gov.kh/khmer/content/2627?fbclid=IwAR1Ppy0c0Dbvh9fqRvDQZg_4zS85_KHNSeyvhcEGMXBbdz79o8bMEpWnphQ
  - ឯកសារស្តីពីស្ថាប័ន ម.ស.ម.ក "ក្រុមប្រឹក្សាឃុំ/សង្កាត់" លេខ២,ខែកុម្ភៈ ឆ្នាំ២០១២ https://cchrcambodia.org/admin/media/factsheet/factsheet/khmer/2012_02_24_CCHR_Institutions_Series_Fact_Sheet_Commune_Councils_(KHM).pdf
  - គ.ជ.អ.ប ៖កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តម្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍមូលដ្ឋានកាន់តែល្អប្រសើរ,ថ្ងៃចន្ទ, 3 ខែធ្នូ 2018 https://ncdd.gov.kh/news-kh/feature1-03122018/
  - ទស្សនទានអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា,ខែវិច្ឆិកា ឆ្នាំ២០១៦ http://www.mcs.gov.kh/training2016/con-sources/training-1-2-pdf
  - សេចក្តីណែនាំស្តីពី៖ ការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ,រដ្ឋាភិបាល លេខ០២ ស.ណ.ន, ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨ https://www.moe.gov.kh/wpcontent/uploads/2018/08/5_6294066622856429603.pdf
  - តួនាទី មុខងារ និង អំនាចនៃរដ្ឋបាល ឃុំ សង្កាត់
  - https://www.interior.gov.kh
  - https://www.coj.gov.kh
  - http://kh.cisa.org.kh ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី២
# អនុក្រឹត្យស្តីពី ការផ្ទេរវិមជ្ឈការ
# អំណាច តួនាទី និងភារកិច្ច ទៅឱ្យ
# ក្រុមប្រឹក្សាឃុំ សង្កាត់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរសិទ្ធិរដ្ឋបាលអំណាច តួនាទី និង ភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃ ទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**សំរេច**

## ជំពូកទី១

## ការប្រគល់អំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអភិបាលកិច្ចរបស់ឃុំ សង្កាត់

**មាត្រា ១.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាឃុំ សង្កាត់មួយ ។

ឃុំ សង្កាត់មានមុខងារ អំណាច និងករណីយកិច្ចក្នុងការគ្រប់គ្រង និង ធ្វើអភិបាលកិច្ចក្នុងឃុំ សង្កាត់របស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋាននានាជាធរមាន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសតាំងឡើង ដោយការបោះឆ្នោតស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋទាំងអស់នៅក្នុង ឃុំ សង្កាត់របស់ខ្លួន។

**មាត្រា ២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់លិខិតជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ និង ប្រមូលជូនអភិបាលខេត្ត ក្រុងនីមួយៗនូវ ÷

- បញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតជាផ្លូវការតាមឃុំ សង្កាត់នីមួយៗ
- ឈ្មោះរបស់បេក្ខជនដែលត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- ឈ្មោះរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅ សង្កាត់រងទី១ និង ជំទប់ទី២ ចៅសង្កាត់រងទី២ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានជ្រើសចេញពីបញ្ជីឈ្មោះបេក្ខជនដែលបានជាប់ឆ្នោតជាផ្លូវការ
- ឈ្មោះសមាជិកថ្មីដើម្បីជំនួសសមាជិកនៃក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែងក្នុងករណីដែលមានសមាជិកណាម្នាក់នៃក្រុមប្រឹក្សាឃុំ សង្កាត់បានបោះបង់ចោលការងារ ឬ បានបញ្ឈប់ពីតំណែង។

**មាត្រា ៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវរៀបចំឱ្យមានកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១៤ថ្ងៃ យ៉ាងយូរបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

របៀបវារៈ នីតិវិធី និង កិច្ចដំណើរការនៃការប្រជុំលើកដំបូងនេះត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការថា " ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ " ។

មេឃុំមានងារជាផ្លូវការថា "មេឃុំ" និង ចៅសង្កាត់មានងារជាផ្លូវការថា "ចៅសង្កាត់ " ។

ជំទប់មានងារជាផ្លូវការថា "ជំទប់" និង ចៅសង្កាត់រង មានងារជាផ្លូវការថា ចៅសង្កាត់រង " ។

សមាជិកដែលបានជាប់ឆ្នោត ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានងារជាផ្លូវការថា " សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ " ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងមានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួនកាន់តំណែងនោះប៉ុណ្ណោះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានងារជាផ្លូវការតែក្នុងអំឡុងពេលដែលសាមីខ្លួននៅជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប៉ុណ្ណោះ ។

**មាត្រា ៥.-**

ឃុំ សង្កាត់នីមួយៗត្រូវមានស្មៀនឃុំ សង្កាត់មួយរូប ។

ស្មៀនឃុំ សង្កាត់ត្រូវបានតែងតាំង និងត្រូវបានប្រើប្រាស់ក្នុងរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ ។

ស្មៀនឃុំ សង្កាត់ត្រូវជួយ និង ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោមទៅតាមតួនាទី និងមុខងារដែលបានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងសំរាប់ដំណើរការ និង ចាត់ចែងកិច្ចប្រជុំព្រមទាំងអនុវត្តការកិច្ចរបស់ខ្លួន ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំផ្អែកលើមូលដ្ឋាននៃសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧.-**

សាលាឃុំ សង្កាត់ គឺជាការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជាទីចាត់ការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

សាលាឃុំ សង្កាត់ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការប្រចាំថ្ងៃស្របតាមម៉ោងធ្វើការរបស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

ក្នុងកំឡុងពេលម៉ោងធ្វើការប្រជាពលរដ្ឋមានសិទ្ធិ ÷

- ធ្វើទំនាក់ទំនង និង ធ្វើកិច្ចការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ទទួលពត៌មានអំពីសំណើ និង ការងារនានាពីក្រុមប្រឹក្សាឃុំ សង្កាត់

- មើល និង អានឯកសាររបស់ឃុំ សង្កាត់

- ចូលរួមយោបល់ ឬ តវ៉ាលើបញ្ហាណាមួយ ។

**មាត្រា ៨.-**

ឃុំ សង្កាត់គឺជាម្ចាស់លើលិខិត និង ឯកសារទាំងអស់ដែលបានប្រគល់ត្រឹមត្រូវដល់ ÷

- ការិយាល័យរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- គណៈកម្មាធិការណាមួយរបស់មេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬមន្ត្រីនៅការិយាល័យក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៩.-**

ឃុំ សង្កាត់គឺជាម្ចាស់លើរាល់លិខិត និង ឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សា ឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និង ជាម្ចាស់កម្មសិទ្ធិលើតែមប្រ៉ិ ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗ ទៀតទាំងអស់របស់ឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម តែមប្រ៉ិ ត្រា អោយបានត្រឹមត្រូវ និង គង់វង្ស ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវរៀបចំឱ្យមានក្តារខៀនពត៌មានសាធារណៈនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសកន្លែងដែលសមស្របដើម្បីដាក់ក្តារខៀនពត៌មានសាធារណៈនៅតាមភូមិ ។

ទីកន្លែងដែលដាក់ក្តារខៀនពត៌មានសាធារណៈត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ប្រសិនបើកន្លែងនោះមានអ្នកកាន់កាប់រួចហើយ ។

ក្តារខៀនពត៌មានសាធារណៈត្រូវសរសេរ ឬ បិទប្រកាសជូនដំណឹងជាផ្លូវការ និង ពត៌មានដទៃទៀតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការសរសេរ ឬ ការបិទប្រកាសពត៌មានជាសាធារណៈ ត្រូវរក្សាទុកអោយបានរយៈ យ៉ាងតិច១០ថ្ងៃ ។

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ជាតំណាង និង ជាអ្នកបំរើអោយផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាត្រូវលើកស្ទួយ និង សំរបសំរួលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយត្រូវរកប្រភពជំនួយកសាង និង តៀងគរសមត្ថភាព និង ធនធានពី ÷

- ក្នុងឃុំ សង្កាត់របស់ខ្លួនផ្ទាល់
- រាជរដ្ឋាភិបាល និង ក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល

- អង្គការជាតិ អន្តរជាតិ និង អង្គការនានានៅមូលដ្ឋាន
- ផ្នែកឯកជន និង សម្បុរសជននានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធភាព សំរាប់អនុវត្តន៍ក្នុងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវសំរបសំរួល និង លើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ ក្នុងឃុំ សង្កាត់ ដោយត្រូវបង្កើតឡើងនូវយន្តការដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល និង សហគមន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

កិច្ចពិភាក្សា និង ការអនុវត្តកិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានលក្ខណៈចំហរ និង មានតម្លាភាព។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយឃុំ សង្កាត់នីមួយៗមានធនធានមនុស្ស និង ធនធានសំភារៈសមស្របដើម្បីដំណើរការការងាររបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាអោយសមាជិករបស់ខ្លួន និង មន្ត្រីដែលបានតែងតាំងនៅក្នុងឃុំ សង្កាត់ឱ្យមានការយល់ដឹង និង មានឥរិយាបថសមស្រប ដើម្បីអនុវត្តតួនាទី និង ភារកិច្ចរបស់ខ្លួនតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និង លិខិតបទដ្ឋាន នានាជាធរមាន ។

**មាត្រា ១៤.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការពិនិត្យ និង វាយតំលៃអំពីសកម្មភាពនានាក្នុងការកសាងសមត្ថភាពសាធារណជននៅក្នុងឃុំ សង្កាត់ តាមរយៈ ÷

- ការបណ្តុះបណ្តាល
- ឯកសារ អត្ថបទ ទស្សនាវដ្តី និង សៀវភៅព័ត៌មានផ្សេងៗ
- ការអប់រំតាមរយៈ វិទ្យុ ទូរទស្សន៍ កាសែត និង ប្រព័ន្ធផ្សព្វផ្សាយដទៃទៀត..... ។

**មាត្រា ១៥.-**

ឃុំ សង្កាត់នីមួយៗត្រូវធ្វើសហការជាមួយឃុំ សង្កាត់ផ្សេងទៀតដើម្បីជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ។

តាមការស្នើសុំរបស់ឃុំ សង្កាត់ផ្សេងទៀត ឃុំ សង្កាត់សាមីអាចផ្តល់យោបល់ និង ផ្តល់សេវាគាំទ្រខាងរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុដល់ឃុំ សង្កាត់នោះ ។



មាត្រា ១៦.-

ក្នុងកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់មួយ ជាមួយឃុំ សង្កាត់ដទៃទៀត ត្រូវអនុវត្តទៅតាមកិច្ចព្រមព្រៀង ឬ តាមការចាត់ចែងរួម ដែលនឹងជួយសំរបសំរួលដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព។

ក្រសួងមហាផ្ទៃត្រូវជួយដល់ឃុំ សង្កាត់ដើម្បីរៀបចំកិច្ចព្រមព្រៀង ឬ ការចាត់ចែងការងាររួមគ្នានេះ ។

## ជំពូកទី២

## មេឃុំ ចៅសង្កាត់ គណៈកម្មាធិការនានា និង អ្នកជំនួយការ

មាត្រា ១៧.-

មេឃុំ ចៅសង្កាត់មានសិទ្ធិតែងតាំងគណៈកម្មាធិការជំនួយការនានា តាមការចាំបាច់ដើម្បីផ្តល់យោបល់ឱ្យខ្លួន ។

មាត្រា ១៨.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់តួនាទី ភារកិច្ច បទបញ្ជាផ្ទៃក្នុង និង នីតិវិធីធ្វើការងាររបស់គណៈកម្មាធិការទាំងនេះដោយអនុលោមទៅតាមស្មារតីនៃសេចក្តីណែនាំ និង លិខិតបទដ្ឋាននានារបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

មាត្រា ១៩.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ជានារីដើម្បីអោយទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែងតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារ ។

ជំនួយការទទួលបន្ទុកកិច្ចការនារី និង កុមារត្រូវបានផ្តល់សិទ្ធិអោយចូលរួមក្នុងរាល់កិច្ចពិភាក្សា ឬ កិច្ចប្រជុំរបស់គណៈកម្មាធិការនានារបស់ឃុំ សង្កាត់ និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

មាត្រា ២០.-

មេឃុំ ចៅសង្កាត់ត្រូវ ÷

- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គណៈកម្មាធិការជំនួយការនានារបស់ឃុំ សង្កាត់
- លើកយោបល់ដល់ក្រុមប្រឹក្សាអំពីរបៀបបង្កើន និង កសាងសមត្ថភាពនៃធនធានរបស់ឃុំ សង្កាត់ និង ក្រុមប្រឹក្សាឃុំ សង្កាត់
- លើកយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពីរបៀបកៀងគរធនធាន និង សមត្ថភាព ដើម្បីអភិវឌ្ឍន៍ឃុំ សង្កាត់

IK

របស់ខ្លួនពីប្រភពនានាមានជាអាទិ៍ ÷

- ភូមិទាំងអស់ក្នុងឃុំ សង្កាត់របស់ខ្លួន
- ឃុំ សង្កាត់ផ្សេង១
- រាជរដ្ឋាភិបាល និង ក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល
- ជំនួយឥតសំណងពីអង្គការជាតិ អន្តរជាតិ និង អង្គការនានានៅមូលដ្ឋាន
- ផ្នែកឯកជន និង សម្បុរសជននានា

– ស្វែងរកការចូលរួមក្នុងភាពជាដៃគូពីក្រុមប្រឹក្សាឃុំ សង្កាត់ដែលនៅក្បែរគ្នា

– លើកយោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ពីរបៀប ÷

- រៀបចំ និង អនុម័ត ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
- អនុវត្ត ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
- ត្រួតពិនិត្យ និង វាយតំលៃការអនុវត្តន៍ ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់
- រៀបចំ និង អនុម័តរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

– រាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ នៅរៀងរាល់ខែអំពីសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ខែកន្លងមក ព្រមទាំងការអនុវត្តន៍គោលនយោបាយ និង ការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

– ធានាអនុវត្តយ៉ាងត្រឹមត្រូវនូវរាល់សេចក្តីសំរេច និង ដីការបស់ឃុំ សង្កាត់

– ធានាគ្រប់គ្រង និង ត្រួតពិនិត្យយ៉ាងត្រឹមត្រូវកិច្ចការបរិវញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

– អនុវត្តកិច្ចការប្រចាំថ្ងៃក្នុងឃុំ សង្កាត់

– ពិនិត្យមើលការងាររបស់ស្មៀនឃុំ សង្កាត់ ។

មាត្រា ២១.–

ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ត្រូវជួយមេឃុំចៅសង្កាត់ លើបញ្ហាសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំទប់ទី២ ឬ ចៅសង្កាត់រងទី២ ត្រូវជួយមេឃុំចៅសង្កាត់ លើបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចការសង្គមកិច្ច រដ្ឋបាល សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់ អាចប្រគល់កិច្ចការបន្ថែមទៀតដល់ជំទប់ ឬ ចៅសង្កាត់រង របស់ខ្លួនតាមការចាំបាច់ ។

ក្នុងករណីមេឃុំ ឬ ចៅសង្កាត់អវត្តមានត្រូវធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅជំទប់ ឬ ចៅសង្កាត់រងតាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងរយៈពេលដែលមេឃុំ ចៅសង្កាត់នោះអវត្តមាន ។

ជំទប់ ឬ ចៅសង្កាត់រងមិនអាចចុះហត្ថលេខាលើឯកសារ លិខិតស្នាមនានា ដោយមិនមានការប្រគល់សិទ្ធិអំណាចពីមេឃុំ ចៅសង្កាត់ ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ ។

**មាត្រា ២២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសមេភូមិម្នាក់ នៅក្នុងភូមិនីមួយៗ ។

មេភូមិ ត្រូវតែងតាំង អនុប្រធានភូមិ និង សមាជិកភូមិ ដើម្បីធ្វើជាជំនួយការ ។

ប្រធានភូមិ អនុប្រធានភូមិ និង សមាជិកភូមិត្រូវតែជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៃភូមិនោះហើយត្រូវមានស្ត្រីយ៉ាងតិចមួយរូប ។

យោងតាមសភាពការណ៍ជាក់ស្តែងនៃភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវខិតខំជ្រើសរើសនារីអោយទទួលតំណែងជាមេភូមិ ឬ អនុប្រធានភូមិ ។

របៀបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការតែងតាំងអនុប្រធានភូមិ សមាជិកភូមិ ការផ្លាស់ប្តូរមេភូមិ និងជំនួយការ មេភូមិត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការអនុម័តយល់ព្រមពីគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា ២៣.-**

មេភូមិជាតំណាងអោយប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និង ជាខ្សែរយៈចំបងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិ និង ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ ជាតំណាងភូមិក្នុងការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការផ្តល់យោបល់អំពីកិច្ចការភូមិ ។

ក្នុងការសំរេចបញ្ហាណាមួយដែលពាក់ព័ន្ធនឹងភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិគ្រោះយោបល់ជាមួយមេភូមិជាមុនសិន ។

**មាត្រា ២៤.-**

មេភូមិត្រូវ ៖

- បង្កើនការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន

- ចូលរួមកិច្ចប្រជុំក្នុងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ដើម្បីផ្តល់យោបល់អំពីកិច្ចការដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួននៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ

- ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីតម្រូវការ និង ផលប្រយោជន៍របស់ភូមិ

- ផ្តល់យោបល់ដល់គណៈកម្មាធិការកិច្ចការភូមិ អំពីរបៀបបង្កើន និង កសាងសមត្ថភាពនៃធនធានរបស់ភូមិ

- ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និង ថវិកាអំពី ៖

• **តំរូវការ និង អាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងថវិកា និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

• **អនុវត្តថវិកា និង ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន**

• **ត្រួតពិនិត្យ និង វាយតំលៃ ការអនុវត្តថវិកា និង ផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន**

- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិ ដើម្បីបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់អោយដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ពិគ្រោះយ៉ាងទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន
- ដោះស្រាយបញ្ហាដែលជាផលប្រយោជន៍រួមជាមួយភូមិក្បែរខ្លា
- ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៥.–**

មេភូមិ មិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬ ការផ្ទេរអំណាច ឬ ការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ ។

មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិត្រូវជួបប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ។

**មាត្រា ២៦.–**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិភាក្សាជាមួយមេភូមិ ដើម្បីរៀបចំអោយមានទីកន្លែងសំរាប់មេភូមិជួបប្រាស្រ័យជាមួយមជ្ឈដ្ឋាននានាតាមភូមិនីមួយៗ ។

ទីកន្លែងនោះមានជាទីស្នាក់ការភូមិចំពោះកន្លែងដែលមានទីស្នាក់ការភូមិ ។ ចំពោះកន្លែងដែលគ្មានស្នាក់ការភូមិត្រូវពិគ្រោះពិភាក្សាគ្នាដើម្បីរកទីកន្លែងសមស្របណាមួយដែលអាចជាសាលារៀន វត្តអារាម វិហារសាសនា អាគារសាធារណៈ ឬ គេហដ្ឋានផ្ទាល់របស់មេភូមិ ។ ការជ្រើសរើសយកកន្លែងទាំងនេះត្រូវមានការពិគ្រោះពិភាក្សាអោយឯកភាពគ្នាពីក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ នឹងត្រូវមានការយល់ព្រមជាមុនពីម្ចាស់ទីកន្លែងទាំងនោះ ។ មេភូមិ និង ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្សព្វផ្សាយទីកន្លែងនោះដល់សាធារណៈជន ។

ទីកន្លែងនេះត្រូវបើកទទួលប្រជាពលរដ្ឋយ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍ ។

មេភូមិ ឬ អនុប្រធានភូមិ ឬ សមាជិកភូមិត្រូវមានវត្តមាននៅទីកន្លែងដែលបានកំណត់នោះនាថ្ងៃនោះ ដើម្បីជួបប្រជាពលរដ្ឋ ។

ក្រៅពីការជួបប្រាស្រ័យជាទៀងទាត់ជាមួយប្រជាពលរដ្ឋរបស់ខ្លួននៅទីកន្លែងដែលបានកំណត់នេះ មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិអាចនឹងជួយប្រាស្រ័យផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនជាប្រចាំតាមការចាំបាច់ ។

**មាត្រា ២៧.-**

មេភូមិត្រូវធានាផ្តល់ព័តមានឯកសារជាសាធារណៈដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ឯកសារព័តមានទាំងនោះអាចរួមមាន ពត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ និង ថវិកាឃុំ សង្កាត់ ។

**មាត្រា ២៨.-**

មេភូមិពុំមានសិទ្ធិអំណាចសំរេចបញ្ហាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានឡើយ ។

**មាត្រា ២៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬ គណៈកម្មាធិការ ឬ អង្គការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

## ជំពូកទី៣
## សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់

**មាត្រា ៣០.-**

ប្រជាពលរដ្ឋមានសិទ្ធិចូលរួមស្តាប់រាល់កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បាន ប៉ុន្តែពុំមានសិទ្ធិអនុម័តបានទេ ។

ប្រជាពលរដ្ឋអាចលើកសំណួរដល់មេឃុំ ចៅសង្កាត់ ឬ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោម ទៅតាមបទបញ្ជាផ្ទៃក្នុងសំរាប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣១.-**

ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬ ធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬ ការប្តឹងតវ៉ានោះជាក់ហិត ។

ចំពោះសំណើ ឬ ការប្តឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់អាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដោះស្រាយ ហើយចាត់អោយជូនពត៌មានអំពីការដោះស្រាយនោះដល់ប្រជាពលរដ្ឋវិញ រួចហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំបន្ទាប់ ។

4C

ចំពោះសំណើ ឬ ការប្ដឹងតវ៉ាទាំងឡាយណាដែលមេឃុំ ចៅសង្កាត់មិនអាចដោះស្រាយបានក្នុងសមត្ថកិច្ចរបស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវដាក់ក្នុងរបៀបវារៈអង្គប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

មេឃុំ ចៅសង្កាត់ ត្រូវជូនពត៌មានដល់ប្រជាពលរដ្ឋអំពីការដោះស្រាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣២.-**

ចំពោះសំណើ ឬ ការប្ដឹងតវ៉ា ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍ជូនក្រសួង ស្ថាប័ន ឬ ភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលមានសមត្ថកិច្ច ។

**មាត្រា ៣៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាផ្សព្វផ្សាយពត៌មានអោយបានទៀងទាត់ដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ អំពីបញ្ហាទាំងឡាយស្របតាមសមត្ថកិច្ចរបស់ខ្លួន និង អំពីសេចក្ដីសំរេចនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ជំពូកទី៤

## វិធានការវិន័យ និង ការបញ្ឈប់មុខតំណែងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៣៤.-**

រាល់ការចាត់វិធានការដាក់វិន័យចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ ដូចមានចែងក្នុងមាត្រា ៨៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើឡើងដោយសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមការបោះឆ្នោតយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

**មាត្រា ៣៥.-**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្ដល់ពត៌មានដល់ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៦ និង មាត្រា ៨៤ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៦.-**

ក្រោយពិនិត្យឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តត្រឹមត្រូវតាមសមត្ថកិច្ចរបស់ខ្លួនហើយ ក្រសួងមហាផ្ទៃត្រូវស្នើសុំទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការបញ្ឈប់ពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្នើអោយជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីមកជំនួសស្របតាមបែបបទ នីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៧.-**

បន្ទាប់ពីទទួលបានលិខិតសំណូមពររបស់ក្រសួងមហាផ្ទៃហើយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើសបេក្ខជនថ្មីដាក់ជំនួសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានបញ្ឈប់ពីតំណែង ស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៨.-**

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយ ដោយអនុលោមទៅតាមមាត្រា ៥៧ ឬ មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់មានរយៈពេលមិនលើសពី ១៨០ថ្ងៃ គិតចាប់ពីថ្ងៃរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់អោយមានការគ្រប់គ្រងឃុំ សង្កាត់នោះស្របតាមមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៣៩.-**

ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយ ដោយអនុលោមទៅតាមមាត្រា ៥៧ ឬ មាត្រា ៥៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយអណត្តិដែលនៅសល់មានរយៈពេលលើសពី ១៨០ថ្ងៃ ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ស្នើសុំអោយរៀបចំបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីមកជំនួស ។

ការបោះឆ្នោតឡើងវិញ ត្រូវរៀបចំឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា ៤០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវកំណត់កាលបរិច្ឆេទសំរាប់ការបោះឆ្នោតឡើងវិញក្នុងរយៈពេលយ៉ាងយូរ ៧ ថ្ងៃ បន្ទាប់ពីមានសំណើដែលតំរូវអោយមានការបោះឆ្នោតឡើងវិញ ។

**មាត្រា ៤១.-**

បន្ទាប់ពីបានទទួលបានលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃអំពីកាលបរិច្ឆេទសំរាប់ការបោះឆ្នោតឡើងវិញ គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតឡើងវិញដោយអនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ឈ.

## ជំពូកទី៥

## ទំនាក់ទំនងរវាងឃុំ សង្កាត់ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរ និង ភ្នាក់ងាររបស់រដ្ឋ

**មាត្រា ៤២.-**

រាល់ទំនាក់ទំនងជាផ្លូវការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរ ភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និង អន្តរជាតិនានា ត្រូវប្រព្រឹត្តទៅតាមរយៈក្រសួងមហាផ្ទៃ ។

**មាត្រា ៤៣.-**

ក្រសួងមហាផ្ទៃអាចធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ឱ្យជួយក្នុងកិច្ចការទំនាក់ទំនងនេះ និង សំរបសំរួលការអនុវត្តតួនាទី មុខងារ អំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការ និង អនុក្រឹត្យពាក់ពន្ធ័នានា ស្របទៅតាម សភាពការណ៍ជាក់ស្ដែង ។

ការធ្វើប្រតិភូកម្មអំណាចនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤៤.-**

ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់ពីរ ឬ ច្រើន និងធានាដោះស្រាយរាល់ទំនាស់ និង ជំលោះដែលក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះមិនអាចដោះស្រាយបាន។

**មាត្រា ៤៥.-**

ក្រសួងមហាផ្ទៃត្រូវសហ និង ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អង្គការអន្តរជាតិនានាដើម្បីដោះស្រាយទំនាស់ ឬ ជំលោះដែលកើតមានឡើងរវាងក្រសួង ស្ថាប័ន ឬ អង្គការទាំងនោះជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ ។

**មាត្រា ៤៦.-**

ក្រសួងមហាផ្ទៃត្រូវធានាថាការសំរុះសំរួល ការដោះស្រាយទំនាស់ និង ជំលោះរវាងឃុំ សង្កាត់ និង ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អន្តរជាតិ មានភាពយុត្តិធម៌ ត្រឹមត្រូវ រក្សាបាននូវផលប្រយោជន៍ទាំងសងខាង និង អនុវត្តបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

**មាត្រា ៤៧.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលអាចត្រួតពិនិត្យលើសេចក្ដីសំរេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ

ធ្វើអន្តរាគមន៍លើសេចក្តីសំរេច ឬ សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅពេលដែលការត្រួតពិនិត្យ ឬ ការធ្វើអន្តរាគមន៍ទាំងនោះត្រូវបានអនុញ្ញាតដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬ លិខិតបទដ្ឋានដទៃទៀត ដែលបានពិនិត្យ ឬ បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៤៨.-**

ក្រសួងមហាផ្ទៃអាចត្រួតពិនិត្យ ឬ ធ្វើអន្តរាគមន៍ផងដែរ ក្នុងករណីដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អង្គការជាតិ និង អង្គការអន្តរជាតិនានាបានធ្វើសេចក្តីរាយការណ៍ ឬ ប្តឹងតវ៉ាចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៤៩.-**

ក្រសួង ឬ ស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាបង្កលក្ខណៈសម្បត្តិឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តមុខងារ និង អំណាចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានត្រឹមត្រូវតាមនីតិវិធី ដែលបានតម្រូវដោយ ÷

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- រាជក្រឹត្យ
- អនុក្រឹត្យ ប្រកាស ឬ លិខិតបទដ្ឋាននានាដែលបានពិនិត្យ ឬ បានសម្រេចយល់ព្រមដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បទបញ្ជាផ្ទៃក្នុង ដីកា ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥០.-**

ក្នុងករណីដែលក្រសួង ស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្តមុខងារ និង អំណាចមិនត្រឹមត្រូវតាមនីតិវិធី និង តំរូវការផ្នែកច្បាប់ ក្រសួង ស្ថាប័នទាំងនោះត្រូវ ÷

- ផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់ក្រសួងមហាផ្ទៃ អំពីនីតិវិធី និង តំរូវការផ្នែកច្បាប់ ដែលតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្ត
- ធ្វើសំណើជាលាយល័ក្ខអក្សរទៅក្រសួងមហាផ្ទៃនូវកំហុសឆ្គងដែលតម្រូវឱ្យកែប្រែ និង ពេលវេលាដែលត្រូវកែប្រែ និង ផ្តល់ពត៌មានអំពីលទ្ធផលបញ្ចប់នៃការកែប្រែនោះ ។

**មាត្រា ៥១.-**

ក្រសួងមហាផ្ទៃត្រូវកំណត់ លក្ខណៈវិនិច្ឆ័យនៃការត្រួតពិនិត្យ និង ការធ្វើអន្តរាគមន៍ដូចតទៅ ÷

- ហេតុផលនៃកំហុសឆ្គង

- ប្រភេទនៃវិធានការ ឬ សកម្មភាពអន្តរាគមន៍ដែលនឹងត្រូវធ្វើ

- ការគាំទ្រ និង ការបង្កើនសមត្ថភាពណាមួយដែលត្រូវផ្តល់ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងការគ្រប់គ្រង ការអនុវត្តនីមុខងារ និង សិទ្ធិអំណាចឱ្យបានត្រឹមត្រូវ និង កាន់តែប្រសើរឡើង។

**មាត្រា ៥២.-**

ក្នុងការត្រួតពិនិត្យលើសេចក្តីសម្រេច និង សកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រសួងមហាផ្ទៃត្រូវ ÷

- ផ្តល់យោបល់ជាលាយល័ក្ខអក្សរដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីនីតិវិធី និង តំរូវការផ្នែកច្បាប់ទាំងឡាយដែលត្រូវអនុវត្ត

- ណែនាំជាលាយល័ក្ខអក្សរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតំរូវកំហុសឆ្គងក្នុងកំឡុងពេលមួយសមស្រប និង ត្រូវរាយការណ៍នូវលទ្ធផលនៃការកែតម្រូវនោះមកក្រសួងមហាផ្ទៃវិញ ។

**មាត្រា ៥៣.-**

ពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់គ្មានសមត្ថភាព ឬ គ្មានបំណងដើម្បីកែតំរូវកំហុសឆ្គង ក្រសួងមហាផ្ទៃត្រូវធ្វើកិច្ចការនោះជំនួសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តសេចក្តីសម្រេច និង កិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយក៏ត្រូវចាត់វិធានការចាំបាច់ផងដែរដើម្បីអភិវឌ្ឍន៍នូវសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**មាត្រា ៥៤.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល មិនអាចធ្វើសេចក្តីសម្រេចក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់បានទេ លើកលែងតែនៅក្នុងករណីដែលបានអនុញ្ញាតដោយច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស ឬ លិខិតបទដ្ឋាននានាដែលបានពិនិត្យ និង បានសម្រេចយល់ព្រម ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

សេចក្តីសំរេចដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលបានធ្វើឡើងក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែធានាថាក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តតាមនីតិវិធី និងតំរូវការផ្នែកច្បាប់ដែលបានចែងក្នុងករណីពិសេសនោះ ។

## ជំពូកទី៦

## មុខងារ និង អំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
## និង ការផ្ទេរអំណាចរបស់រដ្ឋទៅអោយឃុំ សង្កាត់

**មាត្រា ៥៥.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ ធ្វើកិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែស្នើសុំអនុញ្ញាតជាមុនពីគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៥៦.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ ធ្វើកិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្ទេរធនធាន និង សមត្ថភាព ជាចាំបាច់ដើម្បីធានាឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តបាននូវអំណាច ឬ ការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងដែលបានធ្វើប្រតិភូកម្មនោះ ។

ក្រសួងមហាផ្ទៃត្រូវកំណត់នីតិវិធីជាក់ស្តែងថែមទៀតដើម្បីអនុវត្តនូវបទប្បញ្ញត្តិនេះ។

**មាត្រា ៥៧.-**

ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវរាយការណ៍អំពីការធ្វើប្រតិភូកម្មអំណាច ឬ ការផ្ទេរការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងទាំងអស់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ជូនក្រសួងមហាផ្ទៃ និង អាជ្ញាធរខេត្ត ក្រុង ដែលពាក់ព័ន្ធ ។

**មាត្រា ៥៨.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចចុះកិច្ចព្រមព្រៀង ឬ ការចាត់ចែងការងារណាមួយជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ អង្គការជាតិ និង អន្តរជាតិ ឬ ផ្នែកឯកជនណាមួយ ដោយគ្មានការយល់ព្រមពីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥៩.-**

ក្រសួងមហាផ្ទៃត្រូវដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិភាក្សា និង អនុម័ត នូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណាមួយដែលបានស្នើឡើងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានបំណងធ្វើប្រតិភូកម្មអំណាច ឬ ការទទួលខុសត្រូវ ឬ កិច្ចព្រមព្រៀងណាមួយទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ តែកិច្ចព្រមព្រៀង ឬ ការចាត់ចែងនោះមិនមានចែងក្នុងប្រកាស ឬ គោលការណ៍ណែនាំដែលបានសម្រេចដោយគណៈកម្មាធិការជាតិ គាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦០.-**

ក្រសួងមហាផ្ទៃត្រូវត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និង ត្រូវធានាថាធនធាន សមត្ថភាព និង កំរៃដែលបានយល់ព្រមផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានប្រគល់ជូនយ៉ាងត្រឹមត្រូវ ។

**មាត្រា ៦១.-**

ឃុំ សង្កាត់មានតួនាទី និង មុខងារយ៉ាងទូលំទូលាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលក្នុងនោះមានមុខងារ និង តួនាទីជាមូលដ្ឋានគឺ ÷

- រក្សាសន្តិសុខ និង សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
- ចាត់ចែងសេវាកម្មសាធារណៈចាំបាច់ និង មើលការខុសត្រូវឱ្យកិច្ចការនោះដំណើរការបានល្អ
- លើកទឹកចិត្តអោយមានការបង្កើនផាសុខភាព និង សុខមាលភាពប្រជាពលរដ្ឋ
- ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច ហើយលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយមានលក្ខណៈ

ល្អប្រសើរឡើងជាលំដាប់

- ការពារ និង ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ

- ផ្សះផ្សាការខ្វែងមតិយោបល់គ្នា ហើយជំរុញអោយមានការយោគយល់ និង ការអត់ឱនទៅវិញទៅមករវាងប្រជាពលរដ្ឋ

- ទទួលរ៉ាប់រងលើកិច្ចការទូទៅបន្ថែមទៀត ដើម្បីបំពេញទៅតាមតំរូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៦២.-**

ឃុំ សង្កាត់ត្រូវអនុវត្តមុខងារមួយផ្នែក ឬ ទាំងអស់នៃមុខងារ និង ការទទួលខុសត្រូវដែលបានធ្វើប្រតិភូកម្មឱ្យបានសមស្របទៅនឹងធនធានដែលបានផ្តល់ ដើម្បីលើកស្ទួយ និង គាំទ្រដល់ការអនុវត្តន៍តួនាទី និង មុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រកបដោយចេរភាព និង បំពេញបានទៅតាមតំរូវការជាមូលដ្ឋាន ។

**មាត្រា ៦៣.-**

ឃុំ សង្កាត់មានសិទ្ធិជ្រើសរើស និង អនុវត្តសកម្មភាពណាមួយ ដែលស្ថិតនៅក្នុងសមត្ថកិច្ចនៃមុខងារជាទូទៅ និងដែលស្ថិតនៅក្នុងក៏រិតនៃធនធានដែលមាន ។

**មាត្រា ៦៤.-**

កិច្ចការជាក់លាក់មួយចំនួនត្រូវបានហាមឃាត់ មិនឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ អនុវត្ត រួមមាន ÷

- វិស័យព្រៃឈើ

- វិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍

- វិស័យការពារជាតិ

- វិស័យសន្តិសុខជាតិ

- វិស័យរូបិយវត្ថុ

- វិស័យនយោបាយក្រៅប្រទេស

- វិស័យគោលនយោបាយសារពើពន្ធ

- វិសយ័ផ្សេងទៀតដែលកំណត់ដោយក្រសួងមហាផ្ទៃ បន្ទាប់ពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ។

**មាត្រា ៦៥.-**

ឃុំ សង្កាត់អាចមានសិទ្ធិអំណាចដើម្បីជ្រើសរើស និង អនុវត្តសកម្មភាពដែលស្ថិតក្នុងតួនាទី និង មុខងារដែលនៅក្រៅយុត្តាធិការរបស់ខ្លួន ក្នុងករណីមានការអនុញ្ញាតពិសេសណាមួយពីក្រសួង ស្ថាប័ននានារបស់រដ្ឋ ផ្អែកតាមការសំរបសំរួលដោយក្រសួងមហាផ្ទៃ និង ត្រូវរាយការណ៍ជូនដល់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៦៦.-**

ឃុំ សង្កាត់ត្រូវចាត់ចែងនិងប្រើប្រាស់ធនធានដែលមាន ដើម្បីជ្រើសរើសនិងអនុវត្តសកម្មភាពរបស់ខ្លួន។

**មាត្រា ៦៧.-**

មុខងារ និង តួនាទីចំបងរបស់ឃុំ សង្កាត់គឺត្រូវសម្របសម្រួល និង ជំរុញឱ្យមានការអភិវឌ្ឍន៍ក្នុងឃុំ សង្កាត់របស់ខ្លួន ដោយត្រូវជ្រើសរើសវិធីសាស្ត្រសមស្រប និង មានប្រសិទ្ធិភាព ដើម្បីអនុវត្ត និង ផ្តល់សេវាកម្មអោយស្របតាមជំរើសដែលបានសំណូមពរដោយស្ថាប័នខាងលើ ។

**មាត្រា ៦៨.-**

ប្រសិនបើមុខងារ ឬ សេវាដែលឃុំ សង្កាត់ទទួលបានសិទ្ធិអំណាចដើម្បីអនុវត្ត កំពុងត្រូវបានផ្តល់អោយដោយភ្នាក់ងារ ឬ អង្គការដទៃទៀត ដោយមិនគិតក្នុងបន្ទុកចំណាយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់គួរទទួលស្គាល់កិច្ចការទាំងនេះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធ្វើការអភិវឌ្ឍន៍នៅកន្លែងដែលមិនទាន់មានអ្នកជួយគាំទ្រ ។

**មាត្រា ៦៩.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវសិក្សា និង កំណត់ឱ្យបានជាក់លាក់ថែមទៀតអំពីការបែងចែកមុខងាររវាងរដ្ឋបាលថ្នាក់កណ្តាល និង ឃុំ សង្កាត់ ។

ការបែងចែកខាងលើត្រូវមានគោលដៅដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តន៍។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវធ្វើការបែងចែករវាងសេវាកម្មដែលត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់កណ្តាល ភ្នាក់ងារនានារបស់រដ្ឋ អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ជាមួយសេវាកម្មដែលត្រូវផ្តល់ដោយឃុំ សង្កាត់ ។

**មាត្រា ៧០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការរៀបចំ ការអនុម័ត និង ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ និង ផែនការថវិកាឃុំ សង្កាត់របស់ខ្លួន ។

ការរៀបចំ ការអនុម័ត និង ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ និង ប្រើប្រាស់ថវិកាដោយអនុលោមទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនានាដែលបានសម្រេចដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ។

ԿԸ

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៧២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យឡើងវិញរាល់សកម្មភាពនៃការចាត់ចែង និង កិច្ចព្រមព្រៀងទាំងឡាយដែលបានរៀបចំឡើងក្នុងនាមឃុំ សង្កាត់ ឬ ដោយឃុំ សង្កាត់ផ្ទាល់ ឬ ភូមិមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទីមួយនេះ ។

ការចាត់ចែង ឬ កិច្ចព្រមព្រៀងទាំងនោះរួមមានការផ្ទេរអំណាច ឬ សិទ្ធិពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ឬ ការធ្វើសហប្រតិបត្តិការ ឬ ការជួយគាំទ្រពីកម្មវិធី និង អង្គការនានា ។

ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើការពិភាក្សាជាមួយគ្រប់ក្រសួង ស្ថាប័ន តំណាងកម្មវិធី និង អង្គការដែលពាក់ពន្ធ័ដើម្បី ÷

- បញ្ជាក់ថាកិច្ចព្រមព្រៀង ឬ ការចាត់ចែងដែលកំពុងអនុវត្ត ពិតជាបានអនុវត្តនៅក្នុងឃុំ សង្កាត់ ឬភូមិ របស់ខ្លួន
- ពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀង ឬ ការចាត់ចែងណា ដែលផ្ទុយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ឬ ផ្ទុយពីគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដើម្បីស្នើសុំធ្វើការកែសម្រួលអោយបានសមស្រប ។

**មាត្រា ៧៣.-**

ក្នុងអាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាបន័នានា របស់រាជរដ្ឋាភិបាល ដើម្បីកំណត់ និង បែងចែកភារកិច្ចជាក់លាក់រវាងរដ្ឋបាលថ្នាក់កណ្តាល ថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ។

**មាត្រា ៧៤.-**

គណកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវពិនិត្យបញ្ជាក់ថា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមានភាពសមស្រប ឬ មិនសមស្របទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

ច្បាប់ ព្រះរាជក្រឹ្យ អនុក្រឹត្យ និង លិខិតបទដ្ឋានណាដែលមិនសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវរៀបចំបែបបទ និង នីតិវិធីធ្វើវិសោធនកម្ម ឬ កែសំរួលអោយបានសមស្រប ។

**មាត្រា ៧៥.-**

គ្រប់ក្រសួង និង ស្ថាប័ននានារបស់រដ្ឋាភិបាលត្រូវ ÷

- បញ្ជាក់ថាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិត បទដ្ឋាន ទាំងអស់ដែលពាក់ពន្ធ័នឹងក្រសួង និង ស្ថាប័នរបស់ខ្លួនកំពុង អនុវត្តនៅតាមឃុំ សង្កាត់ និង ភូមិ ត្រូវតែសមស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង គោលនយោបាយវិមជ្ឈការ ។

- ពិនិត្យឡើងវិញនូវច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានដែលផ្ទុយនឹងគោលការណ៍វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ពិនិត្យ និង ស្នើសុំធ្វើ វិសោធនកម្មជាបន្ទាន់ ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ៧៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះឱ្យ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី

# ឧបសម្ព័ន្ធទី៣
# ឯកសារឃុំពញាឮ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅគម្រោងថវិកាឃុំ

# ឆ្នាំ២០២០

## ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល

## ខែ មករា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្តាល

លេខ ៥៤១៧/ស.ជ.ណ

ថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

កណ្តាល ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលខេត្តកណ្តាល**

**ជម្រាបមក**

**លោកប្រធានក្រុមប្រឹក្សា ឃុំពញាឮ**

**កម្មវត្ថុ៖** ស្តីពីការទទួលស្គាល់គម្រោងថវិកា ឆ្នាំ ២០២០ របស់ ឃុំពញាឮ ស្រុកពញាឮ ។

**យោង** ៖ព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង ឃុំ សង្កាត់

-អនុក្រឹត្យលេខ២៦អនក្រ.បចុះថ្ងៃទី០២ ខែ មេសា ឆ្នាំ ២០០២របស់ រាជរដ្ឋាភិបាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់។

-ប្រកាសលេខ ១៨៨៤ ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចជូនដល់អភិបាល ខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ ។

-ប្រកាសអន្តរក្រសួង លេខ ២៤២៣ ប្រក ចុះថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និង កម្មវិធីវិនិយោគឃុំ សង្កាត់របស់ ក្រសួងមហាផ្ទៃ និង ក្រសួងផែនការ។

-ប្រកាសណែនាំ លេខ៣៣១សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០២ស្តីពីការរៀបចំនិងការអនុវត្តថវិកាឃុំ សង្កាត់របស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-សារាចរណែនាំលេខ ០០៥ សហវចុះ ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៩ ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-លិខិតលេខ ៥៤៩៨ សហវ.អហក ចុះថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០១៩ ស្តីពីការវិភាជន៍ ធនធានមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២០ ទូទាំងប្រទេស របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-លិខិតលេខ៥៧១៧ សហវ.អហក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការវិភាជន៍ធនធានបន្ថែមសម្រាប់ចំណាយអភិវឌ្ឍន៍ មូលដ្ឋានជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-លិខិតលេខ០០១ /២០សណ ចុះថ្ងៃទី១០ ខែ មករា ឆ្នាំ២០២០ ស្តីពីសំណើសុំបញ្ជាក់ទទួលស្គាល់គម្រោងថវិកាឆ្នាំ ២០២០ របស់ ឃុំ ពញាឮ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោកប្រធាន ក្រុមប្រឹក្សា ជ្រាបថាៈ គម្រោងថវិកា ឆ្នាំ ២០២០ របស់ ឃុំ ពញាឮ ស្រុក ពញាឮ បានដាក់ស្នើសុំការពិនិត្យ និងបញ្ជាក់ទទួលស្គាល់ថវិកា ក្នុងនោះរួមមាន៖

| | | | |
|---|---|---|---|
| ១-ចំណូលថវិកាសរុប | = | 347,606,939 រៀល | ក្នុងនោះ: |
| -ចំណូលចរន្ត | = | 347,606,939 រៀល | |
| -ចំណូលមូលធន | = | 00 រៀល | |
| ២-ចំណាយថវិកាសរុប | = | 347,606,939 រៀល | ក្នុងនោះ: |
| -ចំណាយចរន្ត | = | 347,606,939 រៀល | |
| -ចំណាយមូលធន | = | 00 រៀល | |

រដ្ឋបាលខេត្តយល់ព្រមតាមការស្នើសុំ របស់លោកប្រធានក្រុមប្រឹក្សាឃុំពញាឮ ដែលបានរៀបចំគម្រោងចំណូលចំណាយថវិកា ជាក់ស្តែងតាមចំណាត់ថ្នាក់សេដ្ឋកិច្ច នៃ មាតិកាថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិហើយត្រូវអនុវត្ត អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

អភិបាលខេត្ត

គង់ សោភ័ណ្ឌ

**ចម្លងជូន**

-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល

-រតនាគារខេត្តកណ្តាល

• ដើម្បីអនុវត្ត •

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្តកណ្ដាល
ស្រុកៈពញាឮ
ឃុំៈពញាឮ
លេខៈ០០១/២០៣.៣

ពញាឮ, ថ្ងៃទី ១០ខែមករាឆ្នាំ២០២០

សូមគោរពជូន

**ឯកឧត្តមអភិបាលខេត្តកណ្ដាល**

កម្មវត្ថុៈ សំណើសុំបញ្ជាក់ទទួលស្គាល់គំរោងថវិកាឆ្នាំ២០២០។

យោងៈ
- ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ខែមិនាឆ្នាំ២០០១ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។
- អនុក្រិត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈឆ្នាំ២០០២របស់រាជរដ្ឋាភិបាលស្ដីពីមូនិធិឃុំ សង្កាត់។
- អនុក្រិត្យលេខ២៦អនក្រ.បកចុះថ្ងៃទី០២ខែមេសាឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់ ។
- ប្រកាសលេខ ១៨៨៤ប្រក. ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្ដីពីការធ្វើប្រតិភូកម្មអំណាចជូនដល់អភិបាលខេត្តក្រុងក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ប្រកាសអន្តរក្រសួងលេខ ២៤២៣ប្រក. ចុះថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០០៧ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគ ឃុំ សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ។
- ប្រកាសណែនាំលេខ៣៣១សហវ.ប្រកចុះថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០០២ស្ដីពីការរៀបចំនិងការអនុវត្តថវិកាឃុំ សង្កាត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- លិខិតលេខ ៥៨៧៤ សហវ.អហក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៧ ស្ដីពីការវិភាជន៍ធនធានមូលនិធិឃុំសង្កាត់ ទូទាំងប្រទេសឆ្នាំ២០១៨ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- កំណត់ហេតុស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ ពញាឮនៅថ្ងៃទី.២៩.ខែ..ធ្នូ.ឆ្នាំ ២០១៨. ។

តបតាមកម្មវត្ថុនិងយោងខាងលើ សូមអនុញ្ញាតជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ៖ គំរោងថវិការបស់ឃុំ ពញាឮ ស្រុក ពញាឮ ខេត្តកណ្ដាល ដែលបានដាក់ស្នើសុំការទទួលស្គាល់គម្រោងថវិកាក្នុងនោះរួមមានៈ

១-ចំណូលសរុប ៖ 347,606,939៛00 ក្នុងនោះ
- -ចំណូលចរន្ត 347,606,939៛00
- -ចំណូលមូលធន ............0........៛00

២-ចំណាយសរុប ៖ 347,606,939៛00ក្នុងនោះ
- -ចំណាយចរន្ត 347,606,939៛00
- -ចំណាយមូលធន ........0..........៛00

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យនិងបញ្ជាក់ទទួលស្គាល់គម្រោងថវិកាឆ្នាំ ២០២០ដោយសេចក្ដីអនុគ្រោះ ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ។

សូមជូនភ្ជាប់នូវឯកសារៈអនុសារណៈ ទម្រង់ថវិកា និងកំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំ ។

<u>ចំលងជូន</u>
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្ដាល
- រតនាគារខេត្តកណ្ដាល (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ

រដ្ឋបាលខេត្តកណ្តាល
រដ្ឋបាលស្រុកៈ ពញាឮ
ឃុំៈ ពញាឮ
លេខៈ០០១/២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធ្វើនៅពញាឮ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២០

**អនុសារណៈ**

**ស្តីពី**

**ការរៀបចំគម្រោងថវិកាឆ្នាំ ២០២០**

I. អំពីចំណូលថវិកាចរន្ត

| | | | |
|---|---|---|---|
| ក- សរុបចំណូលចរន្ត (ក+ខ) | សរុបចំនួន | **347,606,939** | រៀលក្នុងនោះមាន៖ |
| ក្រុមទី ១: ចំណូលពិត (ប្រ.១ + ប្រ.២) | | **347,606,939** | រៀល |
| ប្រភេទទី ១: ចំណូលសារពើពន្ធ | | | រៀល |
| ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ | | **347,606,939** | រៀល |
| **២: ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា(73)** | សរុបចំនួន | **1,000,000** | រៀល |
| - ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ (7301) | : | - | រៀល |
| + ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា (73011) | : | - | រៀល |
| + ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈផ្សេងៗទៀត (73018) | : | - | រៀល |
| - ផលពីការគ្រប់គ្រងរដ្ឋបាល (7302) | : | 1,000,000 | រៀល |
| + ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ **(73028)** | : | 1,000,000 | រៀល |
| ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ ឆ្នាំ២០១៩ **(73028)** | : | - | រៀល |
| ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ ឆ្នាំ២០២០ **(73028)** | : | 1,000,000 | រៀល |
| - ការផ្តល់សេវាកម្ម (7304) | : | - | រៀល |
| + សេវាសុរិយោដី (73043) | : | | រៀល |
| + សេវាសំណង់ (73044) | : | | រៀល |
| + ផលពីសេវាផ្សេងៗទៀត (73048) | : | | រៀល |
| - ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗទៀត (7502) | : | - | រៀល |
| + ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗ (73058) | : | | រៀល |
| + មូលនិធិបន្ថែម1%ពីថ្នាក់ជាតិ (75111) | | 95,630,000 | រៀល |
| **៣:ការឧបត្ថម្ភ អំណោយ (75)** | សរុបចំនួន | **250,976,939** | រៀល |
| - ឧបត្ថម្ភធនពីថ្នាក់ជាតិ (7501) | | 115,820,000 | |
| ឧបត្ថម្ភធនពីថ្នាក់ជាតិ សម្រាប់ចំណាយដំណើការ(75011) | | 115,820,000 | |

យោងតាមលិខិតលេខ ៥៦៦៣ សហវ.អហក ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការវិភាជន៍ធនធាន មូលនិធិឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់ ឆ្នាំ២០២០ ដែលក្នុងនោះ ឃុំ ពញាឮ បានទទួលថវិកាសំរាប់ចំណាយរដ្ឋបាលចំនួន ៖ 115,820,000 រៀល

| | | | |
|---|---|---|---|
| - ឧបត្ថម្ភកធន រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (7502) | : | - | រៀល |
| + ឧបត្ថម្ភកធនពីរាជធានី ខេត្ត (75021) | : | | រៀល |
| + ឧបត្ថម្ភកធនពីក្រុង ស្រុក ខណ្ឌ (75022) | : | | រៀល |
| + ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗ (75023) | : | | រៀល |
| - ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន (7503) | : | **23,806,000** | រៀល |
| ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន (75031) | | **23,806,000** | |
| - ឧបត្ថម្ភកធនចរន្តពីក្រៅប្រទេសទ្វេភាគី (7504) | : | | រៀល |
| - ឧបត្ថម្ភកធនចរន្តពីក្រៅប្រទេសពហុភាគី (7505) | : | | រៀល |
| - ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារគី (7506) | : | - | រៀល |
| + ពីក្រសួង ស្ថាប័ន (75061) | : | | រៀល |
| + ពីមន្ទីរជំនាញ (75062) | : | | រៀល |
| + ពីរាជធានី ខេត្ត (75063) | : | | រៀល |
| | : | | រៀល |

+ ពីក្រុង ស្រុក ខណ្ឌ (75064) : រៀល
+ ផ្សេងៗ (75068) : រៀល
- ចំណូលបដិភាគពីប្រជាពលរដ្ឋ សប្បុរសជនក្នុងនិងក្រៅប្រទេស (7507) : រៀល
- ចំណូលចរន្តពីប្រភពផ្សេងៗ (7508) : រៀល
- មូលនិធិបម្រុង (7510) : 15,926,939 រៀល
+ អតិរេកនៃការិយបរិច្ឆេទ (75101) 15,926,939
- ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ (7511) : 95,224,000 រៀល
- ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ (75111) 95,224,000

យោងតាមលិខិតលេខ៥៨៧៤ សហវ.អហក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការវិភាជន៍មូលនិធិឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់ឆ្នាំ ២០១៨ ។ ឃុំ: ពញ្ញាឮ បានទទួលថវិកាសម្រាប់ចំណាយវិនិយោគអភិវឌ្ឍន៍ មូលដ្ឋានចំនួន 119,030,000 រៀល យោងតាមការចាំបាច់របស់រដ្ឋបាលឃុំ និងគណៈកម្មាធិការសាងផែនការ និងថវិកាឃុំ បានឯកភាពវែកថវិកា 20% នេះចំនួន 23,806,000.00 រៀលត្រូវជាថវិកានេះនៅសល់ចំនួន 95,224,000.00 រៀលនឹងត្រូវប្រើប្រាស់សម្រាប់ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ។

- ឧបត្ថម្ភធនរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ (7512) : - រៀល
+ ឧបត្ថម្ភធនពីរាជធានី ខេត្តសម្រាប់ចំណាយវិនិយោគ (75121) : រៀល
+ ឧបត្ថម្ភធនពីក្រុង ស្រុក ខណ្ឌសម្រាប់ចំណាយវិនិយោគ (75122) : រៀល
+ ឧបត្ថម្ភធនពីឃុំ សង្កាត់សម្រាប់ចំណាយវិនិយោគ **(75123)** : រៀល
- ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តគម្រោង **(7513)** : 200,000 រៀល
+ ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តគម្រោង **(75131)** 200,000
- ឧបត្ថម្ភធនពីក្រៅប្រទេសទ្វេភាគី សម្រាប់ចំណាយវិនិយោគ (7514) : រៀល
- ឧបត្ថម្ភធនពីក្រៅប្រទេសពហុភាគីសម្រាប់ចំណាយវិនិយោគ (7515) : រៀល
- ចំណូលពីប្រជាពលរដ្ឋសប្បុរសជនក្នុងនិងក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ (7517) : រៀល
- ចំណូលពីប្រភពផ្សេងៗសម្រាប់ចំណាយវិនិយោគ (7518) : រៀល

**៤: ផលហិរញ្ញវត្ថុ(76)** សរុបចំនួន - រៀល
- ផលហិរញ្ញវត្ថុផ្សេងទៀត (7698) : រៀល

**៥: ផលផ្សេងៗ និងផលពិសេស(77)** សរុបចំនួន - រៀល
- ចំណូលពីការលក់អាគារ (7704) : រៀល
- ចំណូលពីការលក់បបនកម្ម បច្ចេកទេស សម្ភារ: និងហត្ថូបករណ៍ (7705) : រៀល
- ចំណូលពីការលក់រថយន្តដឹកជញ្ជូន (7706) : រៀល
- ចំណូលពីការលក់ឧបករណ៍ចុនជូន (7707) : រៀល
- ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម (7708) : រៀល
- ផលផ្សេងៗទៀត (7798) : រៀល

ខ- ក្រុមទី២ ចំណូលតាមដីកា (ប្រ.៣) : រៀល
ប្រភេទទី ៣: ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់) : រៀល
ខ - សរុបចំណូលជាមូលធន (ក + ខ) : រៀល
ក្រុមទី ១: ចំណូលពិត (ប្រ.១ + ប្រ.២) : រៀល
ប្រភេទទី ១: ចំណូលពីប្រភពផ្ទាល់ : រៀល
ប្រភេទទី ២: ចំណូលពីប្រភពខាងក្រៅ : រៀល
ប្រភេទទី ៣: ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់) : រៀល

## II. អំពីចំណាយថវិកាចរន្ត

ក- សរុបចំណាយចរន្ត (ក្រុមទី១ +ក្រុមទី២) សរុបចំនួន **347,606,939** រៀលក្នុងនោះមាន៖
ក្រុមទី ១: ចំណូលពិត (ប្រ.១ + ប្រ.២+ ប្រ.៣ + ប្រ.៤) សរុបចំនួន **347,606,939** រៀល
ប្រភេទទី ១: មធ្យោបាយសេវា សរុបចំនួន **343,606,339** រៀល
**១: ការទិញ (60)** សរុបចំនួន **15,595,400** រៀល
- សម្ភារៈផ្គត់ផ្គង់ថែទាំ (6001) : **5,000,000** រៀល
+ សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ-(60011) : - រៀល/ខែ x 12 ខែ = - រៀល
+ សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ-(60012) : - រៀល/ខែ x 12 ខែ = - រៀល
+ សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំ ផ្លូវថ្នល់ ស្ពាន និងលូ-(60013) : - រៀល/ខែ x 12 ខែ = - រៀល

| | | | | | | |
|---|---|---|---|---|---|---|
| + សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍-(60014) | - | រៀល/ខែ x | 12 ខែ | = | - | រៀល |
| + ប្រេងឥន្ធនៈ និងប្រេងរំអិល-(60015) | - | រៀល/ខែ x | 12 ខែ | = | 5,000,000 | រៀល |
| + សម្ភារៈផ្គត់ផ្គង់ថែទាំផ្សេងៗ-(60018) | - | រៀល/ខែ x | 12 ខែ | = | - | រៀល |
| - សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល (6002) | | | | | **6,115,400** | រៀល |
| + សម្ភារៈការិយាល័យ -(60021) | - | រៀល/ខែ x | 12 ខែ | = | 3,795,400 | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503) សម្ភារៈការិយាល័យប្រើឱ្យគម្រោង* | - | រៀល/ខែ x | 12 ខែ | = | - | រៀល |
| + សៀវភៅមើល និងឯកសារ-(60022) | | | | | | |
| + ការបោះពុម្ព -(60023) | - | រៀល/ខែ x | 12 ខែ | = | 2,320,000 | រៀល |
| *ថវិកាពីអភិវឌ្ឍន៍(7503) សម្ភារៈការិយាល័យប្រើឱ្យគម្រោង* | | | | | | |
| + សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ-(60028) | - | រៀល/ខែ x | 12 ខែ | = | - | រៀល |
| - ស្បៀងអាហារនិងផលិតផលកសិកម្ម (6003) | | | | | - | រៀល |
| + ស្បៀង-(60031) | - | រៀល/ខែ x | 12 ខែ | = | - | រៀល |
| + ស្បៀងសម្រាប់រដ្ឋបាល-(60037) | - | រៀល/ខែ x | 12 ខែ | = | - | |
| + ស្បៀងអាហារនិងផលិតផលកសិកម្មផ្សេងៗ-(60038) | - | រៀល/ខែ x | 12 ខែ | = | - | រៀល |
| - សំលៀកបំពាក់ និងការតុបតែង(6004) | | | | | **2,000,000** | រៀល |
| + ឯកសណ្ឋាន-(60041) | - | រៀល/ខែ x | 12 ខែ | = | 2,000,000 | រៀល |
